## រាជរដ្ឋាភិបាលកម្ពុជា

### របាយការណ៍ស្ដីពីវឌ្ឍនភាពនៃការអនុវត្ត

# គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

### ក្នុងឆ្នាំ២០២១-២០២៣

« តម្រង់ទិសទីផ្សារ និងបង្កើតលក្ខខណ្ឌអំណោយផល
ដើម្បីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម »



បានទទួលការឯកភាពពីរាជរដ្ឋាភិបាល
នាថ្ងៃចន្ទ ៦កើត ខែមាឃ ព.ស. ២៥៦៨
ត្រូវនឹងថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៥

# បុព្វកថា

ក្រោមម្លប់សន្តិភាពក្នុងរយៈពេលជិតបីទសវត្សរ៍កន្លងមក រាជរដ្ឋាភិបាលកម្ពុជាបានបន្តកសាងនូវសមិទ្ធផលធំៗជាបន្តបន្ទាប់ជូនជាតិមាតុភូមិលើគ្រប់វិស័យ ជាពិសេសការកសាងមូលដ្ឋានគ្រឹះរឹងមាំនៃសេដ្ឋកិច្ចជាតិសម្រាប់ការអភិវឌ្ឍ ការរក្សាបាននូវស្ថិរភាពនយោបាយនិងម៉ាក្រូសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រតាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវ **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤** និង របៀបវារៈគោលនយោបាយអភិវឌ្ឍសង្គម-សេដ្ឋកិច្ចនានា។ ទន្ទឹមនេះ ដើម្បីបន្តរក្សាចលនការនៃសុខសន្តិភាព កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយបរិយាបន្ននិងចីរភាព នៅក្នុងបរិការណ៍នៃពិភពលោកដែលកាន់តែប្រែប្រួល និងមិនប្រាកដប្រជា រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧នៃរដ្ឋសភា បានដាក់ចេញនូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** ដោយរួមបញ្ចូលនូវកម្មវិធីនយោបាយ និងវិធានការគន្លឹះៗប្រទាក់ក្រឡាគ្នានិងគ្រប់ជ្រុងជ្រោយ ក្នុងការជំរុញផលិតភាពនិងការធ្វើពិពិធកម្មសេដ្ឋកិច្ចជាតិ ការអភិវឌ្ឍធនធានមនុស្ស ការពង្រឹងអភិបាលកិច្ចនិងលើកកម្ពស់ស្ថាប័ន ព្រមទាំងការកសាងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ដែលជាគ្រឹះនិងមធ្យោបាយដ៏សំខាន់នៃការសម្រេចបាន **"ចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០"**។

ផ្អែកលើចក្ខុវិស័យដ៏វែងឆ្ងាយនេះ រាជរដ្ឋាភិបាលកម្ពុជា នៅតែចាត់ទុកការអភិវឌ្ឍវិស័យឧស្សាហកម្មពិសេស អនុវិស័យកម្មន្តសាល ជាយុទ្ធសាស្ត្រមូលដ្ឋានសម្រាប់ការគាំទ្រកំណើនប្រកបដោយចីរភាព និងភាពធន់។ ក្នុងន័យនេះ រាជរដ្ឋាភិបាល បាននិងកំពុងបន្តអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ (IDP) ដែលជាយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចថ្មី ដើម្បីជំរុញការអភិវឌ្ឍវិស័យនេះតាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង ការលើកកម្ពស់ផលិតភាព ការផ្ទេរបច្ចេកវិទ្យានិងអភិវឌ្ឍជំនាញ ការបង្កើនសមត្ថភាពសហគ្រាសធុនតូចនិងមធ្យមក្នុងស្រុក និងការបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ សំដៅរួមចំណែកសម្រេចបាននូវគោលដៅអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងឆ្លើយតបទៅនឹងការប្រែប្រួលនិម្មាបនកម្មសេដ្ឋកិច្ចក្នុងតំបន់ និងសកលលោកដែលកំពុងកើតមានឡើងជាបន្តបន្ទាប់។

កម្ពុជា បាននិងកំពុងបោះជំហានក្នុងល្បឿនកាន់តែលឿនជាងមុន ក្នុងការបង្កើនសកម្មភាពឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់, ការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចទាំងផ្នែកផលិតកម្ម និងទីផ្សារនាំចេញ, ការទាក់ទាញវិនិយោគផ្ទាល់ពីបរទេស, ការពង្រឹងសមាហរណកម្មរបស់ខ្លួនទៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់តំបន់និងសកល និងការបង្កើតការងារកាន់តែច្រើនក្នុងអនុវិស័យកម្មន្តសាលជូនប្រជាជនកម្ពុជា ក្នុងរយៈពេល ៨ឆ្នាំ (២០១៥-២០២៣) នៃការអនុវត្តគោលនយោបាយ IDP កន្លងមក។ ទន្ទឹមនឹងការសម្រេចបាននូវសមិទ្ធផលទាំងនេះ ការអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជាក៏នៅតែប្រឈមមុខនឹងបញ្ហាមួយចំនួនដែលត្រូវបន្តដោះស្រាយ ដើម្បីកាត់បន្ថយថ្លៃដើមផលិតកម្ម និងធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ចនិងវិនិយោគ។ លើសពីនេះ ហានិភ័យមួយចំនួនដូចជា ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល, ស្ថានភាពកាន់តែតានតឹងនៃភូមិសាស្ត្រនយោបាយនិងសេដ្ឋកិច្ច, ស្លាកស្នាមនៃវិបត្តិជំងឺកូវីដ-១៩, បរិវត្តកម្មបច្ចេកវិទ្យានិងឌីជីថល, បរិស្ថាននិងការប្រែប្រួលអាកាសធាតុ, ព្រមទាំងការត្រៀមខ្លួនចាកចេញរបស់កម្ពុជាពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួចជាដើម ក៏បាននិងកំពុងដាក់សម្ពាធ និងជះឥទ្ធិពលដល់សង្គម-សេដ្ឋកិច្ចកម្ពុជាផងដែរ។ ក្នុងស្មារតីនេះ

ការបន្តតាមដានវឌ្ឍនភាពនៃការអនុវត្តវិធានការដែលបានដាក់ចេញក្នុងគោលនយោបាយ IDP ពិតជាមានសារៈសំខាន់ និងចាំបាច់ ក្នុងគោលបំណងត្រួតពិនិត្យលើវឌ្ឍនភាពនិងបញ្ហាប្រឈម ដើម្បីជាមូលដ្ឋានក្នុងការរៀបចំវិធានការឆ្លើយតបលើបញ្ហាចំពោះមុខដែលកើតមានឡើងក្នុងពេលអនុវត្ត។ ដោយទទួលបានការប្រគល់ភារកិច្ចពីរាជរដ្ឋាភិបាល **ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** បានបន្តរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ IDP ក្នុងឆ្នាំ២០២១-២០២៣ នេះ ដែលនឹងផ្តល់ជាធាតុចូលដ៏សំខាន់បន្ថែមទៀតសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការគិតគូរ និងតម្រង់ទិសការអនុវត្តសម្រាប់ដំណាក់កាលបន្ទាប់ សំដៅធ្វើឱ្យវិស័យឧស្សាហកម្មកម្ពុជាកាន់តែរីកចម្រើនបន្ថែមទៀត។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ ក្នុងការអនុវត្តវិធានការដែលបានដាក់ចេញក្នុងគោលនយោបាយ IDP ឱ្យសម្រេចបានប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះ **គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ដែលបានដឹកនាំកិច្ចប្រជុំពិនិត្យ ពិភាក្សា និងផ្តល់ជាអនុសាសន៍តម្រង់ទិសល្អៗលើរបាយការណ៍ ព្រមទាំងការអភិវឌ្ឍវិស័យឧស្សាហកម្មជារួមផងដែរ។ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ **ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** ដែលមានលេខាធិការដ្ឋានដឹកនាំនិងសម្របសម្រួលការអនុវត្តគោលនយោបាយ IDP ជាសេនាធិការ និងគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ក្នុងការសហការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ IDP ក្នុងឆ្នាំ២០២១-២០២៣ នេះឡើង ប្រកបដោយការទទួលខុសត្រូវ និងស្មារតីសហការខ្ពស់។

ជាចុងក្រោយ ខ្ញុំសូមជំរុញគ្រប់ក្រសួង ស្ថាប័នទទួលបន្ទុកអនុវត្តវិធានការគោលនយោបាយ ត្រូវចូលរួមឱ្យបានពេញលេញក្នុងការអនុវត្តវិធានការដែលនៅសេសសល់ ប្រកបដោយប្រសិទ្ធភាពខ្ពស់និងភាពបុរេសកម្មក្នុងស្មារតីអភិក្រមរដ្ឋាភិបាលទាំងមូល និងជវភាពនៃប្រព័ន្ធតួអង្គតែមួយ ដើម្បីធានាបាននូវសមិទ្ធផលដ៏ជោគជ័យក្នុងការកែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជា។

ថ្ងៃចន្ទ ៦កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# មាតិកា


ខ្លឹមសារសង្ខេប.......................................................................................................I

១. សេចក្តីផ្តើម.......................................................................................................១

២. វិធីសាស្ត្រនៃការតាមដាន.......................................................................................................២

៣. ការតាមដានសមិទ្ធកម្មនៃការអនុវត្តគោលនយោបាយ IDP.......................................................................................................៤

៣.១. សមិទ្ធកម្មគោលបំណងទី១ “បង្កើនសកម្មភាពឧស្សាហកម្ម”.......................................................................................................៥

៣.២. សមិទ្ធកម្មគោលបំណងទី២ “បង្កើនការនាំចេញទំនិញឧស្សាហកម្ម និងកសិ-ឧស្សាហកម្ម”.......................................................................................................៧

៣.៣. សមិទ្ធកម្មគោលបំណងទី៣ “សេដ្ឋកិច្ចដែលមានភាពធន់ និងមានពិពិធកម្ម”.......................................................................................................៩

៣.៤. សមិទ្ធកម្មគោលបំណងទី៤ “ធ្វើឱ្យប្រសើរឡើងនូវគុណភាពការងារ”.......................................................................................................១២

៣.៥. សមិទ្ធកម្មគោលបំណងទី៥ “បង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមា”.......................................................................................................១៤

៣.៦. ការតាមដានវឌ្ឍនភាពជារួមនៃការអនុវត្តវិធានការគោលនយោបាយ IDP ក្នុងឆ្នាំ២០២១-២០២៣.......................................................................................................១៧

៤. បញ្ហាប្រឈម និងហានិភ័យ.......................................................................................................១៨

៤.១. បញ្ហាប្រឈមក្នុងការរៀបចំរបាយការណ៍.......................................................................................................១៨

៤.២. បញ្ហាប្រឈមក្នុងការអនុវត្តគោលនយោបាយ.......................................................................................................១៩

៤.៣. ហានិភ័យ.......................................................................................................១៩

៥. សេចក្តីសន្និដ្ឋាន និងទិសដៅបន្ត.......................................................................................................២៥

បរិសិដ្ឋ៖

បរិសិដ្ឋទី១៖ តារាងសង្ខេបអំពីសមិទ្ធកម្មក្នុងអន្តរាគមន៍គោលនយោបាយ និងការអនុវត្តវិធានការគោលនយោបាយ.............១

បរិសិដ្ឋទី២៖ រូបភាពបង្ហាញអំពីវឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយ ក្នុងឆ្នាំ២០២១-២០២៣ តាមគោលបំណង-គោលនយោបាយ.......................................................................................................២១

បរិសិដ្ឋទី៣៖ ម៉ាទ្រីសវិធានការឃើតយ៉ាវ.......................................................................................................២២

បរិសិដ្ឋទី៤៖ ម៉ាទ្រីសវឌ្ឍនភាពវិធានការ និងអនុវិធានការគោលនយោបាយ IDP.......................................................................................................២៦

បញ្ជីពាក្យកាត់.......................................................................................................I

បញ្ជីរូបភាព.......................................................................................................II

# ខ្លឹមសារសង្ខេប

បន្ទាប់ពីទទួលបានសុខសន្តិភាពពេញលេញ ស្ថេរភាពនយោបាយនិងម៉ាក្រូសេដ្ឋកិច្ច និងសណ្តាប់ធ្នាប់សង្គម តាមរយៈនយោបាយឈ្នះ-ឈ្នះ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានព្រឹទ្ធសភា** រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងអភិវឌ្ឍសង្គម-សេដ្ឋកិច្ច សម្រេចបានសមិទ្ធផល ដ៏ត្រចះត្រចង់។ ដើម្បីថែរក្សាសមិទ្ធផលដ៏ថ្លៃថ្លានេះ និងបន្តជំរុញកំណើនសេដ្ឋកិច្ច និងលើកកម្ពស់ជីវភាពរបស់ប្រជាជនកម្ពុជា **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានប្រកាសដាក់ឱ្យអនុវត្ត ‹យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១› ដែលជារបៀបវារៈគោលនយោបាយអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា។ ទោះបីជាកម្ពុជាទទួលរងនូវផលអវិជ្ជមានមួយចំនួនពីវិបត្តិកូវីដ-១៩ និងវិបត្តិសកលនានា រាជរដ្ឋាភិបាលបានប្រកាន់ខ្ជាប់នូវអភិក្រមបុរេសកម្មក្នុងការជម្នះ និងស្តារសេដ្ឋកិច្ចឱ្យងើបឡើងវិញយ៉ាងឆាប់រហ័ស ក្នុងឆ្នាំ២០២១ និងឆ្នាំបន្តបន្ទាប់ តាមរយៈការអនុវត្តក្របខណ្ឌគោលនយោបាយ និងវិធានការសង្គម-សេដ្ឋកិច្ចមុតស្រួច។ ការណ៍នេះ បានផ្តល់បច្ច័យជាវិជ្ជមានដល់កិច្ចអភិវឌ្ឍកម្ពុជា ពិសេស ការត្រៀមខ្លួនរបស់កម្ពុជាក្នុងការចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច (LDC) និងឈានទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

វិស័យឧស្សាហកម្ម ត្រូវបានកំណត់ជាវិស័យអាទិភាព ក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ និងបន្តចាត់ទុកជាវិស័យគន្លឹះក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ សម្រាប់រួមចំណែកក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ។ ឈរលើមូលដ្ឋាននេះ រាជរដ្ឋាភិបាលបានដាក់ចេញ និងបាននិងកំពុងអនុវត្តគោល-នយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ (IDP) ដែលជាមគ្គុទ្ទេសក៍ដ៏សំខាន់ក្នុងការតម្រង់ទិសការអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច, លើកកម្ពស់ឧត្តមភាពប្រកួត-ប្រជែងនៅក្នុងតំបន់ និងសកល, បង្កើនផលិតភាព, និងការពង្រីកទីផ្សារនាំចេញ ក្នុងគោលដៅប្រែក្លាយឧស្សាហកម្មកម្ពុជាពីឧស្សាហកម្មអតិពលកម្ម ទៅជាឧស្សាហកម្មផ្អែកលើជំនាញ និងមានតម្លៃបន្ថែមខ្ពស់។

ដោយទទួលបានសិទ្ធិប្រទានពីរាជរដ្ឋាភិបាល ក្នុងការតាមដានវឌ្ឍនភាព និងតម្រង់ទិសការអនុវត្តគោលនយោបាយ IDP ឱ្យកាន់តែមានប្រសិទ្ធភាព ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក.) បានសម្របសម្រួលរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពចំនួន២លើក (ឆ្នាំ២០១៦ និងឆ្នាំ២០១៧-២០១៨) និងរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ (MTR) ឆ្នាំ២០១៥-២០២០។ របាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោល-នយោបាយ IDP ឆ្នាំ ២០២១-២០២៣ ត្រូវបានរៀបចំឡើងក្នុងគោលបំណងពិនិត្យ និងតាមដានលើវឌ្ឍនភាពនៃការអនុវត្តតាមវិស័យទទួលបន្ទុកនីមួយៗ បញ្ហាប្រឈម និងទិសដៅបន្ត ស្របតាមការប្រែប្រួលនៃបរិការណ៍ជាតិ និងសកល។ របាយការណ៍នេះ ប្រើប្រាស់វិធីសាស្ត្រដែលអនុម័តក្នុងក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ IDP ដែលផ្តោតសំខាន់លើសមិទ្ធកម្មសម្រេចបានក្នុងកម្រិតគោលបំណងគោល-នយោបាយទាំង ៥ ដោយប្រើប្រាស់ប្រភពទិន្នន័យចំនួន ២ គឺប្រភពទិន្នន័យជាតិ និងប្រភពទិន្នន័យអន្តរជាតិ។

ផ្អែកតាមរបកគំហើញនៃរបាយការណ៍លទ្ធផលគន្លឹះ វឌ្ឍនភាពនៃគោលបំណងគោលនយោបាយទាំង ៥ ត្រូវបានរំលេចដោយសង្ខេបដូចខាងក្រោម៖

**១-សមិទ្ធកម្មគោលបំណងទី១** "បង្កើនសកម្មភាពឧស្សាហកម្ម"៖ តម្លៃបន្ថែមសរុបនៃវិស័យឧស្សាហកម្មសម្រាប់មនុស្សម្នាក់បានកើនឡើងជាបន្តបន្ទាប់ពី ៧៨០ដុល្លារអាម៉េរិក ក្នុងឆ្នាំ២០២១ ដល់ ៨៥៦ដុល្លារអាម៉េរិក ក្នុងឆ្នាំ២០២៣ ខណៈដែលតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាលសម្រាប់មនុស្សម្នាក់បានកើនឡើងពី ៥៣៣ដុល្លារអាម៉េរិក ដល់ប្រមាណ ៥៩១ដុល្លារអាម៉េរិក។ តម្លៃបន្ថែមសរុបនៃវិស័យឧស្សាហកម្ម និងកម្មន្តសាលសម្រាប់មនុស្សម្នាក់ក្នុងរយៈពេល៣ឆ្នាំនេះ សុទ្ធតែស្ថិតក្នុងអត្រាមួយខ្ពស់ជាងតួលេខក្នុងឆ្នាំ២០១៩ ដែលនេះបង្ហាញពីវឌ្ឍនភាពល្អប្រសើរជារួមនៃវិស័យទាំងពីរ ហើយជាវិស័យដែលកំពុងងើបឡើងវិញយ៉ាងឆាប់រហ័ស បន្ទាប់ពីទទួលរងនូវផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ និងផលជះពីវិបត្តិផ្សេងៗ។ គោលបំណងគោលនយោបាយនេះ មានវិធានការសរុបចំនួន ២០ ក្នុងនោះវិធានការដែលសម្រេចពេញលេញ មានចំនួន ១៤, កំពុងអនុវត្តមានចំនួន ៤, និងយឺតយ៉ាវមានចំនួន ២។

**២-សមិទ្ធកម្មគោលបំណងទី២** "បង្កើនការនាំចេញទំនិញឧស្សាហកម្ម និងកសិ-ឧស្សាហកម្ម"៖ ការនាំចេញផលិតផលកម្មន្តសាលសម្រាប់មនុស្សម្នាក់បានកើនឡើងពីប្រមាណ ៩៧៧ដុល្លារអាម៉េរិក នៅឆ្នាំ២០២១ ដល់ ១.១៣០ដុល្លារអាម៉េរិក នៅឆ្នាំ២០២២ ប៉ុន្តែបានធ្លាក់ចុះបន្តិចវិញដល់ ១.០៨៦ដុល្លារអាម៉េរិក នៅឆ្នាំ២០២៣។ តួលេខក្នុងឆ្នាំទាំងបីនេះសុទ្ធតែស្ថិតក្នុងកម្រិតមួយខ្ពស់ជាងតួលេខមុនវិបត្តិជំងឺកូវីដ-១៩ ដោយអត្រាកំណើនមធ្យមនៅចន្លោះឆ្នាំ២០២០ និង២០២៣ មានប្រមាណ១០% ក្នុងមួយឆ្នាំ ដែលបង្ហាញពីសញ្ញាណនៃការងើបឡើងវិញជាវិជ្ជមាននៃការនាំចេញផលិតផលកម្មន្តសាល បន្ទាប់ពីរងនូវផលប៉ះពាល់ពីវិបត្តិកូវីដ-១៩។ ជាមួយគ្នានេះ ទំហំនាំចេញកសិផលកែច្នៃចន្លោះឆ្នាំ២០២០ និង២០២៣ បានបន្តកើនឡើងក្នុងអត្រាកំណើនមធ្យមប្រចាំឆ្នាំក្នុងរង្វង់ ១២,១% ក្នុងមួយឆ្នាំ ដែលបានកើនដល់ប្រមាណ ១.១៩១លានដុល្លារអាម៉េរិក នៅឆ្នាំ២០២៣ ខណៈចំណែកនៃការនាំចេញកសិផលកែច្នៃធៀបនឹងការនាំចេញសរុប ធ្លាក់ចុះពី ៥,៤% នៅឆ្នាំ២០២១ មកត្រឹម ៤,៧% នៅឆ្នាំ២០២២ ប៉ុន្តែបានងើបឡើងវិញដល់ ៥,១% នៅឆ្នាំ២០២៣។ ការណ៍នេះបង្ហាញថា ខណៈដែលទំហំនៃការនាំចេញកសិផលកែច្នៃបានកើនឡើងជាបន្តបន្ទាប់ ការនាំចេញរបស់អនុវិស័យដទៃទៀត ហាក់មានការកើនឡើងខ្ពស់ជាងអនុវិស័យនេះទៅទៀត។ គោលបំណងគោលនយោបាយនេះ មានវិធានការសរុបចំនួន ២៨ ក្នុងនោះវិធានការដែលសម្រេចពេញលេញ មានចំនួន ១៦, កំពុងអនុវត្តមានចំនួន ៧, និងយឺតយ៉ាវមានចំនួន ៥។

**៣-សមិទ្ធកម្មគោលបំណងទី៣** "សេដ្ឋកិច្ចដែលមានភាពធន់ និងមានពិពិធកម្ម"៖ ចំណែកតម្លៃបន្ថែមនៃអនុវិស័យកម្មន្តសាល ៣ នាំមុខគេ ធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល ក្នុងរយៈពេល ៣ឆ្នាំចុងក្រោយនេះមាននិន្នាការប្រែប្រួល ដោយបានកើនឡើងបន្តិចបន្តួចពី ៧៦,៨% នៅឆ្នាំ២០២១ ដល់ ៧៧,២% នៅឆ្នាំ២០២២ ប៉ុន្តែបានធ្លាក់ចុះវិញត្រឹម ៧៤,៩% នៅឆ្នាំ២០២៣។ តួលេខជាមធ្យមពីឆ្នាំ២០១៥ ដល់២០២៣ នៃសូចនាករនេះ នៅតែស្ថិតក្នុងកម្រិតមួយខ្ពស់ក្នុងរង្វង់ ៧៧% ក្នុងមួយឆ្នាំ ដែលនេះបង្ហាញថាវិស័យកម្មន្តសាលរបស់កម្ពុជា នៅតែប្រមូលផ្តុំជុំវិញសកម្មភាពមួយចំនួនតូចប៉ុណ្ណោះ។ ចំណែកនៃការ

នាំចេញផលិតផលកម្មន្តសាលមិនមែនសម្លៀកបំពាក់ និងស្បែកជើង ធៀបនឹងការនាំចេញសរុប ក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ មាននិន្នាការប្រែប្រួល ដោយបានធ្លាក់ចុះពី ២១,២% ក្នុងឆ្នាំ២០២១ មកត្រឹម ១៨,៦% នៅឆ្នាំ២០២២ ប៉ុន្តែបានកើនឡើងវិញដល់ ២០,៦% ក្នុងឆ្នាំ២០២៣។ ទោះជាយ៉ាងណា ចំណែកនៃការនាំចេញផលិតផលកម្មន្តសាលមិនមែនសម្លៀកបំពាក់ និងស្បែកជើង ធៀបនឹងការនាំចេញសរុប ក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយ សុទ្ធតែស្ថិតក្នុងកម្រិតមួយខ្ពស់ជាងឆ្នាំ២០២០ ដែលនេះបង្ហាញពីវឌ្ឍនភាពវិជ្ជមាននៃពិពិធកម្មមុខទំនិញនាំចេញ។ គោលបំណងគោលនយោបាយនេះ មានវិធានការសរុបចំនួន ៤៣ ក្នុងនោះវិធានការដែលសម្រេចពេញលេញ មានចំនួន ២៦, កំពុងអនុវត្តមានចំនួន ១១, និងយឺតយ៉ាវមានចំនួន ៦។

**៤-សមិទ្ធកម្មគោលបំណងទី៤** "ធ្វើឱ្យប្រសើរឡើងនូវគុណភាពការងារ"៖ ចំនួនការងារក្នុង វិស័យកម្មន្តសាលមិនមែនកាត់ដេរ បានកើនឡើងជាបន្តបន្ទាប់ ដោយបានកើនឡើងពី ៤៨៧ពាន់នាក់ នៅឆ្នាំ២០២០ ដល់ ៥១៦ពាន់នាក់ ក្នុងឆ្នាំ២០២១។ ជាមួយគ្នានេះ ចំនួនការងារក្នុងវិស័យឧស្សាហកម្ម បានកើនឡើងពីប្រមាណ ២,៣លាននាក់ នៅឆ្នាំ២០២០ ដល់ ២,៥លាននាក់ ក្នុងឆ្នាំ២០២១ ខណៈចំណែកការងារក្នុងវិស័យឧស្សាហកម្មធៀបនឹងចំនួនការងារសរុបក៏បានកើនឡើងពី ២៤,៧% ទៅ ២៦,៤% ក្នុងឆ្នាំដូចគ្នា។ ការណ៍នេះបានបង្ហាញពីការងើបឡើងវិញនៃវិស័យឧស្សាហកម្មជារួម ដែលបានស្រូបទាញនូវកម្លាំងពលកម្មចូលទៅក្នុងវិស័យនេះបានច្រើនជាងមុន។ គោលបំណងគោលនយោបាយនេះ មានវិធានការសរុបចំនួន ៣២ ក្នុងនោះវិធានការដែលសម្រេចពេញលេញមានចំនួន៣០, កំពុងអនុវត្តមានចំនួន១, និងយឺតយ៉ាវមានចំនួន ១។

**៥-សមិទ្ធកម្មគោលបំណងទី៥** "បង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមា"៖ ទំហំនៃការនាំចូល និងនាំចេញផលិតផលកម្មន្តសាលមានការកើនឡើងទាំងក្នុងឆ្នាំ២០២១ និង២០២២ ខណៈដែលឱនភាពជញ្ជីងពាណិជ្ជកម្មមានការធ្លាក់ចុះពី៣,៩ប៊ីលានដុល្លារអាម៉េរិក នៅឆ្នាំ២០២១ មកត្រឹមប្រមាណ ៣,៤ប៊ីលានដុល្លារអាម៉េរិក នៅឆ្នាំ២០២២ ដែលការណ៍នេះបង្ហាញថា សមត្ថភាពផលិតផ្គត់ផ្គង់ក្នុងស្រុកហាក់មានភាពប្រសើរជាងមុន។ យ៉ាងនេះក្តី សមត្ថភាពផលិតផ្គត់ផ្គង់ក្នុងស្រុកនៅមិនទាន់អាចឆ្លើយតបនឹងកំណើនតម្រូវការប្រើប្រាស់ក្នុងស្រុក និងធាតុចូលផលិតកម្មសម្រាប់ផ្គត់ផ្គង់ក្នុងវិស័យកម្មន្តសាលក្នុងស្រុកបានពេញលេញនៅឡើយ។ យ៉ាងណាមិញ ទំហំនៃការនាំចូល និងនាំចេញផលិតផលកម្មន្តសាលនៅឆ្នាំ២០២៣ សុទ្ធតែមានការធ្លាក់ចុះ ខណៈឱនភាពជញ្ជីងពាណិជ្ជកម្មផលិតផលកម្មន្តសាលមានការធ្លាក់ចុះដល់ប្រមាណ ២,៥ប៊ីលានដុល្លារអាម៉េរិក នៅឆ្នាំ២០២៣។ ការណ៍នេះអាចបណ្តាលមកពីការធ្លាក់ចុះនៃសកម្មភាពសេដ្ឋកិច្ចបង្កដោយភាពមិនប្រាកដប្រជាសេដ្ឋកិច្ចសកល ព្រមទាំងការថយចុះនៃតម្រូវការសកល។ គោលបំណងគោលនយោបាយនេះ មានវិធានការសរុបចំនួន ៨ ក្នុងនោះវិធានការដែលសម្រេចពេញលេញ មានចំនួន ៤, កំពុងអនុវត្តមានចំនួន ៣, និងយឺតយ៉ាវមានចំនួន ១។

ក្នុងរយៈពេល ៣ឆ្នាំ កន្លងមកនេះ លទ្ធផលតាមដានវឌ្ឍនភាពលើការអនុវត្តវិធានការគោល-នយោបាយ បង្ហាញថា ក្នុងចំណោមវិធានការដែលគោលនយោបាយ IDP បានដាក់ចេញទាំងអស់ (រួមបញ្ចូលទាំងអនុវិធានការគាំទ្រ) មានវិធានការនិងអនុវិធានការដែលសម្រេចពេញលេញចំនួន ៩៧ ស្មើនឹង ៧០%, កំពុងអនុវត្តចំនួន ២៥ ស្មើនឹង ១៨% និង យឺតយ៉ាវចំនួន ១៦ ស្មើនឹង១២%។ បើធៀបនឹង

របាយការណ៍ MTR វិធានការនិងអនុវិធានការដែលសម្រេចពេញលេញ បានកើនឡើងចំនួន ២០, កំពុងអនុវត្ត និងយឺតយ៉ាវ បានថយចុះ ចំនួន ៣ និង ១៦ រៀងគ្នា។ គួរកត់សម្គាល់ផងដែរថា ក្នុងចំណោមវិធានការនិងអនុវិធានការដែលសម្រេចពេញលេញ ក៏មានវិធានការនិងអនុវិធានការទូទៅ ចំនួន ៧ ពាក់ព័ន្ធនឹងរដ្ឋបាលសារពើពន្ធទូទៅ, ការលើកកម្ពស់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីវិនិយោគសាធារណៈ សម្រាប់ការអភិវឌ្ឍឧស្សាហកម្ម និងការពង្រឹងការតាមដានការអនុវត្តគម្រោងវិនិយោគ ដែលជះផលដល់គោលបំណងគោលនយោបាយទាំងអស់ផងដែរ។

ទន្ទឹមនឹងវឌ្ឍនភាពគន្លឹះៗដែលសម្រេចបាន ដូចមានរៀបរាប់ខាងលើ ការអនុវត្តគោលនយោបាយនេះក៏បានជួបប្រទះបញ្ហាប្រឈម និងហានិភ័យមួយចំនួន ដែលទាមទារឱ្យមានការចូលរួមពីគ្រប់តួអង្គពាក់ព័ន្ធក្នុងការរៀបចំឡើងវិញនូវផែនការសកម្មភាពលម្អិតដើម្បីអនុវត្តគោលនយោបាយឱ្យបានគ្រប់ជ្រុងជ្រោយ និងប្រកបដោយប្រសិទ្ធភាពខ្ពស់ ។ បញ្ហាប្រឈមក្នុងការអនុវត្ត រួមមាន ១)ការផ្ទុះការរីករាលដាលនៃជំងឺកូវីដ-១៩ នៅកម្ពុជា ២)កង្វះធនធានមនុស្ស និងថវិកា, និង ៣)ពុំទាន់បានកំណត់គោលដៅថ្មីសម្រាប់សូចនាករគន្លឹះមួយចំនួន។

នៅក្នុងឆ្នាំកន្លងនេះ មានលេចចេញនូវនិន្នាការសកល និងតំបន់មួយចំនួន ដែលអាចជាកត្តាបង្កហានិភ័យដល់វិស័យឧស្សាហកម្មនៅកម្ពុជា ពិសេសអនុវិស័យកម្មន្តសាល នាពេលអនាគត មានដូចជា ៖

១) ភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយនិងសេដ្ឋកិច្ច៖ សង្គ្រាមពាណិជ្ជកម្ម និងបច្ចេកវិទ្យារវាងប្រទេសមហាអំណាច, ការអូសបន្លាយសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងជម្លោះនៅមជ្ឈិមបូព៌ា និងការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុរបស់ប្រទេសអភិវឌ្ឍន៍ បាននិងកំពុងយាយីដល់សន្តិសុខអន្តរជាតិ យន្តការពហុភាគីនិយម សកលភាវូបនីយកម្ម និងស្ថិរភាពហិរញ្ញវត្ថុសកល ហើយក៏បាននិងកំពុងជះឥទ្ធិពលជាអវិជ្ជមានផងដែរលើសេដ្ឋកិច្ចកម្ពុជា ជាពិសេស វិស័យឧស្សាហកម្ម។ ដើម្បីឆ្លុះបញ្ចាំងពីការប្ដេជ្ញាចិត្តខ្ពស់របស់ប្រមុខរាជរដ្ឋាភិបាលក្នុងការឆ្លើយតបនឹងបញ្ហាប្រឈមទាំងនេះ ពិសេសការចាត់ទុកវិស័យឯកជនជាដៃគូដ៏សំខាន់របស់រដ្ឋនិងជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចជាតិ និងក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ច និងវិនិយោគនៅកម្ពុជា នៅក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការកែទម្រង់មុតស្រួចចម្បងៗ ចំនួន១១ចំណុចជាកញ្ចប់ នៅក្នុងវិស័យដូចជា ពន្ធដារនិងគយ, ហេដ្ឋារចនាសម្ព័ន្ធនិងដឹកជញ្ជូន, ធនាគារនិងហិរញ្ញវត្ថុ និងវិស័យសំណង់និងអចលនទ្រព្យ ជាដើម។

(២) ការរុះរើខ្សែច្រវាក់ផ្គត់ផ្គង់ផលិតកម្ម៖ ការរង្គោះរង្គើដល់ខ្សែច្រវាក់ផ្គត់ផ្គង់ផលិតកម្មដែលបណ្ដាលមកពីជំងឺកូវីដ-១៩, ភាពតានតឹងខាងភូមិសាស្ត្រនយោបាយ និងសង្គ្រាមពាណិជ្ជកម្មរវាងអាម៉េរិកនិងចិន ព្រមទាំងការកើនឡើងនូវថ្លៃដើមផលិតនិងពលកម្មនៅក្នុងប្រទេសចិន ដែលជាមជ្ឈមណ្ឌលផលិតកម្មពិភព-លោក បានធ្វើឱ្យសាជីវកម្មពហុជាតិភាគច្រើនកែសម្រួលផែនការខ្សែច្រវាក់ផ្គត់ផ្គង់របស់ខ្លួន មកកាន់តំបន់អាស៊ាន ដែលមានថ្លៃពលកម្មប្រកបដោយភាពប្រកួតប្រជែង ហេដ្ឋារចនាសម្ព័ន្ធកាន់តែល្អប្រសើរ និងមានគោលនយោបាយវិនិយោគល្អ ដែលកត្តានេះអាចធ្វើឱ្យកម្ពុជាបាត់ឱកាសនិងផលប្រយោជន៍ ប្រសិនបើកម្ពុជា

ពុំបានត្រៀមខ្លួនឱ្យបានល្អ និងរក្សាបាននូវភាពប្រកួតប្រជែងរបស់ខ្លួនក្នុងការទាក់ទាញវិនិយោគ ជាពិសេសការវិនិយោគក្នុងវិស័យឧស្សាហកម្ម ដែលផ្តល់តម្លៃបន្ថែមខ្ពស់។

(៣) ឌីជីថលូបនីយកម្មក្នុងឧស្សាហកម្ម៖ បដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ បានបោះជំហានបណ្តើរៗចូលក្នុងវិស័យឧស្សាហកម្មកម្ពុជា។ ឌីជីថលូបនីយកម្ម (Digitalization) និងឌេខូបនីយកម្ម (Digitization) ជាកាំបិតមុខពីរដែលអាចផ្តល់នូវផលវិជ្ជមាន លើផ្នែកផលិតភាព ប្រសិទ្ធភាពសេដ្ឋកិច្ច ពិពិធកម្មសេដ្ឋកិច្ច ភាពប្រកួតប្រជែង និងច្រាស់មកវិញ ក៏បានផ្តល់នូវផលអវិជ្ជមានលើការអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា តាមរយៈការបង្កឱ្យមាននិកម្មភាពជារចនាសម្ព័ន្ធ សម្រាប់កម្មករនិយោជិតដែលគ្មានជំនាញ ឬមានកម្រិតជំនាញទាប។ ការណ៍នេះ ទាមទារឱ្យរាជរដ្ឋាភិបាលកម្ពុជាយកចិត្តទុកដាក់ពង្រឹងការបន្ទេរ បន្សាំ ចាប់យក និងពង្រឹងបច្ចេកវិទ្យា, នវានុវត្តន៍ឌីជីថល, ភាពជឿទុកចិត្តក្នុងបរិស្ថានឌីជីថល, សុវត្ថិភាពឌីជីថល និងបង្កើនការវិនិយោគលើមូលធនបច្ចេកវិទ្យា ពិសេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តតភ្ជាប់បច្ចេកវិទ្យា និងបណ្តាញ/ទិន្នន័យ។

(៤) បម្រែបម្រួលប្រជាសាស្ត្រ៖ កំណើនប្រជាជនវ័យចំណាស់នៅបណ្តាសេដ្ឋកិច្ចរីកចម្រើនមួយចំនួន ផ្តល់បច្ច័យអវិជ្ជមានចំពោះសក្តានុពលកំណើនសេដ្ឋកិច្ចក្នុងតំបន់ និងបណ្តាលឱ្យសកម្មភាពឧស្សាហកម្មបែបអតិពលកម្មហូរចូលទៅក្នុងបណ្តាសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ ដែលមានកត្តាប្រជាសាស្ត្រវ័យក្មេងពោរពេញដោយកម្លាំងពលកម្មច្រើន និងមានប្រាក់ឈ្នួលប្រកួតប្រជែងខ្ពស់។ ការណ៍នេះ ការត្រៀមខ្លួនចាប់យករំហូរទុនវិនិយោគ ក្នុងវិស័យឧស្សាហកម្មតែម្យ៉ាង គឺពុំទាន់គ្រប់គ្រាន់ឡើយ។ ដូច្នេះ ការបំពាក់បំប៉នជំនាញដល់កម្លាំងពលកម្មជាយុទ្ធសាស្ត្រគន្លឹះបន្ថែម គឺជាការចាំបាច់ ដើម្បីឈានទៅចាប់យករំហូរឧស្សាហកម្មដែលមានបច្ចេកវិទ្យានិងតម្លៃបន្ថែមខ្ពស់។

(៥) ការប្រែប្រួលអាកាសធាតុ និងការជំរុញសេដ្ឋកិច្ចបៃតង៖ កិច្ចសន្ទនាអំពីបរិស្ថាន និងការប្រែប្រួលអាកាសធាតុ មានការកើនឡើងជាលំដាប់ទាំងក្នុងតំបន់ និងពិភពលោក ព្រមទាំងគោលនយោបាយជាច្រើនត្រូវបានកំពុងដាក់ចេញដូចជា ការប្រើប្រាស់បច្ចេកវិទ្យាថាមពលបៃតង និងថាមពលកកើតឡើងវិញ ជាដើម។ ទោះបីជាកន្លងមក រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំតាក់តែងគោលនយោបាយនិងគោលការណ៍មួយចំនួនឆ្លើយតបនឹងបញ្ហាទាំងនេះ ដែលបានជំរុញឱ្យកម្ពុជាមានលទ្ធភាពប្រើប្រាស់ថាមពលស្អាតរហូតដល់ប្រមាណ ៦០% នាពេលបច្ចុប្បន្ន និងបន្តជំរុញឱ្យឈានទៅដល់៧០% នៅក្នុងឆ្នាំ២០៣០ក្តី រាជរដ្ឋាភិបាលកម្ពុជា និងតួអង្គពាក់ព័ន្ធទាំងអស់នៅក្នុងវិស័យឧស្សាហកម្មនៅកម្ពុជា ត្រូវបន្តរៀបចំដាក់ចេញនិងអនុវត្តគោលនយោបាយ និងវិធានការនានាបន្ថែម លើបញ្ហាប្រែប្រួលអាកាសតុ និងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចបៃតង រួមទាំងហេដ្ឋារចនា-សម្ព័ន្ធដឹកជញ្ជូននិងភស្តុភារកម្មបៃតង ដូចជា ប្រព័ន្ធដឹកជញ្ជូនតាមផ្លូវទឹកសាប គម្រោងព្រែកជីកហ្វូណនតេជោ ផ្លូវដែក និងប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ ជាដើម សំដៅរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ លើកកម្ពស់បរិស្ថាន និងធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្ន និងឈានទៅសម្រេចបានតាមគោលដៅរបស់រាជរដ្ឋាភិបាលស្តីពីអព្យាក្រឹតភាពកាបូននៅឆ្នាំ២០៥០។

(៦) ការចាកចេញពី LDC៖ ស្របគ្នានឹងការសម្រេចបាននេះ បញ្ហាប្រឈមមួយចំនួននឹងកើតមានឡើងចំពោះកម្ពុជាដូចជា៖ ការបាត់បង់នូវភាពអនុគ្រោះផ្នែកពាណិជ្ជកម្ម, ហិរញ្ញវត្ថុ, ជំនួយបច្ចេកទេស, និងភាព

អនុគ្រោះក្នុងភាពជាសមាជិកនៅក្នុងកិច្ចព្រមព្រៀង និងសហគមន៍អន្តរជាតិនានា ជាដើម ។ ផលប៉ះពាល់ផ្ទាល់មួយដែលសំខាន់បំផុតគឺ វិស័យពាណិជ្ជកម្ម បើទោះបីកន្លងមកនេះ កម្ពុជាបង្កើនកិច្ចចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTAs) ក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគី (អាស៊ាន (ASEAN), អាស៊ានបូក១ (ASEAN+1), កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP)។ល។) ក៏ដោយ ការបាត់បង់នូវភាពអនុគ្រោះផ្នែកពាណិជ្ជកម្ម សម្រាប់ទីផ្សារសហរដ្ឋអាម៉េរិក សហភាពអឺរ៉ុប និងទីផ្សារដទៃទៀតក្រោមប្រព័ន្ធអនុគ្រោះទូទៅសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច នៅតែជាហានិភ័យចៀសមិនផុតសម្រាប់វិស័យឧស្សាហកម្មនៅកម្ពុជា។ ក្នុងន័យនេះ ការបើកច្រកទីផ្សារតាមរយៈការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីបន្ថែម, ការបង្កើនភាពប្រទាក់ក្រឡាឱ្យកាន់តែស៊ីជម្រៅទៅនឹងខ្សែ-ច្រវាក់ផ្គត់ផ្គង់តំបន់និងសកល, ការជំរុញពិពិធកម្មឧស្សាហកម្ម, ការបង្កើនកម្លាំងចរចាបើកច្រកទីផ្សារ និងការបើកការចរចាឡើងវិញជាមួយសហរដ្ឋ-អាម៉េរិក និងសហភាពអឺរ៉ុប, និងការពង្រឹងបរិយាកាសអំណោយផលសម្រាប់ពាណិជ្ជកម្ម ធុរកិច្ច និងវិនិយោគបន្ថែមទៀត គឺជាកត្តាចាំបាច់ក្នុងការកាត់បន្ថយហានិភ័យខាងលើ។

សរុបជារួម សមិទ្ធកម្មនៃគោលបំណងគោលនយោបាយភាគច្រើន បានបង្ហាញពីវឌ្ឍនភាពវិជ្ជមានក្នុងការអនុវត្តគោលនយោបាយ IDP សម្រាប់រយៈពេល ៣ឆ្នាំនេះ (២០២១-២០២៣) បើទោះបីជាកម្ពុជាបានទទួលរងផលប៉ះពាល់ពីវិបត្តិនៃជំងឺកូវីដ-១៩, ភាពតានតឹងខាងភូមិសាស្ត្រនយោបាយ, សង្គ្រាមពាណិជ្ជកម្ម និងបច្ចេកវិទ្យារវាងប្រទេសមហាអំណាច, វិបត្តិសេដ្ឋកិច្ចសកល, និងវិបត្តិផ្សេងៗនៅតាមតំបន់ ក៏ដោយ។ ការណ៍នេះបានបង្ហាញពីការយកចិត្តទុកដាក់ខ្ពស់ និងការចាត់វិធានការប្រកបដោយប្រសិទ្ធភាព និងបុរេ-សកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តវិធានការគន្លឹះ ដែលបានដាក់ចេញសម្រាប់ស្តារសេដ្ឋកិច្ចកម្ពុជាឡើងវិញ ពិសេសវិធានការម៉ឺងម៉ាត់ចំពោះវិស័យឧស្សាហកម្ម និងកម្មន្តសាល។

ឆ្លើយតបទៅនឹងបញ្ហាប្រឈម និងហានិភ័យនានា ដែលអាចកើតឡើងជាយថាហេតុ កម្ពុជាត្រូវយកចិត្តទុកដាក់ក្នុងការបង្កើត និងជំរុញការវិនិយោគបៃតង ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននិងភស្តុភារកម្មបៃតង ហិរញ្ញប្បទានបៃតង និងអន្តរកម្មបៃតង ដែលកត្តាទាំងនេះគឺជាកាតាលីករក្នុងការជំរុញការធ្វើពិពិធកម្ម និងអភិវឌ្ឍឧស្សាហកម្ម និងសេដ្ឋកិច្ច ព្រមទាំងលើកកម្ពស់ផលិតភាព និងភាពប្រកួតប្រជែងរបស់កម្ពុជា ដើម្បីធានាបាននូវការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព បរិយាបន្ន និងភាពធន់។

# របាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្ត គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ក្នុងឆ្នាំ២០២១-២០២៣

"តម្រង់ទិសទីផ្សារ និងបង្កើតលក្ខខណ្ឌអំណោយផលដើម្បីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម"



## ១. សេចក្តីផ្តើម

លើមាគ៌ាសុខសន្តិភាព, សាមគ្គីភាពជាតិ, ស្ថិរភាពនយោបាយនិងម៉ាក្រូសេដ្ឋកិច្ច និងសណ្តាប់ធ្នាប់សង្គម, ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនា-បតីតេជោ ហ៊ុន សែន** **អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានព្រឹទ្ធសភា** អតីតរាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផល និងវឌ្ឍនភាពដ៏ត្រចះត្រចង់ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។ ជាក់ស្តែងក្នុងរយៈពេល ជាងពីរទសវត្សរ៍កន្លងមកនេះ រាជរដ្ឋាភិបាលសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ ដែលបានផ្តល់បច្ច័យវិជ្ជមានសម្រាប់កិច្ចអភិវឌ្ឍន៍ជាតិ ពិសេសការត្រៀមចាកចេញរបស់កម្ពុជាពី LDC និងការសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០។

ក្នុងកិច្ចប្រជុំពេញអង្គលើកទី១ របស់គណៈរដ្ឋមន្ត្រី នាថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានប្រកាសឱ្យអនុវត្ត ‹យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១› ដែលជារបៀបវារៈគោលនយោបាយអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា ដោយផ្អែកតាមសមិទ្ធកម្មដែលសម្រេចបានពីការអនុវត្តយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណទាំង៤ដំណាក់កាលកន្លងមក។ ក្នុងន័យនេះ, ដើម្បីធានាបាននិរន្តរភាពក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រជាតិដ៏មានប្រសិទ្ធភាពក្នុងការស្រូបយកកាលានុវត្តភាពសម្រាប់ការស្តារ និងពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ច ដែលឆ្លើយតបទៅនឹងការប្រែប្រួលយ៉ាងឆាប់រហ័សនៃបរិការណ៍សកល និងតំបន់ រួមទាំងភាពតានតឹងខាងភូមិសាស្ត្រនយោបាយ, ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល និងអស្ថិរភាពនៅតាមតំបន់មួយចំនួន រួមផ្សំនឹងភាពផុយស្រួយនៃសេដ្ឋកិច្ចដែលទើបងើបចេញពីវិបត្តិជំងឺកូវីដ-១៩, វិវាទពាណិជ្ជកម្មអន្តរជាតិ, បដិវត្តន៍ឧស្សាហកម្ម ៤.0, ការកើនឡើងនៃសេដ្ឋកិច្ចឌីជីថល, និងកំណើនសកលភាវូបនីយកម្ម។

តាមរយៈអាទិភាពដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ និងការបន្តចង្អុលបង្ហាញពីយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ វិស័យឧស្សាហកម្មត្រូវបានចាត់ទុកជាវិស័យគន្លឹះ ដែលបានដើរតួនាទីសំខាន់ក្នុងការរួមចំណែកដល់កំណើនសេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្ន និងអនាគត។ ឈរលើមូលដ្ឋាននេះ, រាជរដ្ឋាភិបាលបានបន្តអនុវត្តគោលនយោបាយ IDP ដែលជា

## ១. សេចក្តីផ្តើម

មគ្គទ្ទេសក៍ដ៏សំខាន់ក្នុងការតម្រង់ទិសកម្ពុជា តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច, លើកកម្ពស់ឧត្តមភាពប្រកួតប្រជែងនៅក្នុងតំបន់ និងសកល, បង្កើនផលិតភាព, និងការពង្រីកទីផ្សារនាំចេញ ក្នុងគោលដៅប្រែក្លាយឧស្សាហកម្មកម្ពុជាពីអតិពលកម្មទៅជាឧស្សាហកម្មផ្អែកលើជំនាញ និងបច្ចេកវិទ្យាទំនើប។

គោលនយោបាយ IDP ត្រូវបានអនុម័តដោយ គណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៥។ ក.អ.ក. ទទួលបានសិទ្ធិប្រទានពីរាជរដ្ឋាភិបាល ក្នុងការបំពេញតួនាទីជាស្ថាប័នដឹកនាំ និងសម្របសម្រួលការអនុវត្តគោលនយោបាយនេះ។ ក្នុងនាមជាសេនាធិការរាជរដ្ឋាភិបាល ក.អ.ក. បានបំពាក់មុខងារ និងយន្តការចាំបាច់សម្រាប់ការសម្រេចចិត្តផ្នែកគោលនយោបាយ ការសម្របសម្រួល ការរៀបចំតាមដាន និងវាយតម្លៃការអនុវត្តផែនការសកម្មភាពនានានៃគោលនយោបាយ IDP ក៏ដូចជាដោះស្រាយបញ្ហាប្រឈមនានា ដោយបានសហការយ៉ាងសកម្មជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ, ដៃគូអភិវឌ្ឍន៍, វិស័យឯកជន និងអង្គពាក់ព័ន្ធដទៃទៀត ក្នុងគោលបំណងសម្របសម្រួល ប្រមូលទិន្នន័យក្នុងការរៀបចំរបាយការណ៍វឌ្ឍនភាព និងការបញ្ជ្រាប និងជំរុញការអនុវត្តគោលនយោបាយនេះ។

ក្នុងស្មារតីនេះ ក.អ.ក. បានរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ IDP ចំនួន ២លើករួចមកហើយ៖ របាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ IDP ឆ្នាំ២០១៦ និង របាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ IDP ឆ្នាំ២០១៧-២០១៨ និងរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ (MTR) ឆ្នាំ២០១៥-២០២០។

ការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ IDP ឆ្នាំ ២០២១-២០២៣ គឺក្នុងគោលបំណងពិនិត្យតាមដានពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ IDP តាមវិស័យទទួលបន្ទុកនីមួយៗ បញ្ហាប្រឈម និងលើកឡើងនូវអនុសាសន៍សំខាន់ៗសម្រាប់ជាមូលដ្ឋានអនុវត្តបន្ត ស្របតាមការចង្អុលបង្ហាញនៃក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ IDP ដែលបានអនុម័តដោយគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បន្ទាប់ពីសេចក្តីផ្តើម របាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ IDP ឆ្នាំ២០២១-២០២៣ មានរចនាសម្ព័ន្ធដូចខាងក្រោម ៖

- **ផ្នែកទី២** វិធីសាស្ត្រនៃការតាមដាន
- **ផ្នែកទី៣** ការតាមដានសមិទ្ធកម្មកម្រិតយុទ្ធសាស្ត្រនៃការអនុវត្តគោលនយោបាយ IDP
- **ផ្នែកទី៤** បញ្ហាប្រឈម និងហានិភ័យ
- **ផ្នែកទី៥** សេចក្តីសន្និដ្ឋាន និងទិសដៅបន្ត។

## ២. វិធីសាស្ត្រនៃការតាមដាន

របាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ IDP ក្នុងឆ្នាំ២០២១-២០២៣ នេះត្រូវបានរៀបចំឡើងដោយប្រើប្រាស់ឧបករណ៍ចាំបាច់នៃប្រព័ន្ធតាមដាននិងវាយតម្លៃចំនួន ៣ រួមមាន៖ តក្កកម្មអន្តរាគមន៍, ក្របខណ្ឌតក្កកម្ម និងទម្រង់គំរូរបាយការណ៍ ដែលជាវិធីសាស្ត្រធ្លាប់បានប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍ MTR។

## ២. វិធីសាស្ត្រនៃការតាមដាន

**តក្កកម្មអន្តរាគមន៍** (Intervention Logic) គឺជាឧបករណ៍បង្ហាញពីរចនាសម្ព័ន្ធគោលរបស់គោលនយោបាយ IDP ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ ឧបករណ៍នេះបង្ហាញពីលទ្ធផលរំពឹងទុក រយៈពេលមធ្យម នៃការអនុវត្តវិធានការគោលនយោបាយ, គោលបំណង និងការរួមចំណែករបស់គោលនយោបាយ IDP ក្នុងគោលដៅអភិវឌ្ឍន៍ជាតិ (សូមមើលរូបភាពទី១)។

**ក្របខណ្ឌតក្កកម្ម** (Log-frame) គឺជាឧបករណ៍ដែលត្រូវបានប្រើប្រាស់ដើម្បីប្រែក្លាយតក្កកម្មអន្តរាគមន៍ទៅជាតារាងម៉ាទ្រីសដែលអាចវាស់វែងបាន ដោយប្រមូលផ្តុំព័ត៌មានពាក់ព័ន្ធទាំងអស់ និងកំណត់ថាសមាសធាតុផ្សេងៗ នៃតក្កកម្មអន្តរាគមន៍ត្រូវវាស់វែង "ដោយរបៀបណា"។ ក្នុងក្របខណ្ឌតក្កកម្ម សូចនាករត្រូវបានកំណត់ដើម្បីវាស់វែងសមិទ្ធកម្ម ឬវឌ្ឍនភាពតាមកម្រិតនីមួយៗ (ឧទាហរណ៍៖ គោលបំណងគោលនយោបាយ, អន្តរាគមន៍គោលនយោបាយ, និងវិធានការគោលនយោបាយ) រួមទាំងមានការបញ្ជាក់ប្រភពទិន្នន័យត្រឹមត្រូវ និងព័ត៌មានចាំបាច់ដទៃទៀត។ ជារួម សូចនាករគន្លឹះ (KPI) ចំនួន ៦៧ ត្រូវបានកំណត់ដើម្បីវាស់វែងសមិទ្ធកម្មរបស់គោលនយោបាយ IDP ក្នុងនោះ កម្រិតយុទ្ធសាស្ត្រមានចំនួន ៩ សូចនាករ និងកម្រិតវិស័យមានចំនួន ៥៨ សូចនាករ។ ការតាមដានវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ IDP ប្រើប្រាស់ប្រភពទិន្នន័យចំនួន២គឺ ទិន្នន័យដែលត្រូវបានផ្តល់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ និងការទាញយកពីប្រព័ន្ធទិន្នន័យអន្តរជាតិរបស់ធនាគារពិភពលោក និងអង្គការអន្តរជាតិខាងការងារ ដែលរួមមាន World Integrated Trade Solution (WITS), World Development Indicators (WDI) និង ILOStat។

**ទម្រង់គំរូរបាយការណ៍** (Reporting Template Format - RTF) គឺជាឧបករណ៍ប្រើប្រាស់ដើម្បីប្រមូលព័ត៌មាន និងពិនិត្យវឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយក្នុងកម្រិតបច្ចេកទេស។ ឧបករណ៍នេះគឺជាតារាងដែលដាក់បញ្ចូលរាល់វិធានការគោលនយោបាយ និងសូចនាករសម្រាប់អនុវត្ត ដែលបានមកពីក្របខណ្ឌតក្កកម្ម។ តារាងនេះប្រើប្រាស់សម្រាប់ប្រមូលទិន្នន័យបែបបរិមាណវិស័យ និងគុណវិស័យដើម្បីវាស់វែងវឌ្ឍនភាព និងលទ្ធផលនៃការអនុវត្តវិធានការគោលនយោបាយនីមួយៗ របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។ សូចនាករគោលចំនួន ៣ ត្រូវបានកំណត់សម្រាប់វិធានការគោលនយោបាយនីមួយៗ ដើម្បីតាមដានវឌ្ឍនភាពនៃការអនុវត្តក្នុងកម្រិតបច្ចេកទេស។ សូចនាករវឌ្ឍនភាពបន្ថែម (API) អាចត្រូវបានកំណត់ដើម្បីប្រមូលទិន្នន័យបែបបរិមាណវិស័យបន្ថែមលើការអនុវត្ត និងលទ្ធផលនៃវិធានការគោលនយោបាយជាក់លាក់ណាមួយ។

ចំពោះការប្រមូលនិងវិភាគទិន្នន័យ ជាការកត់សម្គាល់ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចផ្លាស់ប្តូរឆ្នាំគោលគណនេយ្យជាតិ ពីឆ្នាំ២០០០ មកឆ្នាំ២០១៤ ក្នុងគោលបំណងធ្វើបច្ចុប្បន្នភាព និងវាស់វែងកំណើនសេដ្ឋកិច្ច និងរចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជា ឱ្យកាន់តែមានភាពល្អប្រសើរ និងកាន់តែឆ្លុះបញ្ចាំងតថភាពជាក់ស្តែងក្នុងសង្គម។ ការផ្លាស់ប្តូរឆ្នាំគោលនេះធ្វើឱ្យតួលេខនៃសូចនាករមួយចំនួនក្នុងរបាយការណ៍នេះ ខុសគ្នាទៅនឹងតួលេខក្នុងរបាយការណ៍MTR។

គួរបញ្ជាក់ថា របាយការណ៍នេះប្រើប្រាស់វិធីសាស្ត្រចម្រុះ ដោយរួមបញ្ចូលទាំងវិធីសាស្ត្រ បែបបរិមាណវិស័យ និងគុណវិស័យ។ ចំពោះវិសាលភាព របាយការណ៍វឌ្ឍនភាពនេះផ្តោតសំខាន់លើ**សមិទ្ធកម្មនៃសូចនាករកម្រិតយុទ្ធសាស្ត្រក្នុងឆ្នាំ២០២១ ២០២២ និង២០២៣** ដោយធ្វើការ**តាមដានពីវឌ្ឍនភាពរបស់**

## ២. វិធីសាស្ត្រនៃការតាមដាន

**គោលបំណងគោលនយោបាយនីមួយៗ** ព្រមទាំងសង្ខេបខ្លីអំពីវឌ្ឍនភាពនៃការអនុវត្តវិធានការ បញ្ហាប្រឈម និងហានិភ័យនៃការអនុវត្តគោលនយោបាយ។ យ៉ាងណាមិញ របាយការណ៍នេះពុំបានបញ្ចូលការវិភាគអំពីចក្ខុវិស័យ និងគោលដៅអភិវឌ្ឍន៍ជាតិ ព្រមទាំងផលជះជារួមឡើយ ដែលជាកម្មវត្ថុនៃការវាយតម្លៃចុងអាណត្តិ។ ដោយឡែក លទ្ធផលតាមដានវឌ្ឍនភាពលម្អិតក្នុងកម្រិតវិស័យ (អន្តរាគមន៍គោលនយោបាយ) និងកម្រិតបច្ចេកទេស (ការអនុវត្តវិធានការគោលនយោបាយ) ត្រូវបានបង្ហាញនៅក្នុងផ្នែកបរិសិដ្ឋនៃរបាយការណ៍នេះ។ ការតាមដានវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ IDP ក្នុងរយៈពេល ៣ឆ្នាំនេះ នៅពុំទាន់គ្រប់ជ្រុងជ្រោយនៅឡើយ ព្រោះទិន្នន័យនៃសូចនាករមួយចំនួនតូចពុំមានទិន្នន័យរហូតដល់ឆ្នាំ២០២៣នោះទេ។

**រូបភាពទី១៖ តក្កកម្មអន្តរាគមន៍គោលនយោបាយ IDP**




## ៣. ការតាមដានសមិទ្ធកម្មនៃការអនុវត្តគោលនយោបាយ IDP

ការវិភាគកម្រិតយុទ្ធសាស្ត្រ នឹងផ្តោតលើវឌ្ឍនភាពនៃការសម្រេចបានរបស់គោលបំណងគោល-នយោបាយទាំង៥ ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ ដែលជាឆ្នាំដែលកម្ពុជាប្រឈមនឹងបញ្ហាចម្រូងៗជាបន្តបន្ទាប់ ដែលកើតចេញពីការរីករាលដាលនៃជំងឺកូវីដ-១៩, ភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយ និងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចតំបន់ និងសកល។ បច្ចុប្បន្ន បើទោះបីជាស្ថានភាពសេដ្ឋកិច្ច-សង្គមកម្ពុជាបាន

## ៣. ការតាមដានសមិទ្ធកម្មនៃការអនុវត្តគោលនយោបាយ IDP

និងកំពុងឈានត្រឡប់មករកភាពប្រក្រតីក្រោយវិបត្តិជំងឺកូវីដ-១៩ក្តី ប៉ុន្តែផលជះដ៏យូរអង្វែងនៃវិបត្តិជំងឺកូវីដ-១៩ រួមជាមួយនឹងសម្ពាធពីវិបត្តិខាងក្រៅ បានជះឥទ្ធិពលដល់វឌ្ឍនភាពនៃការសម្រេចបាននូវគោល-បំណងគោលនយោបាយនីមួយៗ។ ហេតុនេះ ការវិភាគពីវឌ្ឍនភាពក្នុងគោលបំណងនីមួយៗនឹងរំលេចនូវវិបត្តិចម្បងៗទាំងនេះ ដូចខាងក្រោម៖

### ៣.១ សមិទ្ធកម្មគោលបំណងទី១ "បង្កើនសកម្មភាពឧស្សាហកម្ម"

រូបភាពទី២៖ តម្លៃបន្ថែមសរុបនៃវិស័យឧស្សាហកម្មសម្រាប់មនុស្សម្នាក់




ប្រភពទិន្នន័យ៖ ការគណនារបស់លេខាធិការដ្ឋាន IDP ផ្អែកលើទិន្នន័យក្រសួងផែនការ

ការបង្កើនសកម្មភាពឧស្សាហកម្ម ជាពិសេសការបង្កើនមូលដ្ឋានឧស្សាហកម្ម អាចជួយបង្កើនតួនាទីនៃវិស័យនេះក្នុងខឿនសេដ្ឋកិច្ច និងជំរុញដល់ការកែប្រែរចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជា។ យោងតាមរបាយការណ៍ MTR គោលបំណងទី១ "បង្កើនសកម្មភាពឧស្សាហកម្ម" ត្រូវបានវាយតម្លៃថា "**សម្រេចបានដោយផ្នែក**"។ លទ្ធផលនេះត្រូវបានវាយតម្លៃដោយផ្អែកលើសូចនាករចំនួន២ ដែលត្រូវបានប្រើប្រាស់ដើម្បីវាស់វែងពីកម្រិតនៃឧស្សា-ហូបនីយកម្ម គឺ (១) តម្លៃបន្ថែមសរុបនៃវិស័យឧស្សាហកម្មសម្រាប់មនុស្សម្នាក់ និង (២) តម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាលសម្រាប់មនុស្សម្នាក់។

គួរកត់សម្គាល់ផងដែរថា ក្នុងឆ្នាំ២០២០ ការរីករាលដាលនៃជំងឺកូវីដ-១៩ បានជះផលអវិជ្ជមានមកលើវិស័យឧស្សាហកម្មនៅកម្ពុជា ដោយមានការកាត់បន្ថយការធ្វើដំណើរ ការថមថយនៃតម្រូវការសកល និងការរឹតបន្តឹងសកម្មភាពដឹកជញ្ជូនទំនិញឆ្លងកាត់ព្រំដែន ដែលនាំឱ្យមានការរាំងស្ទះដល់ដំណើរការនៃការផ្គត់ផ្គង់ធាតុចូលផលិតកម្មដល់ឧស្សាហកម្មក្នុងស្រុក និងការនាំចេញទំនិញទៅក្រៅប្រទេសផងដែរ។ ការណ៍នេះ បានរុញច្រានសកម្មភាពផលិតកម្មក្នុងវិស័យនេះ ឱ្យឈានទៅរកការផ្អាក ឬបង្អាក់សកម្មភាព និងការពន្យារពេលនៃការបណ្តាក់ទុន លើគម្រោងវិនិយោគក្នុងចង្កោមឧស្សាហកម្មថ្មីៗពីសំណាក់វិនិយោគិន។ ទោះជាយ៉ាងណា ការងើបឡើងវិញនូវតម្រូវការសកល និងការបើកប្រទេសឡើងវិញនៅចុងឆ្នាំ២០២១ បានធ្វើឱ្យសកម្មភាពផលិតកម្មនៅកម្ពុជាមានសញ្ញាណនៃការងើបឡើងវិញជាបណ្តើរៗ។ ទន្ទឹមនេះ ទោះបីជាវិស័យ

ឧស្សាហកម្មកម្ពុជាប្រឈមនឹងការថមថយនៃកំណើនសេដ្ឋកិច្ចសកល និងភាពមិនប្រាកដប្រជានៃស្ថានភាពសេដ្ឋកិច្ចនយោបាយសកលមួយចំនួនក៏ដោយ វិស័យនេះនៅតែបន្តទទួលបានកំណើនវិជ្ជមានក្នុងឆ្នាំ២០២៣។

តម្លៃបន្ថែមសរុបនៃវិស័យឧស្សាហកម្មសម្រាប់មនុស្សម្នាក់ (រូបភាពទី២) បានកើនឡើងជាបន្តបន្ទាប់ពីប្រមាណ ៧៨០ដុល្លារអាមេរិក នៅឆ្នាំ២០២១ ដល់ប្រមាណ ៨៥៦ដុល្លារអាមេរិក នៅឆ្នាំ២០២៣ ដោយមានអត្រាកំណើនមធ្យម (CAGR) នៅចន្លោះឆ្នាំ២០២០ និង២០២៣ ក្នុងរង្វង់ ៥,៣% ក្នុងមួយឆ្នាំ ខណៈដែលតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាលសម្រាប់មនុស្សម្នាក់ (រូបភាពទី៣) បានកើនឡើងពីប្រមាណ ៥៣៣ ដុល្លារអាមេរិក នៅឆ្នាំ២០២១ ដល់ប្រមាណ ៥៩១ដុល្លារអាមេរិក នៅឆ្នាំ២០២៣ ជាមួយនឹងអត្រាកំណើនជាមធ្យមនៅចន្លោះឆ្នាំ២០២០ និង២០២៣ ក្នុងរង្វង់ ៧,៧% ក្នុងមួយឆ្នាំ។

រូបភាពទី៣៖ តម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាលសម្រាប់មនុស្សម្នាក់




ប្រភពទិន្នន័យ៖ ការគណនារបស់លេខាធិការដ្ឋាន IDP ផ្អែកលើទិន្នន័យក្រសួងផែនការ

និន្នាការនេះ បានបង្ហាញថាវិស័យឧស្សាហកម្ម ក៏ដូចជាអនុវិស័យកម្មន្តសាលមានវឌ្ឍនភាពល្អប្រសើរជារួម ហើយជាវិស័យដែលកំពុងងើបឡើងវិញយ៉ាងឆាប់រហ័ស បន្ទាប់ពីទទួលរងនូវផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ និងផលជះពីវិបត្តិផ្សេងៗ។ ជាមួយគ្នានេះដែរ កំណើនជាមធ្យមប្រចាំឆ្នាំនៅចន្លោះឆ្នាំ ២០២០ និង២០២៣ សម្រាប់វិស័យឧស្សាហកម្មទាំងមូល (៥,៣%) មានសន្ទុះយឺតជាងកំណើនក្នុងអនុវិស័យកម្មន្តសាល (៧,៧%) ដែលករណីនេះ បណ្តាលមកពីការកើនឡើងនៃតម្លៃបន្ថែមរបស់វិស័យកម្មន្តសាលផង និងការថមថយនៃតម្លៃបន្ថែមរបស់អនុវិស័យសំណង់ ក្នុងរយៈពេល៣ឆ្នាំចុងក្រោយ បើធៀបនឹងឆ្នាំ២០២០ ដោយសារអនុវិស័យនេះរងផលជះអវិជ្ជមានជាខ្លាំងពីវិបត្តិជំងឺកូវីដ-១៩ និងវិបត្តិផ្សេងៗ។ គួរបញ្ជាក់ផងដែរថា អនុវិស័យសំណង់ជាធាតុផ្សំធំជាងគេទី២ ក្នុងឧស្សាហកម្ម បន្ទាប់ពីអនុវិស័យកម្មន្តសាល។ ករណីនេះបង្ហាញពីតួនាទីរបស់អនុវិស័យកម្មន្តសាល ជាកម្លាំងចលករដ៏សំខាន់ក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម ដែលស្របតាមការរំពឹងទុករបស់គោលនយោបាយ IDP។

គោលបំណងគោលនយោបាយទី១ មានអន្តរាគមន៍គោលនយោបាយចំនួន៤ រួមមាន៖ (១) បង្កើនតម្រូវការក្នុងស្រុក និងការជំនួសផលិតផលនាំចូល (២) បង្កើនការវិនិយោគក្នុងវិស័យឧស្សាហកម្ម (៣) បង្កើនផលិតភាពការងាររបស់សហគ្រាស និង (៤) បង្កើនកម្រិតបច្ចេកវិទ្យារបស់សហគ្រាស។ សមិទ្ធកម្មនៃអន្តរាគមន៍គោលនយោបាយទាំង៤ នេះ មានបង្ហាញលម្អិតក្នុងបរិសិដ្ឋទី១។

គោលបំណងគោលនយោបាយនេះ មានវិធានការសរុបចំនួន ២០ ក្នុងនោះវិធានការសម្រេចពេញ-លេញ មានចំនួន ១៤, កំពុងអនុវត្តមានចំនួន ៤, និង យឺតយ៉ាវមានចំនួន ២ ដូចមានបង្ហាញក្នុងបរិសិដ្ឋទី២។

## ៣.២. សមិទ្ធកម្មគោលបំណងទី២ "បង្កើនការនាំចេញទំនិញឧស្សាហកម្ម និងកសិ-ឧស្សាហកម្ម"

ការបង្កើនការនាំចេញទំនិញឧស្សាហកម្ម និងកសិ-ឧស្សាហកម្ម គឺជាកត្តាសំខាន់មួយ ក្នុងការជំរុញកំណើនសកម្មភាពឧស្សាហកម្មក្នុងស្រុក ដែលនឹងចូលរួមចំណែកយ៉ាងសំខាន់ក្នុងកិច្ចដំណើរការឧស្សា-ហូបនីយកម្ម។ យោងតាមលទ្ធផលនៃរបាយការណ៍ MTR គោលបំណងទី២នេះ ត្រូវបានវាយតម្លៃថា **"សម្រេចបានភាគច្រើន"** ដោយសារការនាំចេញផលិតផលកម្មន្តសាលសម្រាប់មនុស្សម្នាក់បានកើនឡើងជាបន្តបន្ទាប់ ដល់ឆ្នាំ២០១៩។ លទ្ធផលនេះត្រូវបានវាយតម្លៃដោយផ្អែកលើសូចនាករចំនួន ២ ដែលវាស់វែងពីសមត្ថភាពនាំចេញរបស់វិស័យឧស្សាហកម្មកម្ពុជា ក្នុងនោះរួមមាន៖ (១) ការនាំចេញផលិតផលកម្មន្តសាលសម្រាប់មនុស្សម្នាក់ និង (២) ចំណែកនៃការនាំចេញកសិផលកែច្នៃក្នុងការនាំចេញសរុប។

យ៉ាងណាមិញ ការរីករាលដាលនៃជំងឺកូវីដ-១៩ បានធ្វើឱ្យមានការធ្លាក់ចុះយ៉ាងគំហុកនូវតម្រូវការពីទីផ្សារខាងក្រៅ ជាពិសេសនៅតាមទីផ្សារនាំចេញសំខាន់ៗរបស់កម្ពុជា ដែលជាហេតុធ្វើឱ្យការនាំចេញមានការធ្លាក់ចុះ ក្នុងឆ្នាំ២០២០ លើកលែងតែការនាំចេញកសិផលកែច្នៃប៉ុណ្ណោះដែលទទួលរងផលប៉ះពាល់អវិជ្ជមានតិចជាងគេពីវិបត្តិនេះ។ ដោយឡែក ការធូរស្រាលពីផលប៉ះពាល់នៃវិបត្តិនេះនៅចុងឆ្នាំ២០២១ ភាពប្រសើរឡើងនៃតម្រូវការសកល និងការបន្ធូរបន្ថយការរឹតត្បិតផ្សេងៗពីបណ្តាប្រទេសជាច្រើន រួមទាំងកម្ពុជាផងដែរ បានធ្វើឱ្យការនាំចេញផលិតផលឧស្សាហកម្ម និងកសិ-ឧស្សាហកម្មមានការងើបឡើងវិញជាបន្តបន្ទាប់។

រូបភាពទី៤៖ ការនាំចេញផលិតផលកម្មន្តសាល សម្រាប់មនុស្សម្នាក់




ប្រភពទិន្នន័យ៖ ការគណនារបស់លេខាធិការដ្ឋាន IDP ផ្អែកលើទិន្នន័យ WITS និងក្រសួងផែនការ

## ៣. ការតាមដានសមិទ្ធកម្មនៃការអនុវត្តគោលនយោបាយ IDP

រូបភាពទី៤ បង្ហាញថាការនាំចេញផលិតផលកម្មន្តសាលសម្រាប់មនុស្សម្នាក់បានកើនឡើងពីប្រមាណ ៩៧៧ដុល្លារអាម៉េរិក នៅឆ្នាំ២០២១ ដល់ប្រមាណ ១.១៣០ដុល្លារអាម៉េរិក នៅឆ្នាំ២០២២ ប៉ុន្តែបានធ្លាក់ចុះបន្តិចវិញដល់ប្រមាណ ១.០៨៦ដុល្លារអាម៉េរិក នៅឆ្នាំ២០២៣។ ការធ្លាក់ចុះនៃការនាំចេញផលិតផលកម្មន្តសាលសម្រាប់មនុស្សម្នាក់ក្នុងឆ្នាំ២០២៣ បណ្ដាលមកពីការធ្លាក់ចុះនៃទំហំការនាំចេញផលិតផលសម្លៀកបំពាក់ ស្បែកជើង និងកាបូប ដោយសារការថមថយនៃតម្រូវការសកល។ ទោះជាយ៉ាងណា តួលេខក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះសុទ្ធតែស្ថិតក្នុងកម្រិតមួយខ្ពស់ជាងតួលេខមុនវិបត្តិជំងឺកូវីដ-១៩។ ជាមួយគ្នានេះ អត្រាកំណើនមធ្យមនៅចន្លោះឆ្នាំ២០២០ និង២០២៣ គឺក្នុងរង្វង់ ១០% ក្នុងមួយឆ្នាំ ដែលការណ៍នេះបង្ហាញពីសញ្ញាណនៃការងើបឡើងវិញជាវិជ្ជមាន នៃការនាំចេញក្នុងរយៈពេលបីឆ្នាំចុងក្រោយ បន្ទាប់ពីរងនូវផលប៉ះពាល់ពីវិបត្តិកូវីដ-១៩។

រូបភាពទី៥៖ ចំណែកនៃការនាំចេញកសិផលកែច្នៃក្នុងការនាំចេញសរុប




ប្រភពទិន្នន័យ៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

រូបភាពទី៥ បានបង្ហាញថា ទំហំនាំចេញកសិផលកែច្នៃនៅចន្លោះឆ្នាំ២០២០ និង២០២៣ បានបន្តកើនឡើងក្នុងអត្រាកំណើនមធ្យមប្រចាំឆ្នាំក្នុងរង្វង់ ១២,១% ក្នុងមួយឆ្នាំ ដែលបានកើនដល់ប្រមាណ ១.១៩១លានដុល្លារអាម៉េរិក នៅឆ្នាំ២០២៣។ យ៉ាងណាមិញ តួលេខនៃចំណែកការនាំចេញកសិផលកែច្នៃក្នុងការនាំចេញសរុប ក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយនេះ មាននិន្នាការប្រែប្រួល ដោយបានធ្លាក់ចុះពី ៥,៤% នៅឆ្នាំ២០២១ មកត្រឹម ៤,៧% នៅឆ្នាំ២០២២ ប៉ុន្តែបានងើបឡើងវិញដល់ ៥,១% នៅឆ្នាំ២០២៣។ ការណ៍នេះបង្ហាញថា ខណៈដែលទំហំនៃការនាំចេញកសិផលកែច្នៃបានកើនឡើងជាបន្តបន្ទាប់ ការនាំចេញរបស់អនុវិស័យដទៃទៀត ហាក់មានការកើនឡើងធំជាងអនុវិស័យនេះទៅទៀត។

គោលបំណងគោលនយោបាយទី២ មានអន្តរាគមន៍គោលនយោបាយចំនួន២ រួមមាន៖ (១) បង្កើនសមត្ថភាពនាំចេញរបស់ក្រុមហ៊ុន/សហគ្រាសធុនតូចនិងមធ្យមក្នុងស្រុក និង (២) ធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងការតភ្ជាប់។ សមិទ្ធកម្មនៃអន្តរាគមន៍គោលនយោបាយទាំង២ មានបង្ហាញលម្អិតក្នុងបរិសិដ្ឋទី១។

គោលបំណងគោលនយោបាយនេះ មានវិធានការសរុបចំនួន ២៨ ក្នុងនោះវិធានការសម្រេចពេញលេញ មានចំនួន ១៦, កំពុងអនុវត្តមានចំនួន ៧, និង យឺតយ៉ាវមានចំនួន ៥ ដូចមានបង្ហាញក្នុងបរិសិដ្ឋទី២។

## ៣.៣. សមិទ្ធកម្មគោលបំណងទី៣ "សេដ្ឋកិច្ចដែលមានភាពធន់ និងមានពិពិធកម្ម"

ការធ្វើពិពិធកម្មសេដ្ឋកិច្ច ត្រូវបានចាត់បញ្ចូលជាយុទ្ធសាស្ត្រដ៏សំខាន់មួយ ក្នុងការជំរុញកិច្ចអភិវឌ្ឍ និងពង្រឹងភាពធន់នៃសេដ្ឋកិច្ចប្រកបដោយចីរភាព។ វិបត្តិជំងឺកូវីដ-១៩, ភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយ និងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចកាន់តែគូសបញ្ជាក់អំពីតម្រូវការចាំបាច់ និងបន្ទាន់ក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ច ដើម្បីកាត់បន្ថយភាពងាយរងគ្រោះដែលបង្កដោយវិបត្តិពីខាងក្រៅ និងធានាបាននូវការងើបឡើងវិញយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ច ក្រោយវិបត្តិ។

ជាក់ស្តែង នៅពេលដែលជំងឺកូវីដ-១៩បានរីករាលដាលខ្លាំងជុំវិញពិភពលោក វិស័យមួយចំនួនរបស់កម្ពុជា ដែលពឹងផ្អែកខ្លាំងលើតម្រូវការសកល និងងាយរងគ្រោះពីវិបត្តិ ដូចជា អនុវិស័យកាត់ដេរជាដើម បានរងផលប៉ះពាល់អវិជ្ជមាន ដោយនៅពេលនោះមានការកើនឡើងនៃចំនួនរោងចក្រ ដែលបានផ្អាកដំណើរការផលិតកម្មបណ្តោះអាសន្ន ឬបិទជាស្ថាពរ ព្រោះកំណើនសេដ្ឋកិច្ចសកល និងតម្រូវការខាងក្រៅមានការថមថយ។ ការធ្វើពិពិធកម្មទៅរកសកម្មភាពផ្សេងទៀត ជាពិសេសអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរដែលមានកំណើនល្អប្រសើរទោះបីប្រឈមមុខនឹងវិបត្តិជំងឺកូវីដ-១៩ បូករួមនឹងការចរចាបើកទីផ្សារជាមួយដៃគូពាណិជ្ជកម្មនានា អាចជួយឱ្យកម្ពុជាឆ្លងផុតពេលវេលាដ៏លំបាកនេះ និងអាចមានលទ្ធភាពស្តារសេដ្ឋកិច្ចរបស់ខ្លួនបានយ៉ាងឆាប់រហ័ស។

យោងតាមលទ្ធផលនៃរបាយការណ៍ MTR សមិទ្ធកម្មនៃគោលបំណងទី៣នេះ ត្រូវបានវាយតម្លៃថា "**សម្រេចបានដោយផ្នែក**"។ លទ្ធផលនេះត្រូវបានវាយតម្លៃដោយផ្អែកលើសូចនាករចំនួន ២ គឺ (១) ចំណែកតម្លៃបន្ថែមនៃអនុវិស័យកម្មន្តសាល ៣ នាំមុខគេ ធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល ដែលវាស់វែងពីភាពប្រមូលផ្តុំនៃតម្លៃបន្ថែមក្នុងវិស័យកម្មន្តសាល និង (២) ចំណែកនៃការនាំចេញផលិតផលកម្មន្តសាលមិនមែនសម្លៀកបំពាក់ និងស្បែកជើងធៀបនឹងការនាំចេញសរុប ដែលវាស់វែងពីការធ្វើពិពិធកម្មមុខទំនិញនាំចេញ។

## ៣. ការតាមដានសមិទ្ធកម្មនៃការអនុវត្តគោលនយោបាយ IDP

រូបភាពទី៦៖ ចំណែកតម្លៃបន្ថែមនៃអនុវិស័យកម្មន្តសាល ៣ នាំមុខគេធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល (%)




ប្រភពទិន្នន័យ៖ ការគណនារបស់លេខាធិការដ្ឋាន IDP ផ្អែកលើទិន្នន័យក្រសួងផែនការ

សម្គាល់៖ តម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាលរាប់បញ្ចូល អនុវិស័យម្ហូបអាហារ, ភេសជ្ជៈនិងថ្នាំជក់, វាយនភណ្ឌ សម្លៀក-បំពាក់ ស្បែកជើង និងផលិតផលធ្វើអំពីស្បែក, ឈើ ក្រដាស និងបោះពុម្ព, កៅស៊ូ, ផលិតផលមិនមែនលោហធាតុ, ផលិតផលលោហធាតុ និងគ្រឿងសង្ហារិម។

ផ្អែកតាមការវាយតម្លៃបែបបរិមាណវិស័យ ចំណែកតម្លៃបន្ថែមនៃអនុវិស័យកម្មន្តសាល ៣ នាំមុខគេធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល (រូបភាពទី៦) ក្នុងរយៈពេល ៣ ឆ្នាំ ចុងក្រោយនេះមាននិន្នាការប្រែប្រួល ដោយបានកើនឡើងបន្តិចបន្តួចពី ៧៦,៨% នៅឆ្នាំ២០២១ ដល់ ៧៧,២% នៅឆ្នាំ២០២២ ប៉ុន្តែបានធ្លាក់ចុះវិញត្រឹម ៧៤,៩% នៅឆ្នាំ២០២៣។ តួលេខក្នុងរយៈពេល ៣ឆ្នាំចុងក្រោយនេះ សុទ្ធតែស្ថិតក្នុងកម្រិតមួយទាបជាងឆ្នាំ២០១៩ ដែលបង្ហាញថាការប្រមូលផ្តុំនៃតម្លៃបន្ថែមក្នុងវិស័យកម្មន្តសាលត្រូវបានកាត់បន្ថយតិចជាងមុន។

ជារួម តួលេខជាមធ្យមពីឆ្នាំ២០១៥ ដល់២០២៣ នៃសូចនាករនេះ នៅតែស្ថិតក្នុងកម្រិតមួយខ្ពស់ក្នុងរង្វង់ ៧៧% ក្នុងមួយឆ្នាំ។ សញ្ញានេះរំលេចឱ្យឃើញថា វិស័យកម្មន្តសាលរបស់កម្ពុជា នៅតែប្រមូលផ្តុំជុំវិញសកម្មភាពមួយចំនួនតូចប៉ុណ្ណោះ ដោយមូលដ្ឋានផលិតកម្មនៅតែមិនទាន់មានពិពិធកម្មគួរឱ្យកត់សម្គាល់នៅឡើយ។

## ៣. ការតាមដានសមិទ្ធកម្មនៃការអនុវត្តគោលនយោបាយ IDP

រូបភាពទី៧៖ ចំណែកនៃការនាំចេញផលិតផលកម្មន្តសាលមិនមែនសម្លៀកបំពាក់ និងផលិតផលស្បែកជើង ធៀបនឹងការនាំចេញសរុប (%)




ប្រភពទិន្នន័យ៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

រូបភាពទី៧ បង្ហាញថា ទោះបីរងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ក្តី ចំណែកនៃការនាំចេញផលិតផលកម្មន្តសាលមិនមែនសម្លៀកបំពាក់ និងស្បែកជើង ធៀបនឹងការនាំចេញសរុប បានបន្តកើនឡើងពី ១៥,៥% ក្នុងឆ្នាំ២០២០ ដល់ ២១,២% ក្នុងឆ្នាំ២០២១។ ដោយឡែក ទិន្នន័យនៃសូចនាករនេះបានធ្លាក់ចុះមកត្រឹម ១៨,៦% នៅឆ្នាំ២០២២ ដោយសារការកើនឡើងនូវទំហំនៃការនាំចេញផលិតផលសម្លៀកបំពាក់ និងស្បែកជើង និងផលិតផលមិនមែនកម្មន្តសាលផ្សេងទៀត ប៉ុន្តែចំណែកនៃការនាំចេញផលិតផលកម្មន្តសាលមិនមែនសម្លៀកបំពាក់ និងស្បែកជើងនេះ បានកើនឡើងវិញដល់ ២០,៦% ក្នុងឆ្នាំ២០២៣។

ជារួម ចំណែកនៃការនាំចេញផលិតផលកម្មន្តសាលមិនមែនសម្លៀកបំពាក់ និងស្បែកជើង ធៀបនឹងការនាំចេញសរុប ក្នុងរយៈពេល ៣ឆ្នាំចុងក្រោយនេះ សុទ្ធតែស្ថិតនៅក្នុងកម្រិតមួយខ្ពស់ជាងមុនការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលបង្ហាញពីវឌ្ឍនភាពវិជ្ជមាននៃពិពិធកម្មមុខទំនិញនាំចេញ។

គោលបំណងគោលនយោបាយទី៣ មានអន្តរាគមន៍គោលនយោបាយចំនួន៥ រួមមាន៖ (១) បង្កើនសកម្មភាពឧស្សាហកម្មថ្មីៗ (២) ពង្រីក និងធ្វើពិពិធកម្មទីផ្សារ និងផលិតផលនាំចេញ (៣) ធ្វើឱ្យមានតុល្យភាពរវាងសហគ្រាសធុនធំ និងសហគ្រាសធុនតូច និងមធ្យម (៤) បង្កើននវានុវត្តន៍ផ្នែកឧស្សាហកម្ម និង (៥) ធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម។ សមិទ្ធកម្មនៃអន្តរាគមន៍គោលនយោបាយទាំង៥ នេះ មានបង្ហាញលម្អិតក្នុងបរិសិដ្ឋទី១។

គោលបំណងគោលនយោបាយនេះ មានវិធានការសរុបចំនួន ៤៣ ក្នុងនោះវិធានការសម្រេចពេញលេញមានចំនួន ២៦, កំពុងអនុវត្តមានចំនួន ១១, និង យឺតយ៉ាវមានចំនួន ៦ ដូចមានបង្ហាញក្នុងបរិសិដ្ឋទី២។

## ៣.៨. សមិទ្ធកម្មគោលបំណងទី៨ "ធ្វើឱ្យប្រសើរឡើងនូវគុណភាពការងារ"

កម្មករ-និយោជិត គឺជាសសរស្តម្ភដ៏សំខាន់នៃកត្តាផលិតកម្មក្នុងវិស័យឧស្សាហកម្មកម្ពុជា។ ការធ្វើឱ្យប្រសើរឡើងនូវគុណភាពការងារ អាចជួយពន្លឿនឱ្យកម្ពុជាសម្រេចបាននូវចក្ខុវិស័យនៃគោលនយោបាយ IDP "ជំរុញកែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មនៅកម្ពុជាពីឧស្សាហកម្មអតិពលកម្ម ឈានទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹមឆ្នាំ២០២៥" ព្រោះការងារដែលមានគុណភាពខ្ពស់ នឹងផ្តល់ឱកាសកាន់តែច្រើនដល់កម្មករ-និយោជិតក្នុងការបង្កើនកម្រិតជំនាញនិងកម្រិតចំណូល ដែលនឹងរួមចំណែកដល់ការបង្កើនផលិតភាពការងារ, កំណើនសេដ្ឋកិច្ច ព្រមទាំងបង្កើនសមភាព និងសិនិទ្ធភាពសង្គមផងដែរ។

យោងតាមលទ្ធផលនៃរបាយការណ៍ MTR គោលបំណងទី៨នេះត្រូវបានវាយតម្លៃថា "**សម្រេចបានច្រើន**" ដោយសារការកើនឡើងនៃចំនួនការងារក្នុងវិស័យឧស្សាហកម្ម និងវិស័យកម្មន្តសាលមិនមែនកាត់ដេរ។ លទ្ធផលនេះត្រូវបានវាយតម្លៃដោយផ្អែកលើសូចនាករចំនួន ២ គឺ (១) ចំនួនការងារនៅក្នុងវិស័យកម្មន្តសាលមិនមែនកាត់ដេរ និង (២) ចំណែកការងារក្នុងវិស័យឧស្សាហកម្ម ធៀបនឹងចំនួនការងារសរុប។ សូចនាករទាំង២នេះ សុទ្ធតែវាស់វែងពីវឌ្ឍនភាពនៃការបង្កើតការងារក្នុងវិស័យឧស្សាហកម្ម និងកម្មន្តសាលមិនមែនកាត់ដេរ ដោយវិស័យឧស្សាហកម្មជារួម ត្រូវបានចាត់ទុកថាជាវិស័យដែលផ្តល់នូវលក្ខខណ្ឌការងារល្អ ហើយការកើនឡើងនូវចំនួនការងារក្នុងវិស័យនេះ អាចជាមូលដ្ឋានក្នុងការធ្វើឱ្យគុណភាពការងារនៅកម្ពុជាកាន់តែមានភាពប្រសើរឡើង។

ក្នុងបរិបទនៃវិបត្តិជំងឺកូវីដ-១៩ ការលើកកម្ពស់គុណភាពការងារ ដែលពាក់ព័ន្ធនឹងសុវត្ថិភាពការងារ រួមមានការផ្សព្វផ្សាយពីវិធានការការពារដើម្បីកាត់បន្ថយការរីករាលដាលនៃជំងឺកូវីដ-១៩ របស់ក្រុមហ៊ុន សហគ្រាស និងរាជរដ្ឋាភិបាល, ការចាក់វ៉ាក់សាំងឱ្យបានគ្រប់ចំនួនដូស និងការព្យាបាលទាន់ពេលវេលាបានជួយកាត់-បន្ថយហានិភ័យលើសុខភាពរបស់កម្មករ-និយោជិត និងបានធ្វើឱ្យក្រុមហ៊ុន សហគ្រាសមួយចំនួនអាចបន្តដំណើរការផលិតកម្មរបស់ខ្លួន។ ទោះជាយ៉ាងនេះក្តី ការផ្អាក ឬបង្អាក់ផលិតកម្ម ដែលបង្កឡើងដោយការកាត់បន្ថយការបញ្ជាទិញពីទីផ្សារក្រៅប្រទេស នៅតែកើតមាន និងបានជះផលអវិជ្ជមានមកលើវិស័យការងារក្នុងសកម្មភាពឧស្សាហកម្មមួយចំនួន។ បន្ទាប់ពីការថមថយនៃការរីករាលដាលជំងឺកូវីដ-១៩ ដែលឈានដល់ការបើកប្រទេសឡើងវិញ និងការកើនឡើងនៃតម្រូវការសកល សកម្មភាពក្នុងវិស័យឧស្សាហកម្ម និងកម្មន្តសាលមានការងើបឡើងវិញជាបណ្តើរៗ ដូចបានបង្ហាញក្នុងគោលបំណងគោលនយោបាយទី១ នៃរបាយការណ៍នេះ ដែលការណ៍នេះក៏បានជះផលវិជ្ជមានដល់វិស័យការងារផងដែរ។

## ៣. ការតាមដានសមិទ្ធកម្មនៃការអនុវត្តគោលនយោបាយ IDP

រូបភាពទី៨៖ ចំនួនការងារក្នុងវិស័យកម្មន្តសាលមិនមែនកាត់ដេរ




ប្រភពទិន្នន័យ៖ ការប៉ាន់ស្មានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយផ្អែកលើទិន្នន័យរបស់អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០១៥ ដល់ ឆ្នាំ២០២១

កំណត់សម្គាល់៖ សម្រាប់អង្កេតឆ្នាំ២០១៨ មិនមានការធ្វើអង្កេត និងសម្រាប់ឆ្នាំ២០២០ ការប្រមូលទិន្នន័យធ្វើឡើងក្នុងឆមាសទី២ ឆ្នាំ២០១៩ និងឆមាសទី១ ឆ្នាំ២០២០

រូបភាពទី៨ បង្ហាញពីនិន្នាការល្អប្រសើរនៃការបង្កើតការងារក្នុងវិស័យកម្មន្តសាលមិនមែនកាត់ដេរ ដែលទោះបីជាប្រឈមមុខនឹងវិបត្តិជំងឺកូវីដ-១៩, ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល និងបញ្ហាប្រឈមដទៃទៀតក្តី ចំនួនការងារក្នុងវិស័យកម្មន្តសាលមិនមែនកាត់ដេរ បានកើនឡើងជាបន្តបន្ទាប់ ដោយបានកើនឡើងពីប្រមាណ ៤៨៧ពាន់នាក់ នៅឆ្នាំ២០២០ ដល់ប្រមាណ ៥១៦ពាន់នាក់ ក្នុងឆ្នាំ២០២១។ ជាមួយគ្នានេះ ចំនួនការងារក្នុងវិស័យឧស្សាហកម្ម (រូបភាពទី៩) បានកើនឡើងពីប្រមាណ ២,៣លាននាក់ នៅឆ្នាំ២០២០ ដល់ប្រមាណ ២,៥លាននាក់ ក្នុងឆ្នាំ២០២១ ខណៈចំណែកការងារក្នុងវិស័យឧស្សាហកម្មធៀបនឹងចំនួនការងារសរុបក៏បានកើនឡើងពី ២៤,៧% ទៅ ២៦,៤% ក្នុងឆ្នាំដូចគ្នា។ ការណ៍នេះបានបង្ហាញពីការងើបឡើងវិញនៃវិស័យឧស្សាហកម្មជារួម ដែលបានស្រូបទាញនូវកម្លាំងពលកម្មចូលទៅក្នុងវិស័យនេះបានច្រើនជាងមុន។

ដោយឡែក នៅឆ្នាំ២០២២ និងឆ្នាំ២០២៣ សមិទ្ធកម្មនៃគោលបំណងទី៤នេះ ពុំមានលទ្ធផលសម្រាប់រាយការណ៍ទេ ព្រោះពុំទាន់មានទិន្នន័យនៅឡើយ។

## ៣. ការតាមដានសមិទ្ធកម្មនៃការអនុវត្តគោលនយោបាយ IDP



រូបភាពទី៩៖ ចំណែកការងារក្នុងវិស័យឧស្សាហកម្មធៀបនឹងចំនួនការងារសរុប




ប្រភពទិន្នន័យ៖ ការប៉ាន់ស្មានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយផ្អែកលើទិន្នន័យរបស់អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០១៥ ដល់ ឆ្នាំ២០២១

សម្គាល់៖ សម្រាប់អង្កេតឆ្នាំ២០១៨ មិនមានការធ្វើអង្កេត និងសម្រាប់ឆ្នាំ២០២០ ការប្រមូលទិន្នន័យធ្វើឡើងក្នុងឆមាសទី២ ឆ្នាំ២០១៩ និងឆមាសទី១ ឆ្នាំ២០២០

គោលបំណងគោលនយោបាយទី៤ មានអន្តរាគមន៍គោលនយោបាយចំនួន៥ រួមមាន៖ (១) ធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍជំនាញ និងធនធានមនុស្ស (២) បង្កើនតម្រូវការពលកម្មជំនាញ (៣) ធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ (៤) លើកកម្ពស់ការផ្គូផ្គងការងារ និង (៥) ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ។ សមិទ្ធកម្មនៃអន្តរាគមន៍គោលនយោបាយទាំង៥ នេះ មានបង្ហាញលម្អិតក្នុងបរិសិដ្ឋទី១។

គោលបំណងគោលនយោបាយនេះ មានវិធានការសរុបចំនួន ៣២ ក្នុងនោះវិធានការសម្រេចពេញលេញមានចំនួន ៣០, កំពុងអនុវត្តមានចំនួន ១, និង យឺតយ៉ាវមានចំនួន ១ ដូចមានបង្ហាញក្នុងបរិសិដ្ឋទី២។

## ៣.៥. សមិទ្ធកម្មគោលបំណងទី៥ "បង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមា"

ការបង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមា នឹងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការសម្រេចបាននូវកំណើនប្រកបដោយចីរភាព ដែលគោលបំណងទី៥នេះ អាចសម្រេចបានតាមរយៈការពង្រឹងការតភ្ជាប់រវាងសហគ្រាសបរទេស និងសហគ្រាសក្នុងស្រុក (រួមទាំងការផ្ទេរបច្ចេកវិទ្យា), ការពង្រឹងខ្សែច្រវាក់តម្លៃក្នុងស្រុក និងការបង្កើនភាពជាម្ចាស់របស់សហគ្រាសក្នុងស្រុក។

គោលបំណងនេះ មានសារៈសំខាន់កាន់តែខ្លាំង ជាពិសេសក្នុងការកាត់បន្ថយផលប៉ះពាល់រយៈពេលវែង ដែលបង្កឡើងដោយវិបត្តិផ្សេងៗ។ ជាក់ស្តែង កាលពីឆ្នាំ២០២១ វិបត្តិជំងឺកូវីដ-១៩ បានជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងដល់វិស័យកម្មន្តសាល ដែលបណ្តាលឱ្យមានផលរំខានដល់ខ្សែច្រវាក់ផ្គត់ផ្គង់តំបន់ និងសកល។ ទន្ទឹមនេះ ខណៈដែលឥទ្ធិពលនៃផលរំខានពីវិបត្តិនេះ បានថមថយនៅឆ្នាំ២០២២ បញ្ហាប្រឈមថ្មីដទៃទៀត ដែលបង្កដោយវិបត្តិសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងវិបត្តិផ្សេងៗទៀត ក៏បានបន្តលេចឡើង ដែលនាំឱ្យមានផលរំខានក្នុងការផ្គត់ផ្គង់ផលិតកម្ម ការកើនឡើងនៃថ្លៃថាមពល ការចំណាយលើការដឹកជញ្ជូន និងឡូជីស្ទីកខ្ពស់ជាងមុន ក៏ដូចជាការកើនឡើងនូវភាពតានតឹងផ្នែកហិរញ្ញវត្ថុជាដើម។ ក្នុងន័យនេះ ការពង្រឹងខ្សែច្រវាក់តម្លៃក្នុងស្រុក និងការបង្កើនសមត្ថភាពផលិតក្នុងស្រុក ដើម្បីជំរុញការផ្គត់ផ្គង់ធាតុចូលផលិតកម្មដល់សហគ្រាសផលិតទំនិញកម្មន្តសាលធំៗក្នុងស្រុក អាចជួយកាត់បន្ថយសម្ពាធដែលបង្កដោយការរំខាននៃខ្សែច្រវាក់ផ្គត់ផ្គង់តំបន់ និងសកល ព្រមទាំងអាចជួយកាត់បន្ថយការពឹងផ្អែកលើទំនិញនាំចូលពីបរទេស និងហានិភ័យ ដែលកើតឡើងពីការដាក់ចេញនូវវិធានការរឹតត្បិតការនាំចេញទំនិញចាំបាច់នានាពីបរទេសក្នុងអំឡុងពេលមានវិបត្តិ។ ការណ៍នេះអនុញ្ញាតឱ្យសហគ្រាសក្នុងស្រុក នៅតែអាចបន្តផលិតទំនិញកម្មន្តសាលដើម្បីបម្រើតម្រូវការក្នុងស្រុក និងនាំចេញ ដោយមិនងាយរងឥទ្ធិពលអវិជ្ជមានពីកត្តាខាងក្រៅ ជាពិសេសវិបត្តិសកល។

យ៉ាងណាក្តី វិស័យឧស្សាហកម្មនៅកម្ពុជានៅតែត្រូវពឹងផ្អែកជាចម្បងទៅលើសហគ្រាសធុនធំ ដែលធាតុចូលផលិតកម្មភាគច្រើនមិនត្រូវបានផ្គត់ផ្គង់ដោយសហគ្រាសក្នុងស្រុក។ ជាក់ស្តែង ការស្ទង់មតិលើលក្ខខណ្ឌធុរកិច្ចរបស់ក្រុមហ៊ុនជប៉ុនដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅក្រៅប្រទេស (អាស៊ី និងអូសេអានី) ឆ្នាំ២០២១ និង២០២២ ដែលរៀបចំឡើងដោយអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន (JETRO) បានបង្ហាញថាក្រុមហ៊ុនជប៉ុននៅកម្ពុជា បានប្រើប្រាស់វត្ថុធាតុដើម និងគ្រឿងបង្គុំក្នុងស្រុកតិចជាង១០% ខណៈដែលវត្ថុធាតុដើម និងគ្រឿងបង្គុំជាង ៩០%ទៀតត្រូវបាននាំចូលពីបរទេស។

លទ្ធផលនៃរបាយការណ៍ MTR បានបង្ហាញថាសមិទ្ធកម្មនៃគោលបំណងទី៥នេះ គឺ "**នៅមានកម្រិត**" នៅឡើយ ដែលទាមទារឱ្យមានការគិតគូរបន្ថែមទៅលើការបង្កើនសមត្ថភាពផលិតកម្មក្នុងស្រុក ជាពិសេសទៅលើផលិតផលកម្មន្តសាល។ សមិទ្ធកម្មនៃគោលបំណងទី៥ ត្រូវបានវាស់វែងដោយសូចនាករ "ជញ្ជីងពាណិជ្ជកម្មផលិតផលកម្មន្តសាល" ។

## ៣. ការតាមដានសមិទ្ធកម្មនៃការអនុវត្តគោលនយោបាយ IDP

រូបភាពទី១០៖ ជញ្ជីងពាណិជ្ជកម្មផលិតផលកម្មន្តសាល (ប៊ីលានដុល្លារអាម៉េរិក)




ប្រភពទិន្នន័យ៖ WITS

រូបភាពទី១០ បានបង្ហាញថា ទំហំនៃការនាំចូល និងការនាំចេញផលិតផលកម្មន្តសាលមាន អត្រាកំណើនមធ្យមនៅចន្លោះឆ្នាំ២០២០ និង២០២៣ ប្រមាណ ៩% និង១២% ក្នុងមួយឆ្នាំរៀងគ្នា ដោយកំណើននៃការនាំចេញខ្ពស់ជាងកំណើននៃការនាំចូល។ ទំហំនៃការនាំចូល និងនាំចេញនៃផលិតផលកម្មន្តសាលមានការកើនឡើងទាំងក្នុងឆ្នាំ២០២១ និង២០២២ ខណៈដែលឱនភាពជញ្ជីងពាណិជ្ជកម្មផលិតផលកម្មន្តសាលមានការធ្លាក់ចុះពីប្រមាណ ៣,៩ប៊ីលានដុល្លារអាម៉េរិក នៅឆ្នាំ២០២១ មកត្រឹមប្រមាណ ៣,៤ប៊ីលានដុល្លារអាម៉េរិក នៅឆ្នាំ២០២២។ ការណ៍នេះបង្ហាញថា សមត្ថភាពផលិតផ្គត់ផ្គង់ក្នុងស្រុកហាក់មានភាពប្រសើរជាងមុន ព្រោះទំហំជញ្ជីងពាណិជ្ជកម្មផលិតផលកម្មន្តសាលមានការធ្លាក់ចុះ ស្របពេលកំណើននៃការនាំចេញខ្ពស់ជាងកំណើននៃការនាំចូល។ យ៉ាងនេះក្តី សមត្ថភាពផលិតផ្គត់ផ្គង់ក្នុងស្រុកនៅមិនទាន់អាចឆ្លើយតបនឹងកំណើនតម្រូវការប្រើប្រាស់ក្នុងស្រុក និងជាតុចូលផលិតកម្មសម្រាប់ផ្គត់ផ្គង់ក្នុងវិស័យកម្មន្តសាលក្នុងស្រុកបានពេញលេញនៅឡើយ។ យ៉ាងណាមិញ ទំហំនៃការនាំចូល និងនាំចេញផលិតផលកម្មន្តសាលនៅឆ្នាំ២០២៣ សុទ្ធតែមានការធ្លាក់ចុះ ខណៈឱនភាពជញ្ជីងពាណិជ្ជកម្មផលិតផលកម្មន្តសាលមានការធ្លាក់ចុះដល់ប្រមាណ ២,៥ ប៊ីលានដុល្លារអាម៉េរិក នៅឆ្នាំ២០២៣ ដែលបណ្តាលមកពីការថយចុះយ៉ាងខ្លាំងនៃការនាំចូលបើធៀបនឹងការនាំចេញ។ ការណ៍នេះអាចបណ្តាលមកពីការធ្លាក់ចុះនៃសកម្មភាពសេដ្ឋកិច្ច បង្កដោយភាពមិនប្រាកដប្រជាសេដ្ឋកិច្ចសកល ព្រមទាំងការថយចុះនៃតម្រូវការសកល។

គោលបំណងគោលនយោបាយទី៥ មានអន្តរាគមន៍គោលនយោបាយចំនួន៤ រួមមាន៖ (១) ពង្រឹងការតភ្ជាប់រវាងសហគ្រាសក្នុងស្រុកជាមួយសហគ្រាសបរទេស រួមទាំងការផ្ទេរបច្ចេកវិទ្យា (២) ពង្រឹងខ្សែច្រវាក់តម្លៃក្នុងស្រុក (៣) បង្កើនភាពជាម្ចាស់របស់សហគ្រាសក្នុងស្រុក និង (៤) បង្កើនការកែច្នៃផលិតផល

កសិកម្មសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក និងនាំចេញ។ សមិទ្ធកម្មនៃអន្តរាគមន៍គោលនយោបាយទាំង៤ នេះ មានបង្ហាញលម្អិតក្នុងបរិសិដ្ឋទី១។

គោលបំណងគោលនយោបាយនេះ មានវិធានការសរុបចំនួន ៨ ក្នុងនោះវិធានការសម្រេចពេញលេញមានចំនួន ៤, កំពុងអនុវត្តមានចំនួន ៣, និង យឺតយ៉ាវមានចំនួន ១ ដូចមានបង្ហាញក្នុងបរិសិដ្ឋទី២។

## ៣.៦. ការតាមដានវឌ្ឍនភាពជារួមនៃការអនុវត្តវិធានការគោលនយោបាយ IDP ក្នុងឆ្នាំ ២០២១-២០២៣

រូបភាពទី១១៖ ការតាមដានវឌ្ឍនភាពជារួមនៃការអនុវត្តវិធានការគោលនយោបាយ ក្នុងឆ្នាំ២០២១-២០២៣




រូបភាពទី១២៖ ការប្រៀបធៀបវឌ្ឍនភាពជារួមនៃការអនុវត្តវិធានការគោលនយោបាយ




*ក្នុងការវាយតម្លៃពាក់កណ្ដាលអាណត្តិ វិធានការចំនួន ១ ដែលស្ថិតក្នុងគោលបំណងទី៣ ពុំមានព័ត៌មានវឌ្ឍនភាព គឺ "ជំរុញការរៀបចំនូវក្របខ័ណ្ឌគោល-នយោបាយ និង យន្តការអភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍" ហើយដែលយោងតាមឯកសារគោលនយោបាយ IDP ស្ថិតនៅក្រោមក្រសួងផែនការ។ ដោយឡែកសម្រាប់ការ តាមដាន ក្នុងឆ្នាំ ២០២១-២០២៣ វិធានការមួយនេះ មានព័ត៌មានវឌ្ឍនភាពគ្រប់គ្រាន់ ព្រមទាំងត្រូវបានផ្ទេរមក ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីរាយការណ៍វិញ។

## ៣. ការតាមដានសមិទ្ធកម្មនៃការអនុវត្តគោលនយោបាយ IDP

លទ្ធផលតាមដានវឌ្ឍនភាពលើការអនុវត្តវិធានការគោលនយោបាយ បង្ហាញថា ក្នុងចំណោមវិធានការទាំងអស់ដែលគោលនយោបាយ IDP បានដាក់ចេញ (និងអនុវិធានការគាំទ្រ) ចំនួន១៣៨[១] មានវិធានការ និងអនុវិធានការសម្រេចពេញលេញចំនួន ៩៧ ស្មើនឹង ៧០%, កំពុងអនុវត្តចំនួន ២៦ ស្មើនឹង ១៩% និង យឺតយ៉ាវចំនួន ១៥ ស្មើនឹង ១១%។ បើធៀបនឹងរបាយការណ៍ MTR វិធានការនិងអនុវិធានការសម្រេចពេញលេញ បានកើនឡើងចំនួន ២០, កំពុងអនុវត្ត និងយឺតយ៉ាវ បានថយចុះ ចំនួន ២ និង ១៧ រៀងគ្នា។ វិធានការយឺតយ៉ាវ ចំនួន ១៥ ព្រមទាំងវឌ្ឍនភាពនៃវិធានការ និងអនុវិធានការទាំងអស់ ត្រូវបានរំលេចលម្អិតក្នុងបរិសិដ្ឋទី៣ និងទី៤។ គួរកត់សម្គាល់ផងដែរថា ក្នុងចំណោមវិធានការនិងអនុវិធានការដែលសម្រេចពេញលេញ ក៏មានវិធានការនិងអនុវិធានការទូទៅចំនួន ៧ ពាក់ព័ន្ធនឹងរដ្ឋបាលសារពើពន្ធទូទៅ, ការលើកកម្ពស់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីវិនិយោគសាធារណៈសម្រាប់ការអភិវឌ្ឍឧស្សាហកម្ម និងការពង្រឹងការតាមដានការអនុវត្តគម្រោងវិនិយោគ ដែលជះផលដល់គោលបំណងគោលនយោបាយទាំងអស់ផងដែរ។

## ៤. បញ្ហាប្រឈម និងហានិភ័យ

### ៤.១. បញ្ហាប្រឈមក្នុងការរៀបចំរបាយការណ៍

ការប្រមូលទិន្នន័យសូចនាករគន្លឹះសម្រាប់រៀបចំរបាយការណ៍ស្ដីពីវឌ្ឍនភាពនៃការអនុវត្ត IDP ឆ្នាំ ២០២១-២០២៣ នៅតែជាបញ្ហាប្រឈម ហើយដែលលេខាធិការដ្ឋាន IDP នៃ ក.អ.ក. ក៏ធ្លាប់បានជួបប្រទះនូវស្ថានភាពដូចគ្នានេះដែរ សម្រាប់ការរៀបចំរបាយការណ៍ MTR ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីកាលពីខែធ្នូ ឆ្នាំ២០២១។

បញ្ហាចម្បងក្នុងការប្រមូលទិន្នន័យនេះ រួមមាន៖

- ការផ្ដល់ទិន្នន័យពីប្រភពជាតិ ពុំទាន់កាលបរិច្ឆេទកំណត់។
- ការផ្ដល់ទិន្នន័យពុំមានសង្គតិភាព ជាមួយទិន្នន័យដែលធ្លាប់បានផ្ដល់សម្រាប់ការវាយតម្លៃពាក់កណ្ដាលអាណត្តិ ហើយដែលទាមទារឱ្យមានការបញ្ជាក់ពីក្រសួង ស្ថាប័នសាមី។
- ភាពយឺតយ៉ាវនៃការធ្វើបច្ចុប្បន្នកម្មរបស់ប្រភពទិន្នន័យអន្តរជាតិ ដូចជា WITS និង ILO។

កង្វះខាត និងអសង្គតិភាពនូវទិន្នន័យនិងព័ត៌មានខាងលើបានធ្វើឱ្យលទ្ធផល ដែលបានមកពីការវិភាគពីស្ថានភាពនៃការអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា ពុំមានភាពពេញលេញ។

[១] ដើម្បីផ្ដល់ព័ត៌មានគ្រប់ជ្រុងជ្រោយអំពីទិដ្ឋភាពនៃការអនុវត្តវិធានការមួយចំនួន ពិសេសវិធានការដែលមានលក្ខណៈពហុបំណង ឬអន្តរវិស័យ ក្រសួង ស្ថាប័នបានអង្គន់វិធានការ ទៅជាអនុវិធានការដែលមានចំនួនលើសពី១។ ដូចនេះ វិធានការ និងអនុវិធានការសរុបចំនួន ១៣៨ ត្រូវបានយកមកតាមដាន។

## ៩.២. បញ្ហាប្រឈមក្នុងការអនុវត្តគោលនយោបាយ

ជាការកត់សម្គាល់ ការអនុវត្តគោលនយោបាយ IDP ក្នុងឆ្នាំ២០២១-២០២៣ ជួបប្រទះនូវបញ្ហាមួយចំនួន រួមមានៈ វិបត្តិជំងឺកូវីដ-១៩, កង្វះធនធានមនុស្ស និងថវិកាក្នុងការអនុវត្តវិធានការគោលនយោបាយមួយចំនួន និងការពុំទាន់បានកំណត់គោលដៅថ្មីសម្រាប់សូចនាករគន្លឹះមួយចំនួន។

វិបត្តិជំងឺកូវីដ-១៩ បានជះឥទ្ធិពលយ៉ាងខ្លាំងដល់វិស័យឧស្សាហកម្មកម្ពុជា ជាពិសេសអនុវិស័យកម្មន្ត-សាល ដោយសារការរាំងស្ទះនៃការដឹកជញ្ជូននិងភស្តុភារកម្ម និងភាពអាក់រអួលនៃការផ្គត់ផ្គង់កត្តាផលិតកម្មមួយចំនួន ដូចជា វត្ថុធាតុដើម និងកម្លាំងពលកម្ម ជាដើម។

ក្នុងការបន្តអនុវត្តចាប់ពីឆ្នាំ២០២១ កន្លងមកនេះ សូចនាករមួយចំនួនពុំទាន់ត្រូវបានកំណត់គោលដៅថ្មីនៅឡើយ ខណៈដែលប្រភពគណនីជាតិ និងប្រភពទិន្នន័យអន្តរជាតិ (WITS) បានផ្លាស់ប្តូរឆ្នាំគោលពីឆ្នាំ២០០០ មក ២០១៤ និង២០១៥ រៀងគ្នា ដែលធ្វើឱ្យតួលេខនៃសូចនាករមួយចំនួននៅក្នុងរបាយការណ៍នេះខុសគ្នាទៅនឹងតួលេខក្នុងរបាយការណ៍ MTR។ ដោយឡែក គោលដៅដែលមានចែងក្នុងឯកសារគោលនយោបាយ IDP ត្រូវបានកំណត់ដោយផ្អែកលើឆ្នាំគោលនៅមុនឆ្នាំ២០១៤។ ការណ៍នេះនាំឱ្យប៉ះពាល់ដល់សេចក្តីសន្និដ្ឋានលើការវិភាគពីសមិទ្ធកម្មនៃការអនុវត្តគោលនយោបាយនេះ ដោយហេតុថាគោលដៅទាំងនោះលែងឆ្លើយតបទៅនឹងសមិទ្ធកម្មជាក់ស្តែង (តួលេខទិន្នន័យសូចនាករដែលប្រើប្រាស់ឆ្នាំគោលថ្មី២០១៤ និង២០១៥)។

ក្នុងន័យនេះ ការកំណត់គោលដៅថ្មីសម្រាប់សូចនាករគន្លឹះមួយចំនួន ជាការងារអាទិភាព មុននឹងឈានទៅធ្វើការវាយតម្លៃបូកសរុបលទ្ធផលចុងអាណត្តិ នៅឆ្នាំ២០២៥ ខាងមុខ។ម្យ៉ាងវិញទៀត ធនធានមួយចំនួន ដូចជាធនធានមនុស្ស និងថវិកាគាំទ្រ គួរត្រូវបានបំពេញបន្ថែម ដើម្បីជំរុញប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ IDP។ តួយ៉ាង ការផ្សារភ្ជាប់និងបន្សុីគ្នានៃផែនការសកម្មភាពគោលនយោបាយទៅនឹងការងារអាទិភាពរបស់ក្រសួង ស្ថាប័នសាមី និងការធានានូវធនធានគ្រប់គ្រាន់ក្នុងការអនុវត្តផែនការសកម្មភាពទទួលបន្ទុកដោយក្រសួង ស្ថាប័ន ក៏ជាប្រការចាំបាច់ផងដែរ។

## ៩.៣. ហានិភ័យ

ទន្ទឹមនឹងបញ្ហាប្រឈមក្នុងការរៀបចំរបាយការណ៍ និងការអនុវត្តគោលនយោបាយ IDP ក្នុងឆ្នាំ២០២១-២០២៣ ដូចបានលើកឡើងខាងលើ ក៏សង្កេតឃើញលេចចេញនូវហានិភ័យ និងចរន្តនិន្នាការតំបន់ និងសកលមួយចំនួន ដែលអាចជះឥទ្ធិពល និងបង្កហានិភ័យដល់វិស័យឧស្សាហកម្មនៅកម្ពុជា ពិសេសអនុវិស័យកម្មន្តសាល ក្នុងនោះរួមមាន ភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយនិងសេដ្ឋកិច្ច, ការរុះរើខ្សែច្រវាក់ផ្គត់ផ្គង់ផលិតកម្ម, ឌីជីថលូបនីយកម្មក្នុងឧស្សាហកម្ម, បម្រែបម្រួលប្រជាសាស្ត្រ, ការប្រែប្រួលអាកាសធាតុ និងការជំរុញសេដ្ឋកិច្ចបៃតង, និងការចាកចេញពី LDC។

## ភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយនិងសេដ្ឋកិច្ច៖

ភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ច មានជាអាទិ៍ សង្គ្រាមដ៏រ៉ាំរ៉ៃរវាងរុស្ស៊ី-អ៊ុយក្រែន ការអូសបន្លាយនៃជម្លោះនៅមជ្ឈិមបូព៌ា សង្គ្រាមពាណិជ្ជកម្មនិងបច្ចេកវិទ្យារវាងប្រទេសមហាអំណាច និងការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុរបស់ប្រទេសអភិវឌ្ឍន៍ជាពិសេសសហរដ្ឋអាម៉េរិក បាននិងកំពុងយាយីដល់សន្តិសុខអន្តរជាតិ យន្តការពហុភាគីនិយម សកលភាវូបនីយកម្ម និងស្ថិរភាពហិរញ្ញវត្ថុសកល។ ភាពតានតឹងទាំងនេះ បង្កឱ្យមានវិបត្តិថាមពល អតិផរណាសកល ព្រមទាំងបាននិងកំពុងជំរុញឱ្យមាននិន្នាការគាំពារនិយម និងចរន្តបដិសកលភាវូបនីយកម្ម ហើយបែរទៅរកចរន្តតំបន់និយម។ ការណ៍នេះ បានធ្វើឱ្យសេដ្ឋកិច្ចសកលមានភាពមិនប្រាកដប្រជា ហើយបានធ្វើឱ្យប៉ះពាល់ដល់ការសម្រេចចិត្តរបស់វិនិយោគិនក្នុងការបណ្តាក់ទុនវិនិយោគ និង/ឬ ពង្រីកគម្រោងវិនិយោគ ព្រមទាំងបណ្តាលឱ្យប៉ះពាល់ដល់លំហូរពាណិជ្ជកម្ម និងខ្សែច្រវាក់ផ្គត់ផ្គង់ផលិតកម្មផងដែរ។

ក្នុងបរិការណ៍នេះ ហានិភ័យនេះអាចនឹងបន្តជះឥទ្ធិពលអវិជ្ជមានដល់កម្ពុជា ដែលជាប្រទេសតូចនិយាយជារួម និងវិស័យឧស្សាហកម្មកម្ពុជា និយាយដោយឡែក។ ទោះជាយ៉ាងនេះក្តី រាល់បញ្ហានិងឧបសគ្គជានិច្ចកាលតែងតែបង្កប់នូវកាលានុវត្តភាព។ តួយ៉ាង កម្ពុជាបាននិងកំពុងត្រៀមខ្លួនយ៉ាងបុរេសកម្មក្នុងការចាប់យកនូវអត្ថប្រយោជន៍ និងកាលានុវត្តភាពនានាដែលអាចនឹងលេចរូបរាងឡើង តាមរយៈការប្រកាន់ខ្ជាប់នូវគោលការណ៍នៃ «*កិច្ចសហប្រតិបត្តិការអន្តរជាតិ ដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមក និងផ្អែកលើវិធាននៃច្បាប់*» និងគោលការណ៍ «*ពហុភាគីនិយម និងការលើកកម្ពស់ការបើកចំហពាណិជ្ជកម្មអន្តរជាតិ*» ព្រមទាំងដាក់ចេញនូវអភិក្រម និងយុទ្ធសាស្ត្រថ្មីៗសម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច រួមមាន៖ ការដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងបទដ្ឋានពាក់ព័ន្ធ សំដៅអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្ននៅកម្ពុជា ព្រមទាំងបានបន្តដាក់ចេញនិងអនុវត្តគោលនយោបាយពាក់ព័ន្ធជាបន្តបន្ទាប់ ដើម្បីប្រឈមទប់ទៅនឹងការប្រែប្រួលហិរញ្ញវត្ថុសកល ដោយរក្សាឱ្យបាននូវស្ថិរភាពថ្លៃនិងហិរញ្ញវត្ថុក្នុងប្រទេស។

ជាមួយគ្នានេះ ដើម្បីធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ច និងវិនិយោគនៅកម្ពុជា រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ចម្បងៗចំនួន១១ចំណុច នៅក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩ រួមមាន៖ (១) ការកែសម្រួលបរិយាកាសធុរកិច្ច និងការវិនិយោគ (២) ការសម្រាលបន្ទុកលើអនុលោមភាព (៣) ការសម្រួលដល់ធុរកិច្ចក្រោមដែនសមត្ថកិច្ចពន្ធដារ (៤) កិច្ចសម្រួលពាណិជ្ជកម្មក្រោមដែនសមត្ថកិច្ចគយ (៥) ការលើកកម្ពស់ការដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធ (៦) ការស្តារ និងការលើកស្ទួយការអភិវឌ្ឍវិស័យទេសចរណ៍ (៧) ការអភិវឌ្ឍវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម (៨) វិស័យធនាគារ និងហិរញ្ញវត្ថុ (៩) វិស័យរ៉ែ និងថាមពល (១០) វិស័យសំណង់ និងអចលនទ្រព្យ និង (១១) បញ្ហាផ្សេងៗ។ ការណ៍នេះ បានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តខ្ពស់របស់ប្រមុខរាជរដ្ឋាភិបាល ដែលតែងតែបាត់ទុក

វិស័យឯកជនជាដៃគូដ៏សំខាន់ និងជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចជាតិ ដោយបានទទួលយកនូវសំណូមពរ និងបញ្ហាប្រឈមរបស់ផ្នែកឯកជន ពិនិត្យ ដោះស្រាយ និងអន្តរាគមន៍។

**ការរុះរើខ្សែច្រវាក់ផ្គត់ផ្គង់ផលិតកម្ម៖**

និន្នាការសកលនេះ ជាផលជះនៃវិបត្តិនៃជំងឺកូវីដ-១៩ និងភាពតានតឹងខាងភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ច មកលើវិស័យឧស្សាហកម្ម ជាពិសេសអនុវិស័យកម្មន្តសាល។ ជាក់ស្តែង ផលជះអវិជ្ជមាននៃវិបត្តិជំងឺកូវីដ-១៩ និងសង្គ្រាមពាណិជ្ជកម្មរវាងអាម៉េរិកនិងចិន ព្រមទាំងការកើនឡើងនូវថ្លៃដើមផលិតនិងពលកម្មនៅក្នុងប្រទេសចិន ដែលជាមជ្ឈមណ្ឌលផលិតកម្មពិភពលោក បាននិងកំពុងជំរុញឱ្យសាជីវកម្មពហុជាតិជាច្រើន គិតគូកែសម្រួលផែនការខ្សែច្រវាក់ផ្គត់ផ្គង់របស់ខ្លួនសម្រាប់រយៈពេលខ្លី និងមធ្យមខាងមុខ មកកាន់ប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសក្នុងតំបន់អាស៊ាន ដែលមានថ្លៃពលកម្មប្រកបដោយភាពប្រកួតប្រជែង ហេដ្ឋារចនាសម្ព័ន្ធកាន់តែល្អប្រសើរ និងគោលនយោបាយវិនិយោគល្អ និងងាកមកផ្តោតលើការធ្វើពិពិធកម្មខ្សែច្រវាក់ផ្គត់ផ្គង់ ដែលពឹងផ្អែកលើទីតាំងផ្គត់ផ្គង់ពីរឬច្រើន (dual or multiple sourcing strategies) សម្រាប់បម្រើសកម្មភាពផលិតកម្មរបស់ខ្លួន។ យុទ្ធសាស្ត្រពិពិធកម្មទាំងនោះ រួមមានជាអាទិ៍៖

- ការរុះរើខ្សែច្រវាក់ផ្គត់ផ្គង់មួយផ្នែកមកកាន់មូលដ្ឋានផលិតកម្មក្នុងប្រទេសដើមវិញ (Reshoring)
- ការចូលរួមកាន់តែស៊ីជម្រៅទៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់តំបន់
- ការផ្លាស់ខ្សែច្រវាក់ផ្គត់ផ្គង់មួយចំនួន ឬទាំងស្រុងទៅប្រទេសជាសម្ព័ន្ធមិត្ត (Friend-shoring) ជាដើម។

តួយ៉ាង រំហូរវិនិយោគមួយចំណែកធំមកកាន់តំបន់អាស៊ី (ប្រមាណ៤០%) នឹងរុញច្រានដោយការវិនិយោគពីចិន ហើយទំនងជានឹងត្រូវបានស្រូបទាញដោយបណ្តាប្រទេសមួយចំនួនដូចជា កម្ពុជា ហ្វីលីពីន និងឥណ្ឌា ដែលឈរនៅក្នុងកំពូលតារាងនៃប្រទេសទាំង១០ ដែលត្រូវបានចាត់ថ្នាក់ជាប្រទេសដែលមានជវភាពនៃការវិនិយោគខ្ពស់ជាងគេសម្រាប់ឆ្នាំ២០២៤ (យោងតាម FDI Standout Watchlist 2024 របស់ fDi Intelligence នៃទស្សនាវដ្តី Financial Times)។ ក្នុងន័យនេះ កម្ពុជាអាចចាប់យកនូវកាលានុវត្តភាពនានាដែលលេចចេញពីនិន្នាការនេះ តាមរយៈការរក្សាឱ្យបាននូវភាពប្រកួតប្រជែងខ្ពស់ក្នុងការទាក់ទាញវិនិយោគ ជាពិសេសការវិនិយោគក្នុងវិស័យឧស្សាហកម្ម ដែលផ្តល់តម្លៃបន្ថែមខ្ពស់ដល់សេដ្ឋកិច្ចកម្ពុជា។

**ឌីជីថលូបនីយកម្មក្នុងឧស្សាហកម្ម៖**

រលកថ្មីមួយទៀតនៃនិន្នាការសកល បានចូលមកដល់ប្រទេសកម្ពុជាជាបណ្តើរៗគឺបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤។ រលកថ្មីនេះបាននិងកំពុងជ្រាបចូលបន្តិចម្តងៗក្នុងវិស័យឧស្សាហកម្មកម្ពុជាផងដែរ។ ផ្អែកលើ

សេណារីយ៉ូល្អបំផុត ឌីជីថលូបនីយកម្ម (Digitalization) និងឌេខូបនីយកម្ម (Digitization) នឹងផ្តល់កាលានុវត្ត-ភាពច្រើនដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាលើផ្នែកផលិតភាព ប្រសិទ្ធភាពសេដ្ឋកិច្ច ពិពិធកម្មសេដ្ឋកិច្ច ភាពប្រកួតប្រជែង ព្រមទាំងជំរុញការអភិវឌ្ឍប្រកបដោយចីរភាព បរិយាបន្ន និងសុខុមាលភាពសង្គមផងដែរ។ បើផ្អែកលើសេណារីយ៉ូអាក្រក់បំផុតវិញ ប្រទេសកំពុងអភិវឌ្ឍន៍អាចដើរពុំទាន់ប្រទេសអភិវឌ្ឍន៍ ដោយសារឧស្សាហកម្មរបស់ខ្លួននៅពឹងផ្អែកលើអតិពលកម្ម វិស័យអប់រំនៅមានកម្រិត ចំនួនកម្មករជំនាញបច្ចេកទេសមធ្យមនិងខ្ពស់នៅមានចំនួនតិចតួចនៅឡើយ ដោយទាមទារឱ្យមានការវិនិយោគលើមូលធនមនុស្សឌីជីថលឱ្យបានច្រើន។

ទន្ទឹមនឹងនេះ ឌីជីថលូបនីយកម្ម ក៏នឹងអាចបង្កឱ្យមាននិកម្មភាពជារចនាសម្ព័ន្ធផងដែរសម្រាប់កម្មករនិយោជិតដែលគ្មានជំនាញ ឬមានកម្រិតជំនាញទាប និងអាចធ្វើឱ្យប៉ះពាល់ដល់ជីវភាពរបស់ពួកគេ។ គម្លាតឌីជីថលកាន់តែធំក៏អាចនឹងជះឥទ្ធិពលអវិជ្ជមាន ដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចទាំងមូលផងដែរ។ យ៉ាងណាមិញ កម្ពុជាបាន និងកំពុងត្រៀមខ្លួនយ៉ាងសកម្ម ក្នុងការដាក់ចេញនូវគោលនយោបាយ យុទ្ធសាស្ត្រ ផែនទីបង្ហាញផ្លូវ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា សំដៅលើកកម្ពស់វិស័យអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេក-វិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM)។ ក្នុងបរិការណ៍នេះ កម្ពុជាក៏គួរតែគិតគូរឱ្យបានល្អិតល្អន់អំពីហានិភ័យ ដើម្បីទាញយកនូវកាលានុវត្តភាព និងចៀសវាងការធ្លាក់ចូលក្នុងសេណារីយ៉ូអាក្រក់បំផុត តាមរយៈការបន្ស៊ាំ បន្សាំ ចាប់យក និងពង្រឹងបច្ចេកវិទ្យា, នវានុវត្តន៍ឌីជីថល, ភាពជឿទុកចិត្តក្នុងបរិស្ថានឌីជីថល, សុវត្ថិភាពឌីជីថល និងបង្កើនការវិនិយោគលើមូលធនបច្ចេកវិទ្យា ពិសេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តតភ្ជាប់បច្ចេកវិទ្យា និងបណ្តាញ/ទិន្នន័យ ដើម្បីធានាថាកម្ពុជាអាចវិវឌ្ឍខ្លួនទាន់បដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤។

**បម្រែបម្រួលប្រជាសាស្ត្រ៖**

កំណើនប្រជាជនវ័យចំណាស់ នៅបណ្តាប្រទេសសេដ្ឋកិច្ចរីកចម្រើនមួយចំនួន ជាពិសេសចិន និងជប៉ុន ផ្តល់បច្ច័យអវិជ្ជមានចំពោះសក្តានុពលកំណើនសេដ្ឋកិច្ចក្នុងតំបន់ និងបណ្តាលឱ្យសកម្មភាពឧស្សាហកម្មមួយចំនួន ជាពិសេសឧស្សាហកម្មបែបអតិពលកម្ម ហូរចូលទៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានកត្តាប្រជាសាស្ត្រវ័យក្មេងពោរពេញដោយកម្លាំងពលកម្មច្រើន និងមានប្រាក់ឈ្នួលប្រកួតប្រជែងខ្ពស់ ដូចជាកម្ពុជា វៀតណាម និងឥណ្ឌា ជាដើម។ ទោះជាយ៉ាងណាក៏ដោយ ការត្រៀមខ្លួនក្នុងការចាប់យកលំហូរទុនវិនិយោគពីបណ្តាប្រទេសអភិវឌ្ឍន៍ដែលប្រឈម នឹងការគំរាមកំហែងនៃកំណើនប្រជាជនវ័យចំណាស់ទាំងអស់នោះតែម្យ៉ាង គឺពុំទាន់គ្រប់គ្រាន់ឡើយ ដូច្នេះយើងត្រូវតែមានការបំពាក់បំប៉នជំនាញដល់កម្លាំងពលកម្មដ៏ច្រើនសន្ធឹកសន្ធាប់បន្ថែមទៀត ដើម្បីឈានទៅចាប់យកលំហូរឧស្សាហកម្មដែលមានបច្ចេកវិទ្យា និងតម្លៃបន្ថែមខ្ពស់។ ក្នុងន័យនេះ ការពង្រឹងការបណ្តុះបណ្តាលជំនាញនៅតាមគ្រឹះស្ថានអប់រំ និងវិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ការជំរុញសហគ្រាសដែលមានស្រាប់ឱ្យប្រើប្រាស់មូលនិធិអភិវឌ្ឍន៍ជំនាញក្នុងការ

ហ្វឹកហ្វឺនបុគ្គលិករបស់ខ្លួន និងតាមរយៈមធ្យោបាយនានាផ្សេងៗទៀត ដូចជាការបណ្តុះបណ្តាលជំនាញតាមប្រព័ន្ធឌីជីថលជាដើម គឺជាកត្តាដ៏ចាំបាច់ក្នុងការជំរុញការបណ្តុះបណ្តាលជំនាញនៅនឹងកន្លែងការងារ ស្របតាមតម្រូវការ និងទិសដៅទីផ្សារការងារនាពេលបច្ចុប្បន្ន និងអនាគត។

**ការប្រែប្រួលអាកាសធាតុ និងការជំរុញសេដ្ឋកិច្ចបៃតង៖**

ឧស្សាហូបនីយកម្មជាមូលហេតុមួយក្នុងចំណោមមូលហេតុចម្បងដទៃទៀត ដែលបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន ដោយបានចូលរួមចំណែកដល់ការធ្វើឱ្យមានការប្រែប្រួលអាកាសធាតុ។ ទោះជាយ៉ាងនេះក្តី ក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះ កិច្ចសន្ទនាថ្នាក់តំបន់ និងសកលស្តីពីបរិស្ថាន និងការប្រែប្រួលអាកាសធាតុ មានសម្ទុះកាន់តែខ្លាំងក្លាឡើងជាលំដាប់។ ប្រទេសមួយចំនួនរួមទាំងកម្ពុជាផង បានដាក់ចេញនិងអនុវត្តគោលនយោបាយ និងវិធានការនានាជាច្រើន ដើម្បីចូលរួមកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងជំរុញភាពធន់នឹងអាកាសធាតុ រួមមានជាអាទិ៍៖

- ការជំរុញការធ្វើអន្តរកាលថាមពលពីការប្រើប្រាស់ផូស៊ីលឥន្ធនៈ ទៅប្រភពថាមពលស្អាត ព្រមទាំងជំរុញឱ្យមានការប្រើប្រាស់បច្ចេកវិទ្យាថាមពលកកើតឡើងវិញ និងការអនុវត្តកម្មវិធីប្រសិទ្ធ-ភាពថាមពល
- ការអនុវត្តកិច្ចសន្យាជានាតម្លៃទីផ្សារសម្រាប់ផលិតកម្មថាមពលកកើតឡើងវិញ (Feed-in Tariff)
- ការវិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបៃតង និងធន់នឹងអាកាសធាតុ
- ការជំរុញសេដ្ឋកិច្ចបៃតង ការវិនិយោគបៃតង ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននិងភស្តុភារកម្មបៃតង, ហិរញ្ញប្បទានបៃតង នវានុវត្តន៍បៃតង បច្ចេកវិទ្យាបៃតង និងថាមពលបៃតង
- ការកាត់បន្ថយការប្រើប្រាស់ការប្រើប្រាស់ថង់ប្លាស្ទិក និងសារធាតុគ្រោះថ្នាក់ដែលបង្កផលប៉ះពាល់ដល់បរិស្ថាន និងលើកកម្ពស់ការអភិវឌ្ឍប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់
- ការជំរុញអនុវត្តគោលការណ៍3R រួមមាន ការកាត់បន្ថយ (Reduce) ការប្រើប្រាស់ឡើងវិញ (Reuse) និងការកែច្នៃឡើងវិញ (Recycle) ក្នុងខ្សែច្រវាក់ផលិតកម្ម
- ការជំរុញការផលិតនិងប្រើប្រាស់មធ្យោបាយដឹកជញ្ជូនមេត្រីបរិស្ថាន
- ការធ្វើសនិទានកម្មមូលដ្ឋានចំណូលពន្ធ, ការឧបត្ថម្ភធន និងការបោះផ្សាយសញ្ញាបណ្ណបៃតង (Green Bonds)
- ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី (Payment for Ecosystem Services)
- ការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA), ស្តង់ដារបរិស្ថាន សង្គមនិងអភិបាលកិច្ច (ESG) និងស្តង់ដារនៃការបង្កើតថាមពលពីប្រភពកកើតឡើងវិញ (Renewable Portfolio Standard-RPS) ដូចជា ថាមពលពន្លឺព្រះអាទិត្យ ថាមពលខ្យល់ និងជីវឧស្ម័ន ជាដើម។

## ៨. បញ្ហាប្រឈម និងហានិភ័យ

កន្លងមក រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំតាក់តែងគោលនយោបាយនិងវិធានការមួយចំនួនឆ្លើយតបនឹងបញ្ហាទាំងនេះ ដែលបានជំរុញឱ្យកម្ពុជាមានលទ្ធភាពប្រើប្រាស់ថាមពលស្អាតរហូតដល់ប្រមាណ៦០% នាពេលបច្ចុប្បន្ន និងបន្តជំរុញឱ្យឈានទៅដល់៧០% នៅក្នុងឆ្នាំ២០៣០។ នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវ ***"ក្រមបរិស្ថាន និងធនធានធម្មជាតិ"*** *(Code on Environment and Natural Resources)* ដែលប្រមូលផ្តុំសំយោគបញ្ចូលគ្នានូវបទប្បញ្ញត្តិ នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមានពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិ ដើម្បីឱ្យសមស្របនឹងការរីកចម្រើននៃសង្គមកម្ពុជាថ្មី និងការពង្រឹងនីតិរដ្ឋទៅកាន់ដំណាក់កាលថ្មីនៅលើមាគ៌ាចីរភាព។ លើសពីនេះ ***"យុទ្ធសាស្ត្ររយៈពេលវែងប្រកបដោយអព្យាក្រឹត្យកាបូន"*** និង ***"យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ២០២៣-២០២៨"*** ក៏ត្រូវបានដាក់ចេញផងដែរ ដែលជាសក្ខីភាពបញ្ជាក់នូវការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុ។ ទោះជាយ៉ាងនេះក្តី រាជរដ្ឋាភិបាលកម្ពុជា និងតួអង្គពាក់ព័ន្ធទាំងអស់នៅក្នុងវិស័យឧស្សាហកម្មនៅកម្ពុជា ត្រូវរៀបចំដាក់ចេញ និងអនុវត្តគោលនយោបាយ និងគោលការណ៍នានាបន្ថែម លើបញ្ហាប្រែប្រួលអាកាសធាតុ និងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចបៃតង រួមទាំងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននិងភស្តុភារកម្មបៃតង ដូចជា ប្រព័ន្ធដឹកជញ្ជូនតាមផ្លូវទឹកសាប គម្រោងព្រែកជីកហ្វូណនតេជោ ផ្លូវដែក និងប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ជាដើម សំដៅរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ លើកកម្ពស់បរិស្ថាន និងធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្ន និងឆ្ពោះទៅសម្រេចបានតាមគោលដៅរបស់រាជរដ្ឋាភិបាលស្តីពីអព្យាក្រឹតភាពកាបូននៅឆ្នាំ២០៥០។

**ការចាកចេញពី LDC៖**

ការចាកចេញនេះ អាចនាំឱ្យកម្ពុជាបាត់បង់នូវការអនុគ្រោះផ្នែកពាណិជ្ជកម្មសម្រាប់ទីផ្សារសហរដ្ឋ-អាម៉េរិក ក្រោមប្រព័ន្ធអនុគ្រោះពន្ធទូទៅ (Generalized System of Preferences-GSP) និងសហភាព-អឺរ៉ុប ក្រោមប្រព័ន្ធអនុគ្រោះពន្ធគ្រប់យ៉ាងលើកលែងតែអាវុធ(Everything But Arms-EBA)។ បន្ថែមលើនេះ ការចាកចេញនេះក៏នឹងធ្វើឱ្យកម្ពុជាបាត់បង់នូវការអនុគ្រោះពាណិជ្ជកម្ម ក្រោមប្រព័ន្ធអនុគ្រោះទូទៅសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច (GSP LDC-Specific Schemes), ភាពអនុគ្រោះផ្នែកហិរញ្ញវត្ថុ, ជំនួយបច្ចេកទេស, និងភាពអនុគ្រោះក្នុងភាពជាសមាជិកនៅក្នុងកិច្ចព្រមព្រៀង និងសហគមន៍អន្តរជាតិនានា ផងដែរ។ បើទោះបីកន្លងមកនេះ កម្ពុជាបង្កើនការចរចា FTA ក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគី (ASEAN, ASEAN+1, RCEP ។ល។) ការបាត់បង់នូវភាពអនុគ្រោះផ្នែកពាណិជ្ជកម្ម សម្រាប់ទីផ្សារសហរដ្ឋអាម៉េរិក សហភាពអឺរ៉ុប និងទីផ្សារដទៃទៀតនៅក្រោមប្រព័ន្ធអនុគ្រោះទូទៅសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច នៅតែជាហានិភ័យចៀសមិនផុត សម្រាប់វិស័យឧស្សាហកម្មនៅកម្ពុជា ដោយសារៈ

- មូលដ្ឋាននាំចេញរបស់កម្ពុជាប្រមូលផ្ដុំខ្លាំងតែទៅលើមុខទំនិញ និងទីផ្សារមួយចំនួនប៉ុណ្ណោះ (សហរដ្ឋអាម៉េរិក និងសហភាពអឺរ៉ុប) ដោយពុំទាន់មានភាពប្រទាក់ក្រឡាស៊ីជម្រៅខ្លាំងទៅក្នុងបណ្ដាញពាណិជ្ជកម្មតំបន់
- ការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរបស់វិស័យឯកជននៅមានកម្រិត
- មូលដ្ឋាននាំចេញរបស់កម្ពុជាទៅប្រទេសដៃគូ FTA មានលក្ខណៈតូចចង្អៀត ខណៈដែប្រទេសទាំងនោះក៏ជាដៃគូប្រកួតប្រជែង សម្រាប់ការនាំចេញទៅទីផ្សារសហរដ្ឋអាម៉េរិក និងសហភាពអឺរ៉ុបដូចគ្នា ផងដែរ។

ហានិភ័យនេះ អាចបន្តប៉ះពាល់ដល់លំហូរវិនិយោគ និងពាណិជ្ជកម្ម ក្នុងវិស័យឧស្សាហកម្មនៅកម្ពុជា ព្រោះការជ្រៀតចូលទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិក និងសហភាពអឺរ៉ុប ដែលជាទីផ្សារធំសម្រាប់កម្ពុជាក្រោមលក្ខខណ្ឌអនុគ្រោះជាកត្តាគន្លឹះទាក់ទាញវិនិយោគ និងជាកាតាលីករសម្រាប់ពាណិជ្ជកម្មកម្ពុជាកន្លងមក។ ក្នុងន័យនេះ ការបើកច្រកទីផ្សារតាមរយៈការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីបន្ថែម ការបង្កើនភាពប្រទាក់ក្រឡាឱ្យកាន់តែស៊ីជម្រៅទៅនឹងខ្សែច្រវាក់ផ្គត់ផ្គង់តំបន់និងសកល និងការជំរុញពិពិធកម្មឧស្សាហកម្ម ជាជម្រើសអាទិភាព ដើម្បីកាត់បន្ថយភាពងាយរងគ្រោះផ្នែកពាណិជ្ជកម្ម។ បន្ថែមលើនេះ ការបង្កើនកម្លាំងចរចាបើកច្រកទីផ្សារ និងការបើកការចរចាឡើងវិញជាមួយសហរដ្ឋអាម៉េរិក និងសហភាពអឺរ៉ុប ជាកត្តាសំខាន់ ដើម្បីរក្សាបាននូវភាពប្រកួតប្រជែងសម្រាប់ការនាំចេញទៅកាន់ទីផ្សារទាំងពីរ។ លើសពីនេះ ការពង្រឹងបរិយាកាសអំណោយផលសម្រាប់ពាណិជ្ជកម្ម ធុរកិច្ច និងវិនិយោគបន្ថែមទៀតក៏ជាកត្តាចាំបាច់ផងដែរ ដើម្បីបង្កើនភាពប្រកួតប្រជែងសេដ្ឋកិច្ច និងភាពទាក់ទាញវិនិយោគ ក្នុងទីផ្សារអន្តរជាតិដែលកាន់តែមានភាពប្រកួតប្រជែង និងមានលក្ខខណ្ឌតម្រូវខ្ពស់ជាងមុន ដើម្បីកម្ពុជាអាចចាកចេញពី LDC បានដោយរលូន។

## ៩. សេចក្ដីសន្និដ្ឋាន និងទិសដៅបន្ត

របាយការណ៍ស្ដីពីវឌ្ឍនភាព ឆ្នាំ២០២១-២០២៣ នៃការអនុវត្តគោលនយោបាយ IDP បានប្រើប្រាស់ឧបករណ៍សំខាន់ៗនៃក្របខណ្ឌតាមដាននិងវាយតម្លៃត្រឹមត្រូវ និងច្បាស់លាស់រួមមាន៖ តក្កកម្មអន្តរាគមន៍, ក្របខណ្ឌតក្កកម្ម, និងទម្រង់គំរូរបាយការណ៍ ដូចដែលធ្លាប់បានអនុវត្ត ក្នុងរបាយការណ៍ MTR។ ទន្ទឹមនឹងនេះ ក្នុងការធ្វើឱ្យការវិភាគកាន់តែមានភាពគ្រប់ជ្រុងជ្រោយ របាយការណ៍នេះក៏បានប្រើប្រាស់វិធីសាស្ត្រចម្រុះ ដោយរួមបញ្ចូលទាំងវិធីសាស្ត្របែបបរិមាណវិស័យ និងគុណវិស័យ ដោយផ្ដោតសំខាន់លើសមិទ្ធកម្មសម្រេចបានក្នុងកម្រិតយុទ្ធសាស្ត្រ (គោលបំណងគោលនយោបាយ) ព្រមទាំងសង្ខេបខ្លីអំពីវឌ្ឍនភាពនៃការអនុវត្តវិធានការ បញ្ហាប្រឈមនិងហានិភ័យនៃការអនុវត្តគោលនយោបាយ។

ការតាមដានសមិទ្ធកម្មនៃការអនុវត្តគោលនយោបាយ IDP ក្នុងឆ្នាំ២០២១-២០២៣ ត្រូវបានធ្វើឡើងស្ទើរទាំងស្រុង តាមរយៈការវិភាគសូចនាករ ដែលបានកំណត់ក្នុងគោលបំណងគោលនយោបាយទាំង៥

ទោះបីមានសូចនាករមួយចំនួនតូច ពុំមានទិន្នន័យសម្រាប់ឆ្នាំចុងក្រោយ២០២៣ ក៏ដោយ។ បើក្រឡេកមើលលើការអនុវត្តវិធានការគោលនយោបាយវិញ បង្ហាញថា ក្នុងចំណោមវិធានការទាំងអស់ដែលគោល-នយោបាយ IDP បានដាក់ចេញ (និងអនុវិធានការគាំទ្រ) មានវិធានការនិងអនុវិធានការសម្រេចពេញលេញចំនួន ៩៧ (កើនឡើងចំនួន ២០វិធានការ បើធៀបនឹង MTR) ស្មើនឹង ៧០% នៅសល់តែវិធានការមួយចំនួនតូចប៉ុណ្ណោះដែលកំពុងអនុវត្ត និងយឺតយ៉ាវ។ ជាក់ស្តែង សមិទ្ធកម្មនៃគោលបំណងគោលនយោបាយភាគច្រើន បានបង្ហាញពីវឌ្ឍនភាពវិជ្ជមាន លើកលែងតែសមិទ្ធកម្មគោលបំណងទី៣ "សេដ្ឋកិច្ចដែលមានភាពធន់ និងមានពិពិធកម្ម" និង សមិទ្ធកម្មគោលបំណងទី៥ "បង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមា" ដែលលទ្ធផលនៃការអនុវត្តវិធានការនៅមានកម្រិត។ សរុបជារួមមក លទ្ធផលអនុវត្តវិធានការ IDP មានភាពល្អប្រសើរច្រើន ទោះបីជាកម្ពុជាបានទទួលរងផលប៉ះពាល់ពីវិបត្តិនៃជំងឺកូវីដ-១៩, ភាពតានតឹងខាងភូមិសាស្ត្រនយោបាយ, ការគំរាមកំហែងដល់ពាណិជ្ជកម្មសេរី, ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល, និងជម្លោះតាមតំបន់មួយចំនួន ដែលអាចជះឥទ្ធិពលដោយផ្ទាល់ ឬប្រយោលដល់កម្ពុជា។ ការណ៍នេះបានបង្ហាញពីការយកចិត្តទុកដាក់ខ្ពស់ និងការចាត់វិធានការទប់ស្កាត់ប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលារបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តវិធានការគន្លឹះដែលបានដាក់ចេញសម្រាប់ស្តារសេដ្ឋកិច្ចឡើងវិញ បន្ទាប់ពីការស្រាកស្រាននៃការឆ្លងរាលដាលជំងឺកូវីដ-១៩ ជាពិសេសវិធានការម៉ឺងម៉ាត់ចំពោះវិស័យឧស្សាហកម្ម និងកម្មន្តសាល។

ទន្ទឹមនឹងវឌ្ឍនភាពជាវិជ្ជមានទាំងនេះ ការអនុវត្តគោលនយោបាយ IDP ក្នុងឆ្នាំ២០២១-២០២៣ ក៏បានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចជា៖ ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១ នៅកម្ពុជា ដែលបានបង្កឱ្យមានការដាក់ចេញនូវវិធានការបិទខ្ទប់តឹងរ៉ឹង ដែលប៉ះពាល់យ៉ាងខ្លាំងដល់វិស័យឧស្សាហកម្មកម្ពុជា ជាពិសេសអនុវិស័យកម្មន្តសាល។ ទន្ទឹមនឹងនេះ កង្វះធនធានមនុស្ស និងថវិកា ក៏នៅតែជាបញ្ហាប្រឈមចម្បងមួយដែលគំរាមកំហែងដល់វិសាលភាព និងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយដែលបានដាក់ចេញ។ លើសពីនេះ សូចនាករគន្លឹះមួយចំនួន ពុំទាន់បានកំណត់គោលដៅថ្មី ខណៈដែលក្រសួង ស្ថាប័នមួយចំនួនបានផ្លាស់ប្តូរឆ្នាំគោលក្នុងការគណនាតួលេខទិន្នន័យសូចនាករដែលខ្លួនទទួលបន្ទុក ដែលនាំឱ្យប៉ះពាល់ដល់សេចក្តីសន្និដ្ឋានលើការវិភាគ ពីសមិទ្ធកម្មនៃការអនុវត្តគោលនយោបាយដែលបានដាក់ចេញ។ ក្នុងន័យនេះ កម្ពុជាត្រូវខិតខំទ្វេដងដើម្បីប្រែក្លាយវិបត្តិទាំងនេះទៅជាកាលានុវត្តភាព ក៏ដូចជាត្រូវត្រៀមខ្លួនយ៉ាងបុរេសកម្មក្នុងការចាប់យកនូវអត្ថប្រយោជន៍ និងកាលានុវត្តភាពនានា ពិសេសការចាប់យកការវិនិយោគ និងធុរកិច្ច ដែលអាចហូរចេញពីតំបន់មានជម្លោះពាណិជ្ជកម្ម អស្ថិរភាពនយោបាយ ព្រមទាំងការផ្លាស់ប្តូរខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងតំបន់ ចូលមកកម្ពុជា តាមរយៈការធ្វើឱ្យកាន់តែប្រសើរឡើងនូវ បរិយាកាសធុរកិច្ចនិងវិនិយោគ។

ឆ្លើយតបទៅនឹងបញ្ហាប្រឈម និងហានិភ័យនានាដែលអាចកើតឡើងដោយថាហេតុ កម្ពុជាត្រូវយកចិត្តទុកដាក់ក្នុងការបង្កើត និងជំរុញការវិនិយោគបៃតង ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននិងភស្តុភារកម្មបៃតង ដូចជា ប្រព័ន្ធដឹកជញ្ជូនតាមផ្លូវទឹកសាប (Inland Waterway) គម្រោងព្រែកជីកហ្វូណនតេជោ ផ្លូវដែក និង

## ៨. សេចក្តីសន្និដ្ឋាន និងទិសដៅបន្ត

ប្រព័ន្ធទឹកកខ្វក់, ហិរញ្ញប្បទានបៃតង និងអន្តរកម្មបៃតង ដែលកត្តាទាំងនេះជាកាតាលីករក្នុងការជំរុញការធ្វើពិពិធកម្ម និងអភិវឌ្ឍឧស្សាហកម្ម និងសេដ្ឋកិច្ច ព្រមទាំងលើកកម្ពស់ផលិតភាពនិងភាពប្រកួតប្រជែងរបស់កម្ពុជា ដើម្បីធានាបាននូវការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព បរិយាបន្ននិងមានភាពធន់។ លើសពីនេះ ស្របពេល និន្នាការសកលថ្មីមួយទៀតដែលបានចូលមកដល់ប្រទេសកម្ពុជានោះគឺ បដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ កម្ពុជាក៏ត្រូវជំរុញការធ្វើបរិវត្តកម្មឌីជីថលឱ្យបានឆាប់រហ័សដើម្បីជួយរុញច្រានសន្ទុះកំណើន បង្កើតនូវចន្ទល់កំណើនសេដ្ឋកិច្ចថ្មី និងសម្របខ្លួនឱ្យទាន់ជាមួយបរិបទថ្មី ក៏ដូចជាការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានពីបច្ចេកវិទ្យាឌីជីថលឱ្យស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន។

សម្រាប់ទិសដៅបន្ទាប់ រាជរដ្ឋាភិបាលនឹងបន្តប្រកាន់ខ្ជាប់នូវស្មារតីបុរេសកម្ម ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព និងវិសាលភាពជាអតិបរមាក្នុងការអនុវត្តគោលនយោបាយដែលបានដាក់ចេញ ព្រមទាំងបន្តតាមដាន និងវាយតម្លៃ ការអនុវត្តគោលនយោបាយ IDP នៅចុងអាណត្តិនៃគោលនយោបាយនេះ ដើម្បីជាមូលដ្ឋានដាក់ចេញនូវគោលនយោបាយសមស្របនាពេលបន្ទាប់មកទៀត។ ក្នុងន័យនេះ ក.អ.ក. ដែលជាស្ថាប័ន សម្របសម្រួល និងជំរុញការអនុវត្តគោលនយោបាយ IDP នឹងបន្តសហការកាន់តែជិតស្និទ្ធជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងដៃគូអភិវឌ្ឍន៍ ដើម្បីរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាព ឱ្យទាន់ពេលវេលា និងកាន់តែមានភាពល្អប្រសើរគ្រប់ជ្រុងជ្រោយ។ ទន្ទឹមនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបន្តពង្រឹងការអនុវត្តឱ្យកាន់តែសកម្មចំពោះវិធានការគោលនយោបាយ ដែលសាមីក្រសួង ស្ថាប័នទទួលបន្ទុក ដូចបានកំណត់ក្នុងគោលនយោបាយ IDP។ សម្រាប់ជំហានបន្ទាប់ ក.អ.ក. នឹងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ស្តីពីវឌ្ឍនភាព ឆ្នាំ២០២១-២០២៣ នៃការអនុវត្តគោលនយោបាយ IDP ឱ្យកាន់តែទូលំទូលាយ ក៏ដូចជាដើម្បីជំរុញការអនុវត្តវិធានការដែលនៅសេសសល់សំដៅសម្រេចលទ្ធផលដែលបានកំណត់៕

# បរិសិដ្ឋ

# បរិសិដ្ឋទី១៖

## តារាងសង្ខេបអំពីសមិទ្ធកម្មក្នុងអន្តរាគមន៍គោលនយោបាយ និងការអនុវត្តវិធានការគោលនយោបាយ

I. សមិទ្ធកម្មក្នុងអន្តរាគមន៍គោលនយោបាយ និងការអនុវត្តវិធានការគោលនយោបាយរបស់គោលបំណងគោលនយោបាយទី១ **“បង្កើនសកម្មភាពឧស្សាហកម្ម”**

| **អន្តរាគមន៍គោលនយោបាយទី១.១៖** “បង្កើនតម្រូវការក្នុងស្រុក និងការជំនួសផលិតផលនាំចូល” | | |
|---|---|---|
| **ការអនុវត្ត** | អ.គ. នេះមិនមានវិធានការគោលនយោបាយច្បាស់លាស់ចែងក្នុង IDP | |
| **សមិទ្ធកម្ម** | ១.ផលធៀបរវាងការនាំចូលផលិតផលកម្មន្តសាលធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល | រូបភាពទី១.១   ប្រភពទិន្នន័យ៖ WITS និងក្រសួងផែនការ |

| **អន្តរាគមន៍គោលនយោបាយ ១.២៖** “បង្កើនការវិនិយោគក្នុងវិស័យឧស្សាហកម្ម” | | |
|---|---|---|
| **ការអនុវត្ត** | អ.គ. នេះ មានវិធានការ និងអនុវិធានការសរុបចំនួន ១៧។ ជាវឌ្ឍនភាពនៃការអនុវត្ត ក្នុងឆ្នាំ២០២១-២០២៣ **វិធានការចំនួន ១៤ បានសម្រេចពេញលេញ** កើនឡើង ៤វិធានការ បើធៀបនឹង MTR។ ចំណែក**វិធានការកំពុងអនុវត្តមានចំនួន ២** រីឯ **វិធានការយឺតយ៉ាវ** ក៏ឃើញមានការធ្លាក់ចុះផងដែរពី ៦វិធានការ ក្នុងការវាយតម្លៃពាក់កណ្តាលអាណត្តិ មកនៅត្រឹម **១ វិធានការ** ប៉ុណ្ណោះ។ | |
| **សមិទ្ធកម្ម** | ១.ទំហំទុនវិនិយោគឯកជនក្នុងស្រុកក្នុងវិស័យឧស្សាហកម្ម | រូបភាពទី១.២   ប្រភពទិន្នន័យ៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |

**អន្តរាគមន៍គោលនយោបាយ ១.២៖** “បង្កើនការវិនិយោគក្នុងវិស័យឧស្សាហកម្ម”

**សូចនាករ**

២.រំហូរទុនវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យកម្មន្តសាល

រូបភាពទី១.៣




ប្រភពទិន្នន័យ៖ ធនាគារជាតិនៃកម្ពុជា

៣.ចំណែកនៃការវិនិយោគលើសម្ភារៈបរិក្ខារជាប់បានយូរធៀបនឹងការកកើតទុនអចល័តសរុប

រូបភាពទី១.៤




ប្រភពទិន្នន័យ៖ ក្រសួងផែនការ

**អន្តរាគមន៍គោលនយោបាយ ១.៣៖** “បង្កើនផលិតភាពការងាររបស់សហគ្រាស”

**ការអនុវត្ត**

អ.គ. នេះ មាន**វិធានការចំនួន ១** ប៉ុណ្ណោះ ដែល**កំពុងអនុវត្ត**នៅឡើយ។ បើធៀបនឹង MTR អ.គ. នេះ ពុំមានវឌ្ឍនភាពថ្មីឡើយ។

**សូចនាករ**

១.ផលិតភាពការងារក្នុងវិស័យឧស្សាហកម្ម

រូបភាពទី១.៥




ប្រភពទិន្នន័យ៖ ការគណនារបស់លេខាធិការដ្ឋានផ្អែកលើទិន្នន័យ WDI និង ILO

***កំណត់សម្គាល់៖***

- *សម្រាប់តួលេខតម្លៃបន្ថែមសរុបក្នុងវិស័យឧស្សាហកម្មពីឆ្នាំ២០១៥ តទៅ ត្រូវបានជំនួសដោយតួលេខថ្មីពី WDI ដែលយោងតាមតម្លៃថេរ (Constant Prices) ឆ្នាំ២០១៥*
- *សម្រាប់ទិន្នន័យចំនួនការងារសរុបក្នុងវិស័យឧស្សាហកម្ម របស់ ILO ពីឆ្នាំ២០១៥ ដល់ ២០២១ ត្រូវបានដកស្រង់ចេញពី Household Socio-Economic Survey និង Labour Force Survey។ ដោយឡែក ទិន្នន័យឆ្នាំ២០២២ ដល់២០២៣ គឺជាតួលេខប៉ាន់ស្មានដោយ ILO (ILO-Modelled Estimates)។*

<table>
<tr><th colspan="3">អន្តរាគមន៍គោលនយោបាយ ១.៨៖ “បង្កើនកម្រិតបច្ចេកវិទ្យារបស់សហគ្រាស”</th></tr>
<tr><td>ការអនុវត្ត</td><td colspan="2">អ.គ. នេះ មានវិធានការចំនួន ២ ដោយមានវិធានការ ១ កំពុងអនុវត្ត និងវិធានការ ១ យឺតយ៉ាវ។ បើធៀបនឹង MTR អ.គ. នេះ ពុំមានវឌ្ឍនភាពថ្មីឡើយ។</td></tr>
<tr><td>សមិទ្ធកម្ម</td><td>១.ផលធៀបរវាងការនាំចូលផលិតផលមូលធនធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល</td><td>រូបភាពទី១.៦<br><br><br>ប្រភពទិន្នន័យ៖ ការគណនារបស់លេខាធិការដ្ឋានផ្អែកលើទិន្នន័យ WITS និង WDI</td></tr>
</table>

## II. សមិទ្ធកម្មក្នុងអន្តរាគមន៍គោលនយោបាយ និងការអនុវត្តវិធានការគោលនយោបាយរបស់គោលបំណងគោលនយោបាយទី២ **“បង្កើនការនាំចេញទំនិញឧស្សាហកម្ម និងកសិ-ឧស្សាហកម្ម”**

<table>
<tr><th colspan="3">អន្តរាគមន៍គោលនយោបាយ ២.១៖ “បង្កើនសមត្ថភាពនាំចេញរបស់ក្រុមហ៊ុន/សហគ្រាសធុនតូចនិងមធ្យមក្នុងស្រុក”</th></tr>
<tr><td>ការអនុវត្ត</td><td colspan="2">អ.គ. នេះ មានវិធានការចំនួន ៣ ដែលក្នុងនោះ វិធានការចំនួន ២ ត្រូវបានសម្រេចពេញលេញ កើនឡើង ១វិធានការ បើធៀបនឹង MTR។ ចំណែកឯ វិធានការយឺតយ៉ាវ ធ្លាក់ចុះពី ២វិធានការ មកនៅត្រឹម ១វិធានការ ប៉ុណ្ណោះ។</td></tr>
<tr><td rowspan="2">សមិទ្ធកម្ម</td><td>១.ចំណែកនៃចំនួនសហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យកម្មន្តសាលដែលធ្វើការនាំចេញធៀបនឹងចំនួនសហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យកម្មន្តសាលសរុប</td><td>រូបភាពទី១.៧<br><br><br>ប្រភពទិន្នន័យ៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍</td></tr>
<tr><td>២.ចំណែកនៃការនាំចេញរបស់សហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យកម្មន្តសាលធៀបនឹងការនាំចេញសរុប</td><td>រូបភាពទី១.៨<br><br><br>ប្រភពទិន្នន័យ៖ ការគណនារបស់លេខាធិការដ្ឋានផ្អែកលើទិន្នន័យក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ</td></tr>
</table>

<table>
<tr><th colspan="3">អន្តរាគមន៍គោលនយោបាយ ២.២៖ "ធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងការតភ្ជាប់"</th></tr>
<tr><td>ការអនុវត្ត</td><td colspan="2">អ.គ. នេះ មានវិធានការ និងអនុវិធានការសរុបចំនួន ២៥។ ក្នុងនោះ វិធានការចំនួន ១៤ ត្រូវបានសម្រេចពេញលេញ កើនឡើង ១វិធានការ បើធៀបនឹង MTR។ ចំណែកឯ វិធានការកំពុងអនុវត្ត បានធ្លាក់ចុះពី ៨វិធានការ មកនៅ ៧វិធានការ។ រីឯ វិធានការយឺតយាវ នៅមានចំនួន ៤ ដដែល។</td></tr>
<tr><td rowspan="3">សមិទ្ធកម្ម</td><td rowspan="2">១.បរិមាណទំនិញដឹកជញ្ជូនតាមគ្រប់បណ្តាញគមនាគមន៍</td><td>រូបភាពទី១.៩<br><br><br>ប្រភពទិន្នន័យ៖<br>-ក្រសួងសាធារណការ និងដឹកជញ្ជូន (បរិមាណទំនិញដឹកជញ្ជូនតាមផ្លូវគោក ផ្លូវដែក និងកំពង់ផែ)<br>-រដ្ឋលេខាធិការអាកាសចរណ៍ស៊ីវិល (បរិមាណទំនិញដឹកជញ្ជូនតាមផ្លូវអាកាស)</td></tr>
<tr><td>រូបភាពទី១.១០<br><br><br>ប្រភពទិន្នន័យ៖ ការគណនារបស់លេខាធិការដ្ឋានផ្អែកលើទិន្នន័យក្រសួងសាធារណការ និងដឹកជញ្ជូន និង រដ្ឋលេខាធិការអាកាសចរណ៍ស៊ីវិល</td></tr>
<tr><td>២. ចំនួនច្រកទ្វារព្រំដែនដែលបានបង្កើតនិងដាក់ឱ្យដំណើរការជាផ្លូវការ</td><td>រូបភាពទី១.១១<br><br><br>ប្រភពទិន្នន័យ៖ ក្រសួងមហាផ្ទៃ</td></tr>
</table>

| អន្តរាគមន៍គោលនយោបាយ ២.២៖ “ធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងការតភ្ជាប់” | | |
|---|---|---|
| សូចនាករ | ៣. ចំនួនច្រកទ្វារព្រំដែនដែលបានដំឡើងកម្រិតសមត្ថភាពឱ្យមានភាពស្មើគ្នាជាមួយប្រទេសជិតខាង | រូបភាពទី១.១២<br><br><br>ប្រភពទិន្នន័យ៖ ក្រសួងមហាផ្ទៃ |
| | ៤.អត្រាអ្នកប្រើប្រាស់អ៊ិនធឺណិតល្បឿនលឿន (ក្នុងប្រជាជន ១០០ នាក់) | រូបភាពទី១.១៣<br><br><br>ប្រភពទិន្នន័យ៖ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | ៥. វិសាលភាពគ្របដណ្តប់នៃសេវាអ៊ិនធឺណែតល្បឿនលឿននៅក្នុងតំបន់ដែលមានប្រជាជនរស់នៅ | រូបភាពទី១.១៤<br><br><br>ប្រភពទិន្នន័យ៖ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | ៦.សន្ទស្សន៍ភូមិដែលទទួលបានការផ្គត់ផ្គង់អគ្គិសនី | រូបភាពទី១.១៥<br><br><br>ប្រភពទិន្នន័យ៖ ក្រសួងរ៉ែ និងថាមពល, អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា |

| អន្តរាគមន៍គោលនយោបាយ ២.២៖ “ធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងការតភ្ជាប់” | | |
|---|---|---|
| | ៧. ការដាច់ចរន្តអគ្គិសនីនៅតំបន់សេដ្ឋកិច្ចពិសេស | រូបភាពទី១.១៦<br><br>ប្រភពទិន្នន័យ៖ ក្រសួងរ៉ែ និងថាមពល, អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា<br><br>រូបភាពទី១.១៧<br><br>ប្រភពទិន្នន័យ៖ ក្រសួងរ៉ែ និងថាមពល, អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា |
| **សមិទ្ធផល** | ៨. ថ្លៃអគ្គិសនីដែលទិញពីទ្វារចរន្តអនុស្ថានីយ | រូបភាពទី១.១៨<br><br>ប្រភពទិន្នន័យ៖ ក្រសួងរ៉ែ និងថាមពល, អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា<br><br>***កំណត់សម្គាល់៖*** *នៅឆ្នាំ២០១៩ និងឆ្នាំ២០២៣ ថ្លៃទិញពីអនុស្ថានីយមានភាពប្រែប្រួលរវាងរាជធានីភ្នំពេញ និងខេត្ត។ តម្លៃចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ ដែលបង្ហាញក្នុងរូបភាពខាងលើ គឺសម្រាប់នៅតាមបណ្តាខេត្ត។ តម្លៃនៅរាជធានីភ្នំពេញគឺ ១៣,៥សេន/១គីឡូវ៉ាត់ម៉ោង នៅឆ្នាំ២០១៩ និងចាប់ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២៣ គឺ ១៣,២សេន/១គីឡូវ៉ាត់ម៉ោង ដែលមានតម្លៃថ្លៃជាងនៅតាមបណ្តាខេត្ត ដោយសារការបន្ថែមថ្លៃពីអ្នកផលិតអគ្គិសនីឯកជន ដើម្បីរក្សាការផ្គត់ផ្គង់អគ្គិសនីឱ្យមានស្ថិរភាពនៅក្នុងរាជធានីភ្នំពេញ។ នៅពេលដែលមិនមានថាមពលគ្រប់គ្រាន់ពីបណ្តាញអគ្គិសនីជាតិ, អ្នកផលិតអគ្គិសនីឯកជននឹងបំពេញបន្ថែមនូវកង្វះថាមពលដើម្បីផ្គត់ផ្គង់ដល់រាជធានីភ្នំពេញ។* |

**អន្តរាគមន៍គោលនយោបាយ ២.២៖** "ធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងការតភ្ជាប់"

៩. ថ្លៃអគ្គិសនីដែលទិញពីខ្សែមេប្រព័ន្ធភ្នំពេញ និងកណ្តាល

រូបភាពទី១.១៩




ប្រភពទិន្នន័យ៖ ក្រសួងរ៉ែ និងថាមពល, អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា

១០. ថ្លៃអគ្គិសនីដែលទិញពីខ្សែមេនៅតាមខេត្ត

រូបភាពទី១.២០




ប្រភពទិន្នន័យ៖ ក្រសួងរ៉ែ និងថាមពល, អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា

## III. សមិទ្ធកម្មក្នុងអន្តរាគមន៍គោលនយោបាយនិងការអនុវត្តវិធានការគោលនយោបាយរបស់គោលបំណងគោលនយោបាយទី៣ **"សេដ្ឋកិច្ចដែលមានភាពធន់និងមានពិពិធកម្ម"**

**អន្តរាគមន៍គោលនយោបាយ ៣.១៖** "បង្កើនសកម្មភាពឧស្សាហកម្មថ្មីៗ"

**ការអនុវត្ត**

អ.គ. នេះ មានវិធានការ សរុបចំនួន ៤។ សម្រាប់ការអនុវត្ត ក្នុងឆ្នាំ២០២១-២០២៣ **វិធានការចំនួន ៣ ត្រូវបានសម្រេចពេញលេញ**, និង**វិធានការកំពុងអនុវត្ត ចំនួន ១**។ បើធៀបនឹង MTR វិធានការសម្រេចពេញលេញ កើនឡើង ចំនួន ១ និងពុំមានវិធានការយឺតយ៉ាវឡើយ។

**សមិទ្ធកម្ម**

១. ចំនួនក្រុមហ៊ុន និងសហគ្រាសកម្មន្តសាលថ្មីដែលបានចុះបញ្ជី

រូបភាពទី១.២១




ប្រភពទិន្នន័យ៖ ក្រសួងពាណិជ្ជកម្ម

| អន្តរាគមន៍គោលនយោបាយ ៣.១៖ “បង្កើនសកម្មភាពឧស្សាហកម្មថ្មីៗ” | | |
|---|---|---|
| | ២. ចំនួនមុខទំនិញនាំចេញ | រូបភាពទី១.២២<br><br><br>ប្រភពទិន្នន័យ៖ WITS<br>***កំណត់សម្គាល់៖*** *ទោះបីក្រុមការងារលេខាធិការដ្ឋានប្រើប្រាស់វិធីសាស្ត្រក្នុងការទាញយកទិន្នន័យពីប្រភព WITS ដដែល ទិន្នន័យខាងលើខុសពីទិន្នន័យមានក្នុង MTR។* |
| | ៣. ចំនួនមុខទំនិញកម្មន្តសាលនាំចេញ | រូបភាពទី១.២៣<br><br><br>ប្រភពទិន្នន័យ៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |

| អន្តរាគមន៍គោលនយោបាយ ៣.២៖ “ពង្រីក និងធ្វើពិពិធកម្មទីផ្សារ និងផលិតផលនាំចេញ” | | |
|---|---|---|
| **ការអនុវត្ត** | អ.គ. នេះ មានវិធានការ និងអនុវិធានការសរុបចំនួន ៩ ដែលក្នុងនោះ **វិធានការទាំងអស់បានសម្រេចពេញលេញ** ក្នុងឆ្នាំ២០២១-២០២៣ ដែលជាវឌ្ឍនភាពដ៏ល្អប្រសើរ ដោយវិធានការកំពុងអនុវត្ត ចំនួន ១ និងយឺតយ៉ាវ ចំនួន ២ ដូចបានវាយតម្លៃក្នុង MTR បានសម្រេចពេញលេញទាំងអស់។ | |
| **សូចនាករ** | ១. ចំណែកនៃការនាំចេញផលិតផលកម្មន្តសាលសំខាន់ៗ៥នាំមុខគេ ធៀបនឹងការនាំចេញផលិតផលកម្មន្តសាលសរុប | រូបភាពទី១.២៤<br><br><br>ប្រភពទិន្នន័យ៖ WITS |

បរិបទទី១

**អន្តរាគមន៍គោលនយោបាយ ៣.២៖** “ពង្រីក និងធ្វើពិពិធកម្មទីផ្សារ និងផលិតផលនាំចេញ”

២.ចំណែកនៃការនាំចេញផលិតផលកម្មន្តសាលទៅទីផ្សារសំខាន់ ៣នាំមុខគេធៀបនឹងការនាំចេញផលិតផលកម្មន្តសាលសរុប

រូបភាពទី១.២៥




ប្រភពទិន្នន័យ៖ WITS

៣.ចំនួនទីផ្សារនាំចេញដែលមានទំហំលើសពី ១០លានដុល្លារអាម៉េរិក

រូបភាពទី១.២៦




ប្រភពទិន្នន័យ៖ WITS

**អន្តរាគមន៍គោលនយោបាយ ៣.៣៖** “ធ្វើឱ្យមានតុល្យភាពរវាងសហគ្រាសធុនធំ និងសហគ្រាសធុនតូច និងមធ្យម”

**ការអនុវត្ត**

ក្នុង អ.គ. នេះ មានវិធានការ និងអនុវិធានការសរុបចំនួន ៤។ **វិធានការចំនួន ២ ត្រូវបានសម្រេចពេញលេញ, វិធានការចំនួន ២** ទៀតរៀងគ្នា **កំពុងអនុវត្ត** និង**យឺតយ៉ាវ** ។ ក្នុងឆ្នាំ២០២១-២០២៣ ពុំមានវឌ្ឍនភាពឡើយ បើធៀបនឹង MTR។

**សមិទ្ធកម្ម**

១.ចំណែកនៃចំនួនការងារដែលផ្ដល់ដោយសហគ្រាសធុនតូចនិងមធ្យមធៀបនឹងចំនួនការងារសរុបក្នុងវិស័យឧស្សាហកម្ម

រូបភាពទី១.២៧




ប្រភពទិន្នន័យ៖ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

<table>
<tr><th colspan="3">អន្តរាគមន៍គោលនយោបាយ ៣.៨៖ “បង្កើននវានុវត្តន៍ផ្នែកឧស្សាហកម្ម”</th></tr>
<tr><td>ការអនុវត្ត</td><td colspan="2">អ.គ. នេះ មានវិធានការ និងអនុវិធានការ ចំនួន ១៧ ក្នុងនោះ វិធានការចំនួន៤ ត្រូវបានសម្រេចពេញលេញ, វិធានការចំនួន ៩ កំពុងអនុវត្ត និងវិធានការចំនួន៤ ទៀត យឺតយ៉ាវ នៅឡើយ។ សូមកត់សម្គាល់ផងដែរថា ក្នុង MTR វិធានការ និងអនុវិធានការ ចំនួន ១៦ ប៉ុណ្ណោះ ត្រូវបានវាយតម្លៃ ដោយសារវិធានការមួយ ("ជំរុញការរៀបចំនូវក្របខណ្ឌគោលនយោបាយ...វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍" ឧបសម្ព័ន្ធ ទំព័រទី១៤ នៃឯកសារគោលនយោបាយ IDP) ពុំមានព័ត៌មានសម្រាប់ការវាយតម្លៃ។ ដោយវិធានការមួយនេះ មានព័ត៌មានគ្រប់គ្រាន់ សម្រាប់ការតាមដានឆ្នាំ២០២១-២០២៣ ទើបវិធានការនេះត្រូវបានបញ្ចូលក្នុងអ.គ. នេះ។ ជាវឌ្ឍនភាព វិធានការនេះ កំពុងអនុវត្តនៅឡើយ ដោយឡែកចំពោះវិធានការដទៃទៀត ពុំមានវឌ្ឍនភាពថ្មីឡើយ។</td></tr>
<tr><td rowspan="2">សមិទ្ធកម្ម</td><td>១.ចំនួនសំណើនៃការដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្ម</td><td>រូបភាពទី១.២៨<br><br>ប្រភពទិន្នន័យ៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍</td></tr>
<tr><td>២.ចំនួនប្រកាសនីយបត្រតក្កកម្មផ្តល់ជូនសរុប</td><td>រូបភាពទី១.២៩<br><br>ប្រភពទិន្នន័យ៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍</td></tr>
</table>

<table>
<tr><th colspan="3">អន្តរាគមន៍គោលនយោបាយ ៣.៨៖ “ធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម”</th></tr>
<tr><td>ការអនុវត្ត</td><td colspan="2">អ.គ. នេះ មានវិធានការ ចំនួន ៩។ ជាវឌ្ឍនភាព វិធានការចំនួន៧ ត្រូវបានសម្រេចពេញលេញ ដោយមានការកើនឡើងចំនួន ៥ វិធានការ, និងវិធានការយឺតយ៉ាវ ចំនួន២ ថយចុះចំនួន ៤ វិធានការ ធៀបនឹង MTR។</td></tr>
<tr><td rowspan="3">សមិទ្ធកម្ម</td><td>១. អត្រាចុះបញ្ជីសហគ្រាសធុនតូច</td><td>រូបភាពទី១.៣០<br><br><br>ប្រភពទិន្នន័យ៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍</td></tr>
<tr><td>២. អត្រាចុះបញ្ជីសហគ្រាសធុនមធ្យម</td><td>រូបភាពទី១.៣១<br><br><br>ប្រភពទិន្នន័យ៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍</td></tr>
<tr><td>៣. អត្រាចុះបញ្ជីសហគ្រាសធុនធំ</td><td>រូបភាពទី១.៣២<br><br><br>ប្រភពទិន្នន័យ៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍</td></tr>
</table>

<table>
<tr><th colspan="3">អន្តរាគមន៍គោលនយោបាយ ៣.៥៖ “ធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម”</th></tr>
<tr><td></td><td>៤. អត្រាសហគ្រាសធុនតូចដែលកាន់បញ្ជីគណនេយ្យសាមញ្ញ</td><td>រូបភាពទី១.៣៣




ប្រភពទិន្នន័យ៖ អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ</td></tr>
<tr><td></td><td>៥. អត្រាសហគ្រាសធុនមធ្យមដែលមានតារាងតុល្យការ</td><td>រូបភាពទី១.៣៤




ប្រភពទិន្នន័យ៖ អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ</td></tr>
<tr><td></td><td>៦.អត្រាសហគ្រាសធុនធំដែលមានតារាងតុល្យការ</td><td>រូបភាពទី១.៣៥




ប្រភពទិន្នន័យ៖ អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ</td></tr>
</table>

## IV. សមិទ្ធកម្មក្នុងអន្តរាគមន៍គោលនយោបាយនិងការអនុវត្តវិធានការគោលនយោបាយរបស់គោលបំណងគោលនយោបាយទី៨ “ធ្វើឱ្យប្រសើរឡើងនូវគុណភាពការងារ”

<table>
<tr><th colspan="3">អន្តរាគមន៍គោលនយោបាយ ៨.១៖ “ធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍជំនាញនិងធនធានមនុស្ស”</th></tr>
<tr><td>ការអនុវត្ត</td><td colspan="2">វិធានការគោលនយោបាយទាំង១៦ និងអនុវិធានការចំនួន១ បានសម្រេចពេញលេញ តាំងពីMTR ។</td></tr>
<tr><td>សមិទ្ធកម្ម</td><td>១. ចំណែកនៃការចុះឈ្មោះចូលរៀននៅមធ្យមសិក្សា និងឧត្តមសិក្សា ក្នុងចំនួនប្រជាជនគ្រប់អាយុចូលរៀន</td><td>រូបភាពទី១.៣៦<br><br>ប្រភពទិន្នន័យ៖ ក្រសួងអប់រំ យុវជន និងកីឡា</td></tr>
<tr><td>សមិទ្ធកម្ម</td><td>២. អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ</td><td>រូបភាពទី១.៣៧<br><br>ប្រភពទិន្នន័យ៖ ក្រសួងអប់រំ យុវជន និងកីឡា</td></tr>
<tr><td></td><td>៣. អត្រានិស្សិតបញ្ចប់ការសិក្សាផ្នែក STEM</td><td>រូបភាពទី១.៣៨<br><br>ប្រភពទិន្នន័យ៖ ក្រសួងអប់រំ យុវជន និងកីឡា</td></tr>
</table>

## អន្តរាគមន៍គោលនយោបាយ ៨.១៖ "ធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍជំនាញនិងធនធានមនុស្ស"

៤. ចំនួនសិស្សនិស្សិតបញ្ចប់ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈដែលមានសញ្ញាបត្រ

រូបភាពទី១.៣៩




ប្រភពទិន្នន័យ៖ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

## អន្តរាគមន៍គោលនយោបាយ ៨.២៖ "បង្កើនតម្រូវការកម្លាំងពលកម្មជំនាញ"

**ការអនុវត្ត**

មិនមានវិធានការគោលនយោបាយច្បាស់លាស់ចែងក្នុង IDP។

**សមិទ្ធកម្ម**

១. ចំនួនព័ត៌មានតម្រូវការជ្រើសរើសកម្លាំងពលកម្មជំនាញ

រូបភាពទី១.៤០




ប្រភពទិន្នន័យ៖ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

២. ចំនួនកម្លាំងពលកម្មជំនាញ

រូបភាពទី១.៤១




ប្រភពទិន្នន័យ៖ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

***កំណត់សម្គាល់៖*** *កម្លាំងពលកម្មជំនាញសំដៅដល់អ្នកដែលទទួលបានការអប់រំ និងការបណ្ដុះបណ្ដាលយ៉ាងតិច ឬស្មើកម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬអ្នកដែលទទួលបានការអប់រំបណ្ដុះបណ្ដាល បច្ចេកទេស និងវិជ្ជាជីវៈយ៉ាងតិច ឬស្មើសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១ (C1)។*

| អន្តរាគមន៍គោលនយោបាយ ៨.៣៖ "ធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ" | | |
|---|---|---|
| **ការអនុវត្ត** | អ.គ. នេះមានវិធានការ និងអនុវិធានការចំនួន៦ ដែល**បានសម្រេចពេញលេញទាំងអស់** ក្នុងឆ្នាំ២០២១-២០២៣។ | |
| **សមិទ្ធកម្ម** | ១. ប្រាក់ឈ្នួលអប្បបរមា | រូបភាពទី១.៤២<br><br>ប្រភពទិន្នន័យ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| | ២. ភាគរយនៃវិវាទការងារ (ធំៗ) ដែលបានដោះស្រាយ | រូបភាពទី១.៤៣<br><br>ប្រភពទិន្នន័យ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |





| អន្តរាគមន៍គោលនយោបាយ ៨.៤៖ "ធ្វើឱ្យប្រសើរឡើងនូវការផ្គូផ្គងការងារ" | | |
|---|---|---|
| **ការអនុវត្ត** | សម្រាប់ អ.គ. នេះ មានវិធានការ និងអនុវិធានការសរុប ចំនួន៤។ ក្នុង MTR វិធានការទាំង៤នេះ ត្រូវបានវាយតម្លៃថា "សម្រេចបានពេញលេញ"។ ដោយឡែក នៅពេលដែលក្រុមការងារបច្ចេកទេសបានផ្ទៀងផ្ទាត់ព័ត៌មានឡើងវិញ សម្រាប់ការតាមដានការអនុវត្តក្នុងឆ្នាំ ២០២១-២០២៣ មាន**វិធានការចំនួន ៣ បានសម្រេចពេញលេញ** និង**វិធានការចំនួន ១ នៅយឺតយ៉ាវ** [១] នៅឡើយ។ | |
| **សមិទ្ធកម្ម** | ១. អត្រាសហគ្រាសក្នុងស្រុកដែលជួបប្រទះបញ្ហាគម្លាតជំនាញ និងចំណែកនៃសហគ្រាសដែលពិបាកជ្រើសរើសកម្លាំងពលកម្ម | រូបភាពទី១.៤៤<br><br>ប្រភពទិន្នន័យ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |



[១] វិធានការ "ពង្រឹងយន្តការគ្រប់គ្រងកម្មករជំនាញ ជាពិសេសត្រៀមលក្ខណៈឱ្យបានល្អប្រសើរសម្រាប់សមាហរណកម្មអាស៊ាន" (ឧបសម្ព័ន្ធ ឃ, ទំព័រ ១៦) ដែលមានកាលបរិច្ឆេទគោលដៅក្នុងឆ្នាំ២០២០ (ដូចមានចែងក្នុងគោលនយោបាយ IDP)។ តាមការផ្ទៀងផ្ទាត់ព័ត៌មានដែលបានរាយការណ៍ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលជាក្រសួងទទួលបន្ទុកដឹកនាំអនុវត្តវិធានការនេះ ក្នុងឆ្នាំ២០២១-២០២៣ វិធានការនេះ នៅពុំទាន់សម្រេចបានពេញលេញនៅឡើយ។

<table>
<tr><th colspan="3">អន្តរាគមន៍គោលនយោបាយ ៨.៨៖ “ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ”</th></tr>
<tr><td>ការអនុវត្ត</td><td colspan="2">សម្រាប់ អ.គ. នេះ មានវិធានការ និងអនុវិធានការចំនួន៦។ ជាវឌ្ឍនភាពសម្រាប់ឆ្នាំ២០២១-២០២៣ វិធានការចំនួន៥ បានសម្រេចពេញលេញ កើនឡើង ១វិធានការ, ចំណែកឯ វិធានការកំពុងអនុវត្ត មានចំនួន១ បើធៀបនឹង MTR។</td></tr>
<tr><td rowspan="2">សមិទ្ធកម្ម</td><td>១. អត្រាសហគ្រាស គ្រឹះស្ថាន ដែលមានសេវាសង្គ្រោះបឋម</td><td>រូបភាពទី១.៨៥<br><br><br>ប្រភពទិន្នន័យ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ</td></tr>
<tr><td>២. ចំនួនកម្មករនិយោជិត ដែលទទួលបានបណ្ណសមាជិកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.)</td><td>រូបភាពទី១.៨៦<br><br><br>ប្រភពទិន្នន័យ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>កំណត់សម្គាល់៖ ទិន្នន័យចំនួនកម្មករនិយោជិតវិស័យឯកជនដែលទទួលបាន ប.ស.ស. ត្រូវបានធ្វើបច្ចុប្បន្នភាពចាប់ពីឆ្នាំ ២០១៥ ដោយប្រើប្រាស់ទិន្នន័យសមាជិកបច្ចុប្បន្នភាព ឬក្នុងសុពលភាពដោយមិនរាប់បញ្ចូលបុគ្គលស្វ័យនិយោជន៍ អ្នកក្នុងបន្ទុកសមាជិក ប.ស.ស. និងមន្ត្រីរាជការសាធារណៈ។</td></tr>
</table>

## V. សមិទ្ធកម្មក្នុងអន្តរាគមន៍គោលនយោបាយ និងការអនុវត្តវិធានការគោលនយោបាយរបស់គោលបំណងគោលនយោបាយទី៥ **"បង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមា"**

| **អន្តរាគមន៍គោលនយោបាយ ៥.១៖**<br>"បង្កើនការតភ្ជាប់រវាងសហគ្រាសក្នុងស្រុក ជាមួយសហគ្រាសបរទេស រួមទាំងការផ្ទេរបច្ចេកវិទ្យា" | | |
|---|---|---|
| **ការអនុវត្ត** | សម្រាប់ អ.គ. នេះ មានវិធានការចំនួន៣ ដោយមាន **វិធានការចំនួន១ បានសម្រេចពេញលេញ** និង**វិធានការចំនួន២ កំពុងអនុវត្ត**។ បើធៀបនឹង MTR អ.គ. នេះ ពុំមានវឌ្ឍនភាពថ្មីឡើយ។ | |
| **សមិទ្ធកម្ម** | ១. ចំនួនសហគ្រាសក្នុងស្រុកដែលផ្គត់ផ្គង់ធាតុចូលផលិតកម្មសម្រាប់សហគ្រាសបរទេស | លទ្ធផលអន្តរាគមន៍គោលនយោបាយនេះ មានសូចនាករមួយប៉ុណ្ណោះសម្រាប់វាស់វែងលទ្ធផលគឺ ចំនួនសហគ្រាសក្នុងស្រុកដែលផ្គត់ផ្គង់ធាតុចូលផលិតកម្មសម្រាប់សហគ្រាសបរទេស។ មកដល់ពេលនេះ ពុំទាន់មានការធ្វើអង្កេតសហគ្រាសឧស្សាហកម្មណាមួយនៅកម្ពុជា ដែលអាចផ្តល់ទិន្នន័យពាក់ព័ន្ធនឹងសូចនាករមួយនេះនៅឡើយទេ។ យ៉ាងណាក្តី ការស្ទង់មតិលើលក្ខខណ្ឌធុរកិច្ចរបស់ក្រុមហ៊ុនជប៉ុន ដែលកំពុងធ្វើប្រតិបត្តិការនៅក្រៅប្រទេស (អាស៊ី និងអូសេអានី) ឆ្នាំ២០២១ និង២០២២ ដែលរៀបចំឡើងដោយអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន បានបង្ហាញថាក្រុមហ៊ុនជប៉ុននៅកម្ពុជា បានប្រើប្រាស់វត្ថុធាតុដើម និងគ្រឿងបង្គុំក្នុងស្រុកតិចជាង១០% ប៉ុណ្ណោះ ខណៈដែលវត្ថុធាតុដើមជាង ៩០%ទៀត ត្រូវបាននាំចូលពីបរទេស។ |

| **អន្តរាគមន៍គោលនយោបាយ ៥.២៖** "ពង្រឹងខ្សែច្រវាក់តម្លៃក្នុងស្រុក" | | |
|---|---|---|
| **ការអនុវត្ត** | មិនមានវិធានការគោលនយោបាយច្បាស់លាស់ចែងក្នុង IDP។ | |
| **សមិទ្ធកម្ម** | ១. ចំណែកនៃតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាលធៀបនឹងការនាំចេញផលិតផលកម្មន្តសាលសរុប | រូបភាពទី១.៤៧<br><br><br>ប្រភពទិន្នន័យ៖ ការគណនារបស់លេខាធិការដ្ឋានផ្អែកលើទិន្នន័យក្រសួងផែនការ និង WITS |

| អន្តរាគមន៍គោលនយោបាយ ៥.៣៖ “បង្កើនភាពជាម្ចាស់របស់ក្រុមហ៊ុន និងសហគ្រាសក្នុងស្រុក” | | |
|---|---|---|
| **ការអនុវត្ត** | មិនមានវិធានការគោលនយោបាយច្បាស់លាស់ចែងក្នុង IDP។ | |
| **សមិទ្ធកម្ម** | ១. ចំណែកនៃចំនួនគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមានម្ចាស់ភាគហ៊ុនខ្មែរកាន់កាប់ចាប់ពី ៥១% ឡើងទៅ ធៀបនឹងចំនួនគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សរុប | រូបភាពទី១.៤៨   ប្រភពទិន្នន័យ៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| | ២. ចំណែកនៃចំនួនការងារសរុបដែលបានបង្កើតដោយសហគ្រាសបរទេសធៀបនឹងចំនួនការងារសរុប | រូបភាពទី១.៤៩   ប្រភពទិន្នន័យ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |

| អន្តរាគមន៍គោលនយោបាយ ៥.៤៖ “បង្កើនការកែច្នៃផលិតផលកសិកម្មសម្រាប់ផ្គត់ផ្គង់ក្នុងស្រុកនិងនាំចេញ” | | |
|---|---|---|
| **ការអនុវត្ត** | សម្រាប់ អ.គ. នេះ មានវិធានការចំនួន៥ ដោយមាន **វិធានការចំនួន៣ បានសម្រេចពេញលេញ, វិធានការកំពុងអនុវត្ត ចំនួន ១** និង**វិធានការយឺតយ៉ាវចំនួន ១ ថយចុះ ១** បើធៀបនឹង MTR **ដោយបានផ្លាស់ប្តូរជាវិធានការកំពុងអនុវត្តវិញ** ។ | |
| **សមិទ្ធកម្ម** | ១. ទំហំនាំចេញនៃកសិផលកែច្នៃ | រូបភាពទី១.៥០   ប្រភពទិន្នន័យ៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |

## កំណត់សម្គាល់

❖ **សូចនាករគន្លឹះកម្រិតវិស័យមួយចំនួន មានតួលេខទិន្នន័យ ប្រែប្រួលខុសពីទិន្នន័យមានក្នុង MTR ដោយសារៈ**

### ១. ការផ្លាស់ប្តូរឆ្នាំគោល

– តួលេខតម្លៃបន្ថែមសរុបក្នុងវិស័យឧស្សាហកម្មមានប្រភពពី *WDI* ត្រូវបានផ្លាស់ប្តូរដោយតួលេខថ្មី ដែលយោងតាមតម្លៃថេរ (Constant Prices) ឆ្នាំ២០១៥។ ការណ៍នេះនាំឱ្យសូចនាករចំនួន២ មានការប្រែប្រួលខុសពីទិន្នន័យមានក្នុង MTR ក្នុងនោះរួមមាន៖

| | |
|---|---|
| ១.៣.១. | ផលិតភាពការងារក្នុងវិស័យឧស្សាហកម្ម<br>(ប្រភពទិន្នន័យ៖ *ការគណនារបស់លេខាធិការដ្ឋានផ្អែកលើទិន្នន័យ WDI និង ILO*) |
| ១.៤.១. | ផលធៀបរវាងការនាំចូលផលិតផលមូលធន ធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល<br>(ប្រភពទិន្នន័យ៖ *ការគណនារបស់លេខាធិការដ្ឋានផ្អែកលើទិន្នន័យ WITS និង WDI*) |

– តួលេខទិន្នន័យសូចនាករមានប្រភពមកពី *ក្រសួងផែនការ* ត្រូវបានផ្លាស់ប្តូរដោយតួលេខថ្មី ដែលយោងតាមតម្លៃថេរឆ្នាំ២០១៤។ ការណ៍នេះនាំឱ្យសូចនាករចំនួន៣ មានការប្រែប្រួលខុសពីទិន្នន័យមានក្នុង MTR ក្នុងនោះរួមមាន៖

| | |
|---|---|
| ១.១.១. | ផលធៀបរវាងការនាំចូលផលិតផលកម្មន្តសាល ធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល<br>*(ប្រភពទិន្នន័យ៖ ការគណនារបស់លេខាធិការដ្ឋានផ្អែកលើទិន្នន័យ WITS និង ក្រសួងផែនការ)* |
| ១.២.៣. | ចំណែកនៃការវិនិយោគលើសម្ភារៈបរិក្ខារជាប់បានយូរ ធៀបនឹងការកកើតទុនអចល័តសរុប<br>*(ប្រភពទិន្នន័យ៖ ក្រសួងផែនការ)* |
| ៥.២.១. | ចំណែកនៃតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល ធៀបនឹងការនាំចេញផលិតផលកម្មន្តសាលសរុប<br>*(ប្រភពទិន្នន័យ៖ ការគណនារបស់លេខាធិការដ្ឋានផ្អែកលើទិន្នន័យ ក្រសួងផែនការ និង WITS)* |

### ២. សំណើផ្លាស់ប្តូរតួលេខទិន្នន័យដោយក្រសួង ស្ថាប័នសាមី

– ទិន្នន័យសូចនាករចំនួន៦ មានការប្រែប្រួលខុសពីទិន្នន័យមានក្នុង MTR ដោយសារក្រសួង ស្ថាប័នចំនួន៥ បានស្នើកែប្រែទិន្នន័យ ក្នុងនោះរួមមាន៖

| | |
|---|---|
| ១.២.២. | លំហូរទុនវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យកម្មន្តសាល<br>(ប្រភពទិន្នន័យ៖ *ធនាគារជាតិនៃកម្ពុជា*) |
| ២.២.១. | បរិមាណទំនិញដឹកជញ្ជូនតាមផ្លូវគោក<br>(ប្រភពទិន្នន័យ៖ *ក្រសួងសាធារណការ និងដឹកជញ្ជូន*) |
| ២.២.២. | ចំនួនច្រកទ្វារព្រំដែនដែលបានបង្កើត និងដាក់ឱ្យដំណើរការជាផ្លូវការ<br>(ប្រភពទិន្នន័យ៖ *ក្រសួងមហាផ្ទៃ*) |
| ៣.៤.១. | ចំនួនសំណើនៃការដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្មសរុប<br>(ប្រភពទិន្នន័យ៖ *ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍*) |
| ៣.៤.២. | ចំនួនប្រកាសនីយបត្រតក្កកម្មផ្តល់ជូនសរុប<br>(ប្រភពទិន្នន័យ៖ *ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍*) |
| ៤.១.១. | ចំណែកនៃការចុះឈ្មោះចូលរៀននៅមធ្យមសិក្សា និងឧត្តមសិក្សាក្នុងចំនួនប្រជាជនគ្រប់អាយុចូលរៀន<br>(ប្រភពទិន្នន័យ៖ *ក្រសួងអប់រំ យុវជន និងកីឡា*) |
| ៤.១.២. | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ<br>(ប្រភពទិន្នន័យ៖ *ក្រសួងអប់រំ យុវជន និងកីឡា*) |
| ៤.៥.២. | ចំនួនកម្មករនិយោជិតដែលទទួលបានបណ្ណសមាជិកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.)<br>*(ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)* |
| ៥.៣.១. | ចំណែកនៃចំនួនគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលមានម្ចាស់ភាគហ៊ុនខ្មែរកាន់កាប់ចាប់ពី៥១% ឡើងទៅ ធៀបនឹងចំនួនគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់សរុប<br>(ប្រភពទិន្នន័យ៖ *ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*) |

❖ សូចនាករគន្លឹះកម្រិតវិស័យដែលខ្វះតួលេខទិន្នន័យឆ្នាំ២០២៣ រួមមាន៖

| ល.រ. | សូចនាករខ្វះតួលេខទិន្នន័យ ឆ្នាំ២០២៣ | | ប្រភពទិន្នន័យ |
|---|---|---|---|
| ១ | ៤.៤.១. | អត្រាសហគ្រាសក្នុងស្រុកដែលជួបបញ្ហាគម្លាតជំនាញ | *ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ* |
| ២ | ៤.៤.១. | ចំណែកនៃសហគ្រាសដែលពិបាកជ្រើសរើសកម្លាំងពលកម្ម | *ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ* |
| ៣ | ៥.១.១. | ចំនួនសហគ្រាសក្នុងស្រុកដែលផ្គត់ផ្គង់ធាតុចូលផលិតកម្មសម្រាប់សហគ្រាសបរទេស | *N/A* |

# បរិសិដ្ឋទី២៖

## រូបភាពបង្ហាញអំពីវឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយ ក្នុងឆ្នាំ២០២១-២០២៣ តាមគោលបំណងគោលនយោបាយ

រូបភាពទី២.១៖ ការតាមដានវឌ្ឍនភាពនៃការអនុវត្តវិធានការ តាមគោលបំណងគោលនយោបាយក្នុងឆ្នាំ២០២១-២០២៣




*វិធានការ និងអនុវិធានការ ចំនួន ៧ ពុំត្រូវបានចាត់ចូលក្នុងគោលបំណងគោលនយោបាយណាមួយឡើយ ដោយសារតែវិធានការទាំងនេះ ត្រូវបានកំណត់ជាវិធានការទូទៅ ដែលអាចជះផលដល់គោលបំណងទាំងអស់។ វិធានការទាំងនេះពាក់ព័ន្ធនឹងរដ្ឋបាលសារពើពន្ធទូទៅ, ការលើកកម្ពស់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីវិនិយោគសាធារណៈសម្រាប់ការអភិវឌ្ឍឧស្សាហកម្ម និងការពង្រឹងការតាមដានការអនុវត្តគម្រោងវិនិយោគ។

រូបភាពទី២.២៖ ការប្រៀបធៀបលើវឌ្ឍនភាពនៃការអនុវត្តវិធានការតាមគោលបំណងគោលនយោបាយ




*ក្នុងការវាយតម្លៃពាក់កណ្ដាលអាណត្តិ វិធានការចំនួន ១ ដែលស្ថិតក្នុងគោលបំណងទី៣ ពុំមានព័ត៌មានវឌ្ឍនភាព គឺ "ជំរុញការរៀបចំនូវក្របខ័ណ្ឌគោលនយោបាយ និងយន្តការអភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍" ហើយដែលយោងតាមឯកសារគោលនយោបាយ IDP ស្ថិតនៅក្រោមក្រសួងផែនការ។ ដោយឡែកសម្រាប់ការតាមដាន ក្នុងឆ្នាំ ២០២១-២០២៣ វិធានការមួយនេះ មានព័ត៌មានវឌ្ឍនភាពគ្រប់គ្រាន់ ព្រមទាំងត្រូវបានផ្ទេរមក ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីរាយការណ៍វិញ។

**វិធានការ និងអនុវិធានការ ចំនួន ៧ ពុំត្រូវបានចាត់ចូលក្នុងគោលបំណងគោលនយោបាយណាមួយឡើយ ដោយសារតែវិធានការទាំងនេះ ត្រូវបានកំណត់ជាវិធានការទូទៅ ដែលអាចជះផលដល់គោលបំណងទាំងអស់។ វិធានការទាំងនេះពាក់ព័ន្ធនឹងរដ្ឋបាលសារពើពន្ធទូទៅ, ការលើកកម្ពស់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីវិនិយោគសាធារណៈសម្រាប់ការអភិវឌ្ឍឧស្សាហកម្ម និងការពង្រឹងការតាមដានការអនុវត្តគម្រោងវិនិយោគ។

# បរិសិដ្ឋទី៣៖ ម៉ាទ្រីសវិធានការឃើតយ៉ាវ

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| **១. បង្កើនសកម្មភាពឧស្សាហកម្ម** | | |
| ១.២. បង្កើនការវិនិយោគក្នុងវិស័យឧស្សាហកម្ម (១៩) | ១.២.៩. ជំរុញការបង្កើតកម្រងឧស្សាហកម្ម និងសួនឧស្សាហកម្មធំៗ តាមរយៈការអនុម័ត "ច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស" សំដៅអភិវឌ្ឍតំបន់ទាំងនោះឱ្យឈានដល់កម្រិតស្តង់ដារអន្តរជាតិលើគ្រប់ទិដ្ឋភាព រួមមាន ប្រព័ន្ធគ្រប់គ្រងមូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធ ការផ្គត់ផ្គង់អគ្គិសនី ទឹកស្អាត វត្ថុធាតុដើម និងធាតុចូលផ្សេងៗ កិច្ចសម្រួលការដឹកជញ្ជូន និងពាណិជ្ជកម្ម ព្រមទាំងការលើកទឹកចិត្ត និងវិធានការគាំទ្រជាក់ស្តែងផ្សេងទៀត ដើម្បីជំរុញការវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស (ឧបសម្ព័ន្ធ ឃ, ទំព័រទី៣) | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| ១.៤. បង្កើនកម្រិតបច្ចេកវិទ្យារបស់សហគ្រាស (២) | ១.៤.១. ជំរុញ និងលើកទឹកចិត្តការផ្ទេរបច្ចេកវិទ្យាថ្មីៗ ក្នុងវិស័យកម្មន្តសាល រួមទាំងផ្នែកសិប្បកម្ម (ឧបសម្ព័ន្ធ ឃ, ទំព័រទី១៩) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| **២. បង្កើនការនាំចេញទំនិញឧស្សាហកម្ម និងកសិ-ឧស្សាហកម្ម** | | |
| ២.១. បង្កើនសមត្ថភាពនាំចេញរបស់ក្រុមហ៊ុនក្នុងស្រុក (៣) | ២.១.១. ជំរុញឱ្យមានការរៀបចំផែនការរយៈពេលមធ្យមសម្រាប់អភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ដោយកំណត់យកមុខសញ្ញាសហគ្រាសដែលមានសក្តានុពលក្នុងការនាំចេញ ការអភិវឌ្ឍផលិតផលថ្មី ការតភ្ជាប់ទៅនឹងសាជីវកម្មពហុជាតិ (MNCs) ការតភ្ជាប់ខ្សែច្រវាក់តម្លៃ និងការតភ្ជាប់ទៅនឹងបណ្តាញផលិតកម្មតំបន់ ហើយរៀបចំនូវក្របខណ្ឌសកម្មភាពចាំបាច់ និងជាក់ស្តែងដើម្បីអភិវឌ្ឍន៍ សហគ្រាសទាំងនោះ<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៦) | -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងពាណិជ្ជកម្ម |
| ២.២. ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងការតភ្ជាប់ (២៧) | ២.២.២. រៀបចំ និងអនុវត្តផែនការមេសម្រាប់ការអភិវឌ្ឍ ប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ម ក្នុងគោលដៅបង្កើតប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយ និងប្រព័ន្ធភស្តុភារកម្មដែលមានសមាហរណកម្ម និងប្រសិទ្ធភាពខ្ពស់ ពិសេស ផ្តោតលើការតភ្ជាប់ប៉ូលសេដ្ឋកិច្ចសំខាន់ៗ និងការអភិវឌ្ឍរបៀងសេដ្ឋកិច្ច ភ្នំពេញ-ខេត្តព្រះសីហនុ ភ្នំពេញ-បាវិត និង ភ្នំពេញ-ប៉ោយប៉ែត ឱ្យក្លាយទៅជារបៀងសេដ្ឋកិច្ចគន្លឹះ | សម្របសម្រួលដោយគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>ក្រសួង ស្ថាប័នចូលរួម៖<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន |

| គោលបំណងគោលនយោបាយ/ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| | របស់ជាតិ តាមរយៈការកសាងផ្លូវហាយវេស្តង់ដារអន្តរជាតិ និងការបង្កើតប្រព័ន្ធភស្តុភារកម្មប្រកបដោយប្រសិទ្ធភាព<br>(ឧបសម្ព័ន្ធ គ, ទំព័រទី១) | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| | ២.២.៩. ជំរុញកិច្ចខិតខំប្រឹងប្រែងថ្នាក់តំបន់និងអនុតំបន់នានា ដូចជា អាស៊ាន និងកម្មវិធីមហាអនុតំបន់មេគង្គ ដើម្បីអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងដែន (CBTA) និង "យន្តការបញ្ជរតែមួយ" ដែលត្រូវបានបង្កើតឡើងក្នុងគោលដៅកែលម្អប្រសិទ្ធភាពនៃប្រព័ន្ធភស្តុភារកម្មអន្តរជាតិក្នុងតំបន់ ទន្ទឹមនឹងការរៀបចំបង្កើតក្របខ័ណ្ឌស្ថាប័នចាំបាច់នានា ដើម្បីធ្វើសមាហរណកម្មបញ្ចូលក្នុងប្រព័ន្ធភស្តុភារកម្មកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលឱ្យកាន់តែទូលំទូលាយជាមួយអាជ្ញាធរដៃគូពាក់ព័ន្ធ ដែលមានកាតព្វកិច្ចក្នុងការសម្រួលការដឹកជញ្ជូន ការចល័តមនុស្ស និងទំនិញ<br>(ឧបសម្ព័ន្ធ ឃ ទំព័រទី១១) | -ក្រសួងសាធារណការ និងដឹកជញ្ជូន<br>-ក្រសួងពាណិជ្ជកម្ម<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| | ២.២.១៥. ពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាតក្នុងរាជធានី ទីប្រជុំជន តំបន់ឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេស តាមរយៈការពង្រឹងសមត្ថភាព អង្គភាព រដ្ឋាករទឹកសាធារណៈ និងឯកជន ស្របតាមបទដ្ឋានបច្ចេកទេសនៃការផ្គត់ផ្គង់សេវាទឹកស្អាត និងអនុលោមតាមស្តង់ដារទឹកបរិភោគជាតិ<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី២១) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| | ២.២.២០. ដោះស្រាយបញ្ហាកកស្ទះចរាចរណ៍នៅជាយក្រុងភ្នំពេញ ដែលធ្វើឱ្យចំណាយភស្តុភារកម្មកើនឡើងជាប្រចាំ ពិសេស ការកសាងផ្លូវក្រវាត់ក្រុង ឬផ្លូវវៀងក្រៅក្រុង ដើម្បីធានាឱ្យចរាចរប្រព្រឹត្តទៅដោយរលូន<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី២២) | -ក្រសួងសាធារណការ និងដឹកជញ្ជូន<br>-សាលារាជធានីភ្នំពេញ |

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| **៣. សេដ្ឋកិច្ចដែលមានភាពធន់ និងមានពិពិធកម្ម** | | |
| ៣.៣. ធ្វើឱ្យមានតុល្យភាពរវាងក្រុមហ៊ុនធំ និងសហគ្រាសធុនតូច និងមធ្យម (៥) | ៣.៣.២. ពង្រឹងអភិបាលកិច្ចសាជីវកម្មសម្រាប់ពង្រឹង និងពង្រីកវិស័យឯកជន ដើម្បីលើកស្ទួយវប្បធម៌នៃគណនេយ្យភាពសង្គម និងលទ្ធភាពទទួលបានហិរញ្ញប្បទានក្នុងទីផ្សារហិរញ្ញវត្ថុ តាមរយៈផ្តល់ការបណ្តុះបណ្តាលលើការគ្រប់គ្រងទូទៅ ការគ្រប់គ្រងប្រព័ន្ធផលិតកម្ម និងការគ្រប់គ្រងបច្ចេកវិទ្យាសម្រាប់សហគ្រាសធុនតូច និងមធ្យម<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៩) | -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួងពាណិជ្ជកម្ម |
| ៣.៤ បង្កើននវានុវត្តន៍ផ្នែកឧស្សាហកម្ម (១៨) | ៣.៤.៤. កែលម្អប្រសិទ្ធភាពនៃការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម តាមរយៈការអនុវត្តនីតិវិធីធ្វើកិច្ចសហប្រតិបត្តិការផ្តល់សិទ្ធិចុះបញ្ជីដល់ភ្នាក់ងារនៃប្រទេសជាដៃគូនានា និងសម្រួលក្នុងការចុះបញ្ជីភ្នាក់ងារដែលប្រកបអាជីវកម្មធ្វើជាតំណាងរបស់អ្នកដាក់ពាក្យសុំក្នុងការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម ដោយផ្តោតការយកចិត្តទុកដាក់លើការធ្វើស្វ័យប្រវត្តិកម្មប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៣) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| | ៣.៤.៥. បង្កើនការយល់ដឹង និងធ្វើការផ្សព្វផ្សាយអំពីសារៈប្រយោជន៍នៃស្តង់ដារ មាត្រាសាស្ត្រ និងកម្មសិទ្ធិឧស្សាហកម្ម ដើម្បីជំរុញចូលរួមឱ្យបានទូលំទូលាយពីសំណាក់សហគ្រិន<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៣) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| | ៣.៤.១៥. បង្កើតយន្តការប្រឡងប្រណាំងអ្នកជំនាញបច្ចេកវិទ្យា អ្នកមានគំនិតផ្តួចផ្តើមធុរកិច្ច វិស្វករដែលមានទេពកោសល្យ ដើម្បីចម្រាញ់ឧស្សាហករ ដែលមានទេពកោសល្យ និងបង្កើតកម្លាំងចលករឱ្យខិតខំបង្កើតនវានុវត្តន៍ ជាពិសេសក្នុងចំណោមវិស្វករ និងសហគ្រិនវ័យក្មេង<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៩) | -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួងអប់រំ យុវជន និងកីឡា<br>-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៣.៥. ធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម (៩) | ៣.៥.៣. ជំរុញការបង្កើតសមាគមតាមអនុវិស័យនីមួយៗ ដើម្បីចែករំលែកចំណេះដឹង តស៊ូមតិ និងការពារសិទ្ធិប្រយោជន៍ ក៏ដូចជា ពង្រឹងទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល ក្នុងការទទួលការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៨) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |

| គោលបំណងគោលនយោបាយ/ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| | ៣.៥.៥. ពង្រឹងយន្តការក្រោមដំបូលតែមួយសម្រាប់ការចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម ដោយប្រើប្រាស់ការចុះបញ្ជី និងការកាន់បញ្ជីគណនេយ្យសម្រាប់ជាមូលដ្ឋានវាយតម្លៃ និងជាលក្ខខណ្ឌសម្រាប់ការផ្តល់ការលើកទឹកចិត្ត និងការគាំទ្រពីរាជរដ្ឋាភិបាល<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៨) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| **៤. ការធ្វើឱ្យប្រសើរឡើងនូវគុណភាពការងារ** | | |
| ៤.៤. ធ្វើឱ្យប្រសើរឡើងនូវការផ្គត់ផ្គង់ការងារ (៤) | ៤.៤.២. ពង្រឹងយន្តការគ្រប់គ្រងកម្មករជំនាញ ជាពិសេសត្រៀមលក្ខណៈឱ្យបានល្អប្រសើរសម្រាប់សមាហរណកម្មអាស៊ាន<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៦) | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| **៥. បង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមា** | | |
| ៥.៤. បង្កើនការកែច្នៃកសិកម្មក្នុងស្រុក (៤) | ៥.៤.១. ពិនិត្យលទ្ធភាពបង្កើតនូវតំបន់កែច្នៃកសិផល ដូចជាតំបន់កែច្នៃ និងផលិតសង្ការិម តំបន់កែច្នៃផលិតសម្ភារៈពីកៅស៊ូ តំបន់កែច្នៃផលិតម្ហូបអាហារពីសមុទ្រ តំបន់កែច្នៃចំណីអាហារសម្រាប់គោលដៅប្រើប្រាស់ក្នុងស្រុកផង និងនាំចេញផង ជាពិសេសដោយប្រើប្រាស់យន្តការភាពជាដៃគូ រវាងរដ្ឋ និងវិស័យឯកជន<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៩)<br>*៥.៤.១.២. រៀបចំច្បាប់ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា* | -ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួងពាណិជ្ជកម្ម<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |

# បរិសិដ្ឋទី៨៖ ម៉ាទ្រីសវឌ្ឍនភាពវិធានការ និងអនុវិធានការគោលនយោបាយ IDP

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| **១. បង្កើនសកម្មភាពឧស្សាហកម្ម** | | | |
| ១.១ បង្កើនតម្រូវការក្នុងស្រុក និងការជំនួសផលិតផលនាំចូល | មិនមានវិធានការគោលនយោបាយឆ្លើយតបនឹងអន្តរាគមន៍គោលនយោបាយនេះ | | |
| ១.២. បង្កើនការវិនិយោគក្នុងវិស័យឧស្សាហកម្ម (១៩) | ១.២.១. អភិវឌ្ឍ និងប្រែក្លាយខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុ-បំណង ដែលគ្រោងអនុវត្តតាមគោលការណ៍តំបន់រដ្ឋបាលពិសេស ដោយរៀបចំផែនការមេសម្រាប់ការអភិវឌ្ឍក្របខណ្ឌច្បាប់ និងនិយតកម្ម ព្រមទាំងយន្តការគ្រប់គ្រង ចាំបាច់នានា ដែលនឹងផ្តល់សិទ្ធិអំណាច និងយុត្តាធិការពេញលេញសម្រាប់ការកៀរគរ ទាក់ទាញ និងប្រមូលផ្តុំនូវប្រភពធនធាន បញ្ញាញាណ សកម្មភាពធុរកិច្ច និងវិនិយោគ ដើម្បីអភិវឌ្ឍខេត្តនេះឱ្យទៅជាប៉ូលសេដ្ឋកិច្ចសំខាន់មួយ និងជាមជ្ឈមណ្ឌលឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍ ស្របតាមទស្សនាទាននៃការអភិវឌ្ឍប្រកបដោយចីរភាព និងមានតុល្យភាពបរិស្ថាន ព្រមទាំងឱ្យប្រែក្លាយជាទីក្រុងឧស្សាហកម្មបៃតងអាស៊ាន នាពេលអនាគត (ឧបសម្ព័ន្ធ គ, ទំព័រទី៣) | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងទេសចរណ៍<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងបរិស្ថាន<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ទីស្តីការគណៈរដ្ឋមន្ត្រី<br>- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត | កំពុងអនុវត្ត |
| | ១.២.២. ពិនិត្យឡើងវិញនូវច្បាប់វិនិយោគ ព្រមទាំងវិធានច្បាប់ពាក់ព័ន្ធដទៃទៀត ដោយផ្អែកលើតម្រូវការជាក់ស្តែងក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម សំដៅ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សម្រេចពេញលេញ |

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | លើកទឹកចិត្តដល់ការវិនិយោគក្នុងវិស័យឧស្សាហកម្ម រួមមានការទាក់ទាញការវិនិយោគ ការផ្ទេរបច្ចេកវិទ្យា ការបង្កើតការងារ និងបណ្តុះបណ្តាលជំនាញ និងការបង្កើនតម្លៃបន្ថែមនៃឧស្សាហកម្មជារួម<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១) | | |
| | ១.២.៣. បន្តពង្រឹងបរិស្ថានអនុគ្រោះសម្រាប់ការវិនិយោគ និងធុរកិច្ច តាមរយៈការបន្តកែលម្អក្របខណ្ឌគតិយុត្ត ក្របខណ្ឌអភិបាលកិច្ច និងប្រសិទ្ធភាពនៃស្ថាប័នសាធារណៈពាក់ព័ន្ធ ពិសេស ការពង្រឹងយន្តការ "ច្រកចេញចូលតែមួយ" នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឱ្យក្លាយជាយន្តការប្រកបដោយប្រសិទ្ធភាពក្នុងការទាក់ទាញវិនិយោគ<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១) | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | សម្រេចពេញលេញ |
| | ១.២.៤. ពង្រឹងសមត្ថភាពស្ថាប័ន និងសមាហរណកម្មមុខងារគ្រប់គ្រង និងទាក់ទាញវិនិយោគ ជាមួយមុខងារជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម ដែលស្ថិតក្រោមសមត្ថកិច្ចរួមនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមរយៈការរៀបចំផែនការសកម្មភាពរយៈពេលខ្លី និងមធ្យម ការកែទម្រង់ និងទំនើបកម្មស្ថាប័ន និងការលើកកម្ពស់សមត្ថភាពមន្ត្រី ដើម្បីប្រកបដោយប្រសិទ្ធភាពទៅនឹងចក្ខុវិស័យ និងគោលដៅនៃគោលនយាបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី២) | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សម្រេចពេញលេញ |
| | ១.២.៥. ពង្រឹងយន្តការផ្តល់សេវាថែទាំវិនិយោគ ដោយផ្អែកលើឧត្តមានុវត្តន៍ជាសកល ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការសម្រួលការវិនិយោគ និងដោះស្រាយបញ្ហាប្រឈមរបស់វិនិយោគិនក្នុងគ្រប់ដំណាក់កាលនៃការអនុវត្តគម្រោងវិនិយោគ<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី២) | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សម្រេចពេញលេញ |

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | ១.២.៦. បន្តពង្រឹងប្រសិទ្ធភាពនៃ "វេទិការាជរដ្ឋាភិបាលជាមួយនឹងវិស័យឯកជន" ដើម្បីលើកទឹកចិត្តដល់ការចូលរួមរបស់វិស័យឯកជនក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី២) | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សម្រេចពេញលេញ |
| | ១.២.៧. ពិនិត្យឡើងវិញនូវយន្តការផ្តល់ព័ត៌មានវិនិយោគ ដោយយកចិត្តដាក់លើភាពងាយស្រួលក្នុងការទទួលព័ត៌មាន ពិសេស ការកែលម្អមាតិកាព័ត៌មាន ដែលផ្អែកលើប្រតិកម្មតបនៃអ្នកប្រើប្រាស់<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៣) | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សម្រេចពេញលេញ |
| | ១.២.៨. ពិនិត្យឡើងវិញអំពីក្របខ័ណ្ឌលើកទឹកចិត្តសម្រាប់ក្រុមហ៊ុនដែលបោះទីតាំងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ទាំងក្រុមហ៊ុនបរទេស ទាំងក្រុមហ៊ុនក្នុងស្រុក និងទាំងសហគ្រាសធុនតូច និងមធ្យម<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៣) | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សម្រេចពេញលេញ |
| | ១.២.៩. ជំរុញការបង្កើតកម្រងឧស្សាហកម្ម និងសួនឧស្សាហកម្មធំៗ តាមរយៈការអនុម័ត "ច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស" សំដៅអភិវឌ្ឍតំបន់ទាំងនោះឱ្យឈានដល់កម្រិតស្តង់ដារអន្តរជាតិលើគ្រប់ទិដ្ឋភាព រួមមាន ប្រព័ន្ធគ្រប់គ្រងមូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធ ការផ្គត់ផ្គង់អគ្គិសនី ទឹកស្អាត វត្ថុធាតុដើម និងធាតុចូលផ្សេងៗ កិច្ចសម្រួលការដឹកជញ្ជូន និងពាណិជ្ជកម្ម ព្រមទាំងការលើកទឹកចិត្ត និងវិធានការគាំទ្រជាក់ស្តែងផ្សេងទៀត ដើម្បីជំរុញការវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៣) | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | យឺតយ៉ាវ |
| | ១.២.១០. លើកកម្ពស់ការប្រកួតប្រជែងរវាងតំបន់សេដ្ឋកិច្ចពិសេសនានា ដោយសិក្សាបង្កើតសូចនាករស្នូល សម្រាប់វាស់ស្ទង់សមិទ្ធកម្មនៃកិច្ចដំណើរការរបស់ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សម្រេចពេញលេញ |

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | តំបន់សេដ្ឋកិច្ចទាំងនោះ សម្រាប់ជាលក្ខខណ្ឌវិនិច្ឆ័យក្នុងការផ្តល់ការលើកទឹកចិត្ត និងជំរុញឧត្តមានុវត្តន៍ (ឧបសម្ព័ន្ធ ឃ, ទំព័រទី៤) | | |
| | ១.២.១១. ពិនិត្យលទ្ធភាពក្នុងការជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសធំៗ និងមានបទដ្ឋានខ្ពស់ ដោយប្រើយន្តការភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន (ឧបសម្ព័ន្ធ ឃ, ទំព័រទី៦) | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សម្រេចពេញលេញ |
| | ១.២.១២. សិក្សាឡើងវិញពីប្រព័ន្ធពន្ធដារ និងពន្ធគយ ដោយប្រែក្លាយឱ្យទៅជាឧបករណ៍ប្រមូលចំណូលផង និងជាឧបករណ៍ជំរុញការអភិវឌ្ឍឧស្សាហកម្មផង (ឧបសម្ព័ន្ធ ឃ, ទំព័រទី១៤) | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | |
| | *១.២.១២.១. ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣* | | សម្រេចពេញលេញ |
| | *១.២.១២.២. ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣* | | សម្រេចពេញលេញ |
| | ១.២.១៣. ជំរុញការបង្វិលសងឱ្យបានឆាប់ ឬប្រើប្រាស់ជាឥណទានយោង (Tax Credit) ស្របតាមបទប្បញ្ញត្តិពន្ធដារជាធរមាន (ឧបសម្ព័ន្ធ ឃ, ទំព័រទី១៤) | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សម្រេចពេញលេញ |
| | ១.២.១៤. បន្តអនុវត្ត "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០" ដែលជាក្របខណ្ឌរួមនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា (ឧបសម្ព័ន្ធ ឃ, ទំព័រទី២២) | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ធនាគារជាតិនៃកម្ពុជា | សម្រេចពេញលេញ |

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | ១.២.១៥. ពង្រឹងទីផ្សារមូលបត្រ ដើម្បីកៀរគរប្រភពហិរញ្ញវត្ថុ និងប្រើប្រាស់វាឱ្យមានប្រសិទ្ធភាព ជាពិសេស ពិចារណាលើលទ្ធភាពបង្កើតមូលបត្ររតនាគារ ដើម្បីធ្វើហិរញ្ញប្បទានគម្រោងអភិវឌ្ឍន៍ដែលគាំទ្រដល់ការបង្កើតមូលដ្ឋានឧស្សាហកម្ម (ឧបសម្ព័ន្ធ ឃ, ទំព័រទី២៣) | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | |
| | *១.២.១៥.១. រៀបចំច្បាប់ស្តីពីមូលបត្ររដ្ឋ ថ្មីឡើងវិញ* | | សម្រេចពេញលេញ |
| | *១.២.១៥.២. រៀបចំឯកសារយុទ្ធសាស្ត្រនៃការអភិវឌ្ឍទីផ្សារមូលត្រនៅកម្ពុជា* | | កំពុងអនុវត្ត |
| ១.៣. បង្កើនផលិតភាពរបស់សហគ្រាស (១) | ១.៣.១. ជួយគាំទ្រលើកកម្ពស់សមត្ថភាព និងសមត្ថកិច្ចរបស់ "**មជ្ឈមណ្ឌលផលិតភាពកម្ពុជា**" សំដៅលើកកម្ពស់ផលិតភាព និងគុណភាពដល់សហគ្រាសធុនតូច និងមធ្យម(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៣) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | កំពុងអនុវត្ត |
| ១.៤. បង្កើនកម្រិតបច្ចេកវិទ្យារបស់សហគ្រាស (២) | ១.៤.១. ជំរុញ និងលើកទឹកចិត្តការផ្ទេរបច្ចេកវិទ្យាថ្មីៗ ក្នុងវិស័យកម្មន្តសាល រួមទាំងផ្នែកសិប្បកម្ម (ឧបសម្ព័ន្ធ ឃ, ទំព័រទី១៩) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | យឺតយ៉ាវ |
| | ១.៤.២. ជួយគាំទ្រដល់ការផ្ទេរបច្ចេកវិទ្យា តាមរយៈទស្សនកិច្ចសិក្សា និងការបណ្តុះ-បណ្តាលពីបណ្តាប្រទេសនានាជុំវិញពិភពលោក (ឧបសម្ព័ន្ធ ឃ, ទំព័រទី៧) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | កំពុងអនុវត្ត |
| **២. បង្កើនការនាំចេញទំនិញឧស្សាហកម្ម និងកសិ-ឧស្សាហកម្ម** | | | |
| ២.១. បង្កើនសមត្ថភាពនាំចេញរបស់ក្រុមហ៊ុនក្នុងស្រុក (៣) | ២.១.១. ជំរុញឱ្យមានការរៀបចំផែនការរយៈពេលមធ្យមសម្រាប់អភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ដោយកំណត់យកមុខសញ្ញាសហគ្រាសដែលមានសក្តានុពលក្នុងការនាំចេញ ការអភិវឌ្ឍផលិតផលថ្មី ការតភ្ជាប់ទៅនឹងសាជីវកម្មពហុជាតិ (MNCs) ការតភ្ជាប់ខ្សែច្រវាក់តម្លៃ និងការតភ្ជាប់ទៅនឹងបណ្តាញផលិតកម្មតំបន់ ហើយរៀបចំនូវក្របខណ្ឌសកម្មភាពចាំបាច់ និងដាក់ស្តែងដើម្បីអភិវឌ្ឍន៍ សហគ្រាសទាំងនោះ (ឧបសម្ព័ន្ធ ឃ, ទំព័រទី៦) | -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងពាណិជ្ជកម្ម | យឺតយ៉ាវ |

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | ២.១.២. បង្កើតមូលនិធិសម្រាប់ជំរុញការអភិវឌ្ឍផលិតផលបច្ចេកទេសកែច្នៃកសិផល និងអភិវឌ្ឍបច្ចេកទេស ដោយភ្ជាប់ទៅនឹងសក្តានុពលនាំចេញ<br>( ឧបសម្ព័ន្ធ ឃ, ទំព័រទី៩ ) | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សម្រេចពេញលេញ |
| | ២.១.៣. ជំរុញការបង្កើតសមាគមតាមអនុវិស័យនីមួយៗ ដើម្បីចែករំលែកចំណេះដឹង ក៏ដូចជាពង្រឹងទំនាក់ទំនងជាមួយនឹងរាជរដ្ឋាភិបាល<br>( ឧបសម្ព័ន្ធ ឃ, ទំព័រទី១២ ) | -ក្រសួងពាណិជ្ជកម្ម<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សម្រេចពេញលេញ |
| ២.២. ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងការតភ្ជាប់ (២៧) | ២.២.១. រៀបចំ និងអនុវត្តផែនការបញ្ចុះថ្លៃអគ្គិសនី សម្រាប់វិស័យឧស្សាហកម្ម និងពាណិជ្ជកម្ម រួមទាំងការពង្រឹងភាពទុកចិត្ត និងការពង្រីកវិសាលភាពគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនី<br>( ឧបសម្ព័ន្ធ គ, ទំព័រទី១ ) | - ក្រសួងរ៉ែ និងថាមពល<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- អាជ្ញាធរអគ្គិសនីកម្ពុជា<br>- អគ្គិសនីកម្ពុជា | សម្រេចពេញលេញ |
| | ២.២.២. រៀបចំ និងអនុវត្តផែនការមេសម្រាប់ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ម ក្នុងគោលដៅបង្កើតប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយ និងប្រព័ន្ធភស្តុ-ភារកម្មដែលមានសមាហរណកម្ម និងប្រសិទ្ធភាពខ្ពស់ ពិសេស ផ្តោតលើការតភ្ជាប់ប៉ូលសេដ្ឋកិច្ចសំខាន់ៗ និងការអភិវឌ្ឍរបៀងសេដ្ឋកិច្ច ភ្នំពេញ-ខេត្តព្រះសីហនុ ភ្នំពេញ-បាវិត និង ភ្នំពេញ-ប៉ោយប៉ែត ឱ្យក្លាយទៅជារបៀងសេដ្ឋកិច្ចគន្លឹះរបស់ជាតិ តាមរយៈការកសាងផ្លូវហាយវេស្តង់ដារអន្តរជាតិ និងការបង្កើតប្រព័ន្ធភស្តុភារកម្មប្រកបដោយប្រសិទ្ធភាព<br>( ឧបសម្ព័ន្ធ គ, ទំព័រទី១ ) | សម្របសម្រួលដោយគណៈកម្មាធិការគោល-នយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>ក្រសួង ស្ថាប័នចូលរួមៈ<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | យឺតយ៉ាវ |
| | ២.២.៣. ចាត់វិធានការ និងជំរុញឱ្យមានការចូលរួមកាន់តែសកម្មថែមទៀតពីវិស័យឯកជន ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅតាមបណ្តាទីតាំងនៃតំបន់សេដ្ឋកិច្ចពិសេស ដែលបានទទួលគោលការណ៍ពីរាជរដ្ឋាភិបាលកន្លងមក សំដៅ ធានាឱ្យមាន | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សម្រេចពេញលេញ |

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | ភាពទាក់ទាញ និងការចាប់អារម្មណ៍ពីសំណាក់វិនិយោគិន ដែលកំពុងស្វែងរកទីតាំងបង្កើតមូលដ្ឋានផលិតកម្មក្នុងតំបន់ទាំងនោះ<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៣) | | |
| | ២.២.៤. ជំរុញការអភិវឌ្ឍរបៀងឧស្សាហកម្ម ពិសេសផ្តោតលើរបៀងសេដ្ឋកិច្ចតំបន់ឆ្នេរខាងត្បូង (Southern Coastal Economic Corridor) រួមមាន ខេត្តព្រះសីហនុ និងខេត្តកោះកុង ព្រមទាំងរបៀងតាមបណ្តោយផ្លូវជាតិសំខាន់ៗដែលតភ្ជាប់ប៉ូលសេដ្ឋកិច្ចក្នុងស្រុក ក៏ដូចជាតភ្ជាប់របៀងសេដ្ឋកិច្ចកម្ពុជាទៅនឹងប្រទេសជិតខាង នៅក្នុងក្របខណ្ឌនៃរបៀងសេដ្ឋកិច្ចមហាអនុតំបន់មេគង្គ និងអាស៊ាន<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៤) | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ | កំពុងអនុវត្ត |
| | ២.២.៥. រៀបចំផែនការអភិវឌ្ឍទីប្រជុំជន/ទីក្រុងឱ្យក្លាយជាមជ្ឈមណ្ឌលឧស្សាហកម្ម ផ្តោតលើខេត្តព្រះសីហនុ ខេត្តកោះកុង ក្រុងបាវិត និងក្រុងប៉ោយប៉ែត តាមរយៈការបង្កើតយន្តការស្ថាប័នសម្របសម្រួលមួយ ដើម្បីជំរុញការអភិវឌ្ឍមជ្ឈមណ្ឌលឧស្សាហកម្មគ្រប់ជ្រុងជ្រោយ រួមមាន ការកំណត់តំបន់ដីធ្លីផ្អែកលើផែនការប្រើប្រាស់ដីធ្លីច្បាស់លាស់ ការគ្រប់គ្រងបរិស្ថានដែលធានាចីរភាពនៃប្រព័ន្ធអេកូឡូស៊ី ការអភិវឌ្ឍលំនៅឋាន និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដែលរួមមាន អគ្គិសនី ផ្លូវថ្នល់ កំពង់ផែ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធការពារទឹកជំនន់ ប្រព័ន្ធបញ្ចេញចោលកាកសំណល់ និងទឹកសម្អុយ ព្រមទាំងសេវាសង្គម រួមទាំងសេវាសុខាភិបាល អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយផ្អែកលើផែនការអភិវឌ្ឍរយៈពេលវែង<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៤) | -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងសាធារណការ និងដឹកជញ្ជូន<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួងពាក់ព័ន្ធផ្សេងទៀត | |
| | *២.២.៥.១. រៀបចំផែនការអភិវឌ្ឍទីប្រជុំជនខេត្តព្រះសីហនុ* | | សម្រេចពេញលេញ |
| | *២.២.៥.២. រៀបចំផែនការអភិវឌ្ឍទីប្រជុំជនខេត្តកោះកុង* | | កំពុងអនុវត្ត |

| គោលបំណងគោលនយោបាយ/ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | *២.២.៥.៣. រៀបចំផែនការអភិវឌ្ឍទីប្រជុំជន/ទីក្រុងបាវិត* | | សម្រេចពេញលេញ |
| | *២.២.៥.៤. រៀបចំផែនការអភិវឌ្ឍទីប្រជុំជន/ទីក្រុងប៉ោយប៉ែត* | | សម្រេចពេញលេញ |
| | ២.២.៦. អភិវឌ្ឍតំបន់ជុំវិញទីក្រុងភ្នំពេញឱ្យក្លាយជាតំបន់ឧស្សាហកម្មប្រមូលផ្តុំ ដោយមានផែនការប្រើប្រាស់ដីធ្លីច្បាស់លាស់ ដោយបែងចែករវាងតំបន់ឧស្សាហកម្ម និងតំបន់និវេសនដ្ឋាន ឬទីប្រជុំជន រួមទាំងផែនការរយៈពេលវែងសម្រាប់ប្រែក្លាយទីក្រុងភ្នំពេញទៅជាមជ្ឈមណ្ឌលរដ្ឋបាល ឧស្សាហកម្ម វិទ្យាសាស្ត្រ និងនវានុវត្តន៍ (ឧបសម្ព័ន្ធ ឃ, ទំព័រទី៥) | -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>-ក្រសួងមហាផ្ទៃ/សាលារាជធានីភ្នំពេញ<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងសាធារណការ និងដឹកជញ្ជូន<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត | សម្រេចពេញលេញ |
| | ២.២.៧. បន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមមាន ទឹកស្អាត អគ្គិសនី គមនាគមន៍ និងទូរគមនាគមន៍ជាដើម សំដៅបម្រើឱ្យគោលដៅឧស្សាហកម្ម ពិសេសការបោះទីតាំងតំបន់សេដ្ឋកិច្ចពិសេស ការអភិវឌ្ឍប៉ូលឧស្សាហកម្ម និងការប្រែក្លាយតំបន់ទីប្រជុំជន/ទីក្រុងជាមជ្ឈមណ្ឌលឧស្សាហកម្មជាតិ ស្របតាមផែនការរៀបចំដែនដី នគរូបនីយកម្ម និងផែនការប្រើប្រាស់ដី (ឧបសម្ព័ន្ធ ឃ, ទំព័រទី៥) | -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួងរ៉ែ និងថាមពល<br>-ក្រសួងសាធារណការ និងដឹកជញ្ជូន<br>-ក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត | សម្រេចពេញលេញ |
| | ២.២.៨. រៀបចំឱ្យមានផែនការមេមួយអំពីការអភិវឌ្ឍប្រព័ន្ធភស្តុភារកម្ម ដែលជាមូលដ្ឋានក្នុងការជួយសម្រួលពាណិជ្ជកម្ម និងជាប្រព័ន្ធដែលមានប្រសិទ្ធភាព អាចទុកចិត្តបាន និងមានភាពប្រកួតប្រជែងខ្ពស់ (ឧបសម្ព័ន្ធ ឃ, ទំព័រទី១១) | -ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ក្រសួងពាណិជ្ជកម្ម<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | |

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | *២.២.៨.១. រៀបចំផែនការមេស្តីពីការតភ្ជាប់ប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយ និងភស្តុភារកម្ម ឆ្នាំ២០២១-២០២៣* | | សម្រេចពេញលេញ |
| | *២.២.៨.២. រៀបចំផែនការអភិវឌ្ឍន៍ដឹកជញ្ជូន និងភស្តុភារកម្ម ២០២០-២០៣០* | | សម្រេចពេញលេញ |
| | ២.២.៩. ជំរុញកិច្ចខិតខំប្រឹងប្រែងថ្នាក់តំបន់ និងអនុតំបន់នានា ដូចជា អាស៊ាន និងកម្មវិធីមហាអនុតំបន់មេគង្គ ដើម្បីអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងដែន (CBTA) និង "យន្តការបញ្ជរតែមួយ" ដែលត្រូវបានបង្កើតឡើងក្នុងគោលដៅកែលម្អប្រសិទ្ធភាពនៃប្រព័ន្ធភស្តុភារកម្មអន្តរជាតិក្នុងតំបន់ ទន្ទឹមនឹងការរៀបចំបង្កើតក្របខណ្ឌស្ថាប័នចាំបាច់នានា ដើម្បីធ្វើសមាហរណកម្មបញ្ចូលក្នុងប្រព័ន្ធភស្តុភារកម្ម កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលឱ្យកាន់តែទូលំទូលាយជាមួយអាជ្ញាធរដៃគូពាក់ព័ន្ធ ដែលមានកាតព្វកិច្ចក្នុងការសម្រួលការដឹកជញ្ជូន ការចល័តមនុស្ស និងទំនិញ<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១១) | -ក្រសួងសាធារណការ និងដឹកជញ្ជូន<br>-ក្រសួងពាណិជ្ជកម្ម<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | យឺតយ៉ាវ |
| | ២.២.១០. បង្កើតយន្តការសម្របសម្រួលការកសាងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (ផ្លូវថ្នល់ ផ្លូវរថភ្លើង ផ្លូវអាកាស និងកំពង់ផែ) ដោយផ្សារភ្ជាប់ទៅនឹងតំបន់គោលដៅនៃការអភិវឌ្ឍឧស្សាហកម្ម<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី២០) | ក្រសួងសាធារណការ និងដឹកជញ្ជូន | សម្រេចពេញលេញ |
| | ២.២.១១. ពិនិត្យតម្រង់ការផ្គត់ផ្គង់ថាមពលទៅកាន់តំបន់ផលិតកម្មសំខាន់ៗ ដោយធានាឱ្យបានការផ្គត់ផ្គង់ចរន្តអគ្គិសនីស្របតាមតម្រូវការ និងមានស្ថិរភាពបំផុត ដែលអនុញ្ញាតឱ្យរោងចក្រអាចគ្រោងផលិតកម្មខ្លួនប្រកបដោយប្រសិទ្ធភាព<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី២០) | -ក្រសួងរ៉ែ និងថាមពល<br>-អាជ្ញាធរអគ្គិសនីកម្ពុជា<br>-អគ្គិសនីកម្ពុជា | សម្រេចពេញលេញ |

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | ២.២.១២. អនុវត្តគម្រោងកសាងស្ថានីយផលិតអគ្គិសនីដែលបានគ្រោង និងកំពុងបន្តអនុវត្តឱ្យទាន់ពេលវេលា ដើម្បីបំពេញកង្វះខាតថាមពលអគ្គិសនីនៅឆ្នាំ២០២០ រួមទាំងការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាព និងគុណភាពនៃការបញ្ជូនថាមពល (ឧបសម្ព័ន្ធ ឃ, ទំព័រទី២០) | -ក្រសួងរ៉ែ និងថាមពល<br>-អាជ្ញាធរអគ្គិសនីកម្ពុជា<br>-អគ្គិសនីកម្ពុជា | សម្រេចពេញលេញ |
| | ២.២.១៣. ពិនិត្យឡើងវិញនូវការប៉ាន់ស្មានពីតម្រូវការអគ្គិសនីរយៈពេលវែង និងផែនការអភិវឌ្ឍវិស័យថាមពល ធៀបនឹងចក្ខុវិស័យថ្មីសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងឧស្សាហកម្ម រួមទាំងពិនិត្យឡើងវិញនូវជម្រើសក្នុងការផ្គត់ផ្គង់ថាមពល ដែលមានសមត្ថភាពគ្រប់គ្រាន់ ជាពិសេស សម្រាប់ផ្គត់ផ្គង់តំបន់ឧស្សាហកម្មយុទ្ធសាស្ត្រសំខាន់ៗ<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី២០) | -ក្រសួងរ៉ែ និងថាមពល<br>-អាជ្ញាធរអគ្គិសនីកម្ពុជា<br>-អគ្គិសនីកម្ពុជា | សម្រេចពេញលេញ |
| | ២.២.១៤. បង្កើនវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងកែលម្អសេវា និងមធ្យោបាយដឹកជញ្ជូន សម្រាប់សម្រួល និងជួយគាំទ្រប្រតិបត្តិការអាជីវកម្ម (ឧបសម្ព័ន្ធ ឃ, ទំព័រទី២០) | -ក្រសួងសាធារណការ និងដឹកជញ្ជូន<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | កំពុងអនុវត្ត |
| | ២.២.១៥. ពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាតក្នុងរាជធានី ទីប្រជុំជន តំបន់ឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេស តាមរយៈការពង្រឹងសមត្ថភាពអង្គភាពរដ្ឋាករទឹកសាធារណៈ និងឯកជន ស្របតាមបទដ្ឋានបច្ចេកទេសនៃការផ្គត់ផ្គង់សេវាទឹកស្អាត និងអនុលោមតាមស្តង់ដារទឹកបរិភោគជាតិ<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី២១) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | យឺតយ៉ាវ |
| | ២.២.១៦. បន្តពង្រីក និងថែទាំកំណាត់ផ្លូវជាតិសំខាន់ៗ ដែលជាច្រកសម្រាប់ការដឹកជញ្ជូនទំនិញ ជាពិសេស ផ្លូវជាតិឱ្យក្លាយជាផ្លូវថ្នល់ធំទូលាយដើម្បីធ្វើឱ្យប្រសើរនូវការតភ្ជាប់ទៅកាន់ប្រទេសថៃ និងវៀតណាម ព្រមទាំងច្រករបៀងភ្នំពេញ-សៀមរាប និងភ្នំពេញ-ក្រុងព្រះសីហនុ ទន្ទឹមនឹងការពិនិត្យសម្រាប់រយៈពេលវែងនូវ | -ក្រសួងសាធារណការ និងដឹកជញ្ជូន<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | កំពុងអនុវត្ត |

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | លទ្ធភាពកសាងផ្លូវហាយវេចំពោះផ្លូវជាតិសំខាន់ៗ សម្រាប់ពង្រឹងសមត្ថភាពប្រព័ន្ធភស្តុភារកម្មរវាងកម្ពុជា និងប្រទេសជិតខាងទៀត ជាអាទិ៍ ប្រទេសថៃ និងវៀតណាម (ឧបសម្ព័ន្ធ ឃ, ទំព័រទី២១) | | |
| | ២.២.១៧. ធ្វើឱ្យប្រសើរឡើង និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធនៃតំបន់សេដ្ឋកិច្ចពិសេស រួមមាន ប្រព័ន្ធផ្លូវថ្នល់ ដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ជាពិសេស នៅខេត្តស្វាយរៀង និងកោះកុង ដែលមានច្រកព្រំដែនអន្តរជាតិ និងខេត្តព្រះសីហនុ ដែលមានកំពង់ផែសមុទ្រអន្តរជាតិ (ឧបសម្ព័ន្ធ ឃ, ទំព័រទី២១) | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួងសាធារណការ និងដឹកជញ្ជូន<br>រដ្ឋបាលថ្នាក់ក្រោមជាតិ | កំពុងអនុវត្ត |
| | ២.២.១៨. បន្តអភិវឌ្ឍផ្លូវដែកនៅកម្ពុជា បន្ទាប់ពីផ្លូវដែកភ្នំពេញ-ខេត្តព្រះសីហនុបានដាក់ឱ្យដំណើរការ ដើម្បីប្រែក្លាយផ្លូវដែកជាជម្រើសដឹកជញ្ជូនមួយសំខាន់ ដែលចូលរួមចំណែកធ្វើឱ្យថ្លៃដឹកជញ្ជូនធ្លាក់ចុះ និងមានប្រសិទ្ធភាពជាងមុន (ឧបសម្ព័ន្ធ ឃ, ទំព័រទី២១) | ក្រសួងសាធារណការ និងដឹកជញ្ជូន | កំពុងអនុវត្ត |
| | ២.២.១៩. អភិវឌ្ឍបណ្តាញដឹកជញ្ជូនតាមផ្លូវទន្លេ ដែលមានសក្តានុពលក្នុងការកាត់បន្ថយចំណាយភស្តុភារកម្ម ជាពិសេស សម្រាប់ការដឹកជញ្ជូនកសិផល ដោយកសាងកំពង់ផែតូចៗ ដែលអាចឱ្យនាវាដឹកជញ្ជូនចូលផ្ទុក និងផ្ទេរទំនិញនៅតាមដងទន្លេមេគង្គ ស្របគ្នានឹងការសាងសង់កំពង់ផែថ្មីនៅភ្នំពេញ និងខេត្តព្រះសីហនុ ដែលនឹងសម្រួលដល់ការដឹកជញ្ជូនតាមនាវាក្នុងបរិមាណកាន់តែច្រើន (ឧបសម្ព័ន្ធ ឃ, ទំព័រទី២១) | ក្រសួងសាធារណការ និងដឹកជញ្ជូន | កំពុងអនុវត្ត |
| | ២.២.២០. ដោះស្រាយបញ្ហាកកស្ទះចរាចរណ៍នៅជាយក្រុងភ្នំពេញ ដែលធ្វើឱ្យចំណាយភស្តុភារកម្មកើនឡើងជាប្រចាំ ពិសេស ការកសាងផ្លូវក្រវាត់ក្រុង ឬផ្លូវវៀងក្រៅក្រុង ដើម្បីធានាឱ្យចរាចរប្រព្រឹត្តទៅដោយរលូន (ឧបសម្ព័ន្ធ ឃ, ទំព័រទី២២) | -ក្រសួងសាធារណការ និងដឹកជញ្ជូន<br>-សាលាក្រុងភ្នំពេញ | យឺតយ៉ាវ |

| គោលបំណងគោលនយោបាយ/ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | ២.២.២១. ពិនិត្យលទ្ធភាពនៃភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងវិស័យឯកជនសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលអាចបន្ទុរបន្ទុកវិនិយោគសាធារណជន (ឧបសម្ព័ន្ធ ឃ, ទំព័រទី២២) | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សម្រេចពេញលេញ |
| **៣. សេដ្ឋកិច្ចដែលមានភាពធន់ និងមានពិពិធកម្ម** | | | |
| ៣.១. បង្កើនសកម្មភាពឧស្សាហកម្មថ្មីៗ (៤) | ៣.១.១. ពិនិត្យឡើងវិញ និងកែសម្រួលលក្ខខណ្ឌវិនិច្ឆ័យពិសេសសម្រាប់ទាក់ទាញ "គម្រោងវិនិយោគសក្តានុពល និងមានគុណភាព" ដែលផ្តល់ផលវិជ្ជមាន និងតម្លៃបន្ថែមសម្រាប់ការបើកផ្លូវដល់ការអភិវឌ្ឍ និងការទាក់ទាញឧស្សាហកម្មថ្មីៗមកកម្ពុជា<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១) | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួង ស្ថាប័នពាក់ព័ន្ធ | សម្រេចពេញលេញ |
| | ៣.១.២. រៀបចំ និងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្រ្ត និងវិធានការជាក់ស្តែង ដើម្បីជំរុញការផ្សព្វផ្សាយ និងទាក់ទាញការវិនិយោគ ដោយផ្តោតលើប្រទេសគោលដៅមួយចំនួន និងកំណត់ប្រភេទឧស្សាហកម្មអាទិភាពច្បាស់លាស់<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី២) | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សម្រេចពេញលេញ |
| | ៣.១.៣. បន្តពង្រឹង និងលើកកម្ពស់សមត្ថភាពរដ្ឋបាល និងក្របខណ្ឌស្ថាប័នសម្រាប់គ្រប់គ្រងប្រតិបត្តិការនៃតំបន់សេដ្ឋកិច្ចពិសេស តាមរយៈការបង្កើនប្រសិទ្ធភាពនៃយន្តការច្រកចេញចូលតែមួយរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស សំដៅជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសឯកទេស ដោយផ្តោតលើវិស័យអាទិភាពមួយចំនួន ដូចជា ការកែច្នៃកសិផលសម្រាប់នាំចេញ (ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចឯកទេស ត្រូវចំណុះលើកត្តាសំខាន់ៗ ដូចជា ទីតាំងភូមិសាស្រ្ត ប្រភេទប្រតិបត្តិការអាជីវកម្ម មូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធ រួមទាំង អគ្គិសនី និងទឹកស្អាត និងប្រព័ន្ធភស្តុភារកម្ម ព្រមទាំងការលើកទឹកចិត្តផងដែរ)<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៦) | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សម្រេចពេញលេញ |

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | ៣.១.៤. ពិនិត្យឡើងវិញ និងប្រមូលផ្តុំសក្តានុពលធនធានធម្មជាតិ ដែលជំរុញឱ្យមានការវិនិយោគលើវិស័យឧស្សាហកម្មធុនធ្ងន់<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី២០) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | កំពុងអនុវត្ត |
| ៣.២. ពង្រីក និងពិពិធកម្មទីផ្សារ និងផលិតផលនាំចេញ (១០) | ៣.២.១. ពន្លឿនបញ្ចប់ការអនុវត្តផែនការកែទម្រង់ការសម្រួលពាណិជ្ជកម្ម រួមទាំងការដាក់ឱ្យប្រើប្រាស់សេវា "បញ្ជរតែមួយជាតិ" ដោយមានការសម្របសម្រួលគ្នាក្នុងចំណោមអាជ្ញាធរតាមមាត់ច្រកអន្តរជាតិទាំងអស់ ហើយធានាឱ្យមានសមាហរណកម្មជាមួយនឹងសេវា "បញ្ជរតែមួយអាស៊ាន" និងការតភ្ជាប់ទៅនឹងបណ្តាញភស្តុភារកម្មអន្តរជាតិ(ឧបសម្ព័ន្ធ ឃ, ទំព័រទី១០) | -ក្រសួងពាណិជ្ជកម្ម<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួងសាធារណការ និងដឹកជញ្ជូន | សម្រេចពេញលេញ |
| | ៣.២.២. បង្កើតនូវមជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្ម ដែលប្រមូលផ្តុំនូវព័ត៌មានអំពីវិធានពាណិជ្ជកម្ម តារាងពន្ធ និងកម្រៃផ្លូវការដែលត្រូវបង់ដោយពាណិជ្ជករ ហើយដាក់ព័ត៌មានទាំងនេះលើបណ្តាញ<br>អ៊ីនធើណែត<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១០) | -ក្រសួងពាណិជ្ជកម្ម<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សម្រេចពេញលេញ |
| | ៣.២.៣. កែលម្អការធ្វើបែបបទបញ្ចេញទំនិញ (Custom Clearance) សម្រាប់ទំនិញដែលលើកលែងពន្ធ ដោយពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធ កាត់បន្ថយនូវតម្រូវការឯកសារមិនចាំបាច់ សម្រួលនីតិវិធីឱ្យបានឆាប់រហ័ស និងលុបបំបាត់ចំណាយក្រៅផ្លូវការ<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១១) | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | |
| | *៣.២.៣.១. ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធ ដើម្បីការកាត់បន្ថយនូវតម្រូវការឯកសារមិនចាំបាច់ សម្រួលនីតិវិធីឱ្យបានឆាប់រហ័ស សម្រាប់ទំនិញដែលលើកលែងពន្ធ* | | សម្រេចពេញលេញ |

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | *៣.២.៣.២. ការលុបបំបាត់ចំណាយក្រៅផ្លូវការ ក្នុងការបំពេញបែបបទបញ្ចេញទំនិញ* | | សម្រេចពេញលេញ |
| | ៣.២.៤. កាត់បន្ថយនូវនីតិវិធីត្រួតពិនិត្យដែលជាន់គ្នា និងគ្មានតម្លាភាព (ឧបសម្ព័ន្ធ ឃ, ទំព័រទី១១) | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួង ស្ថាប័នពាក់ព័ន្ធ | សម្រេចពេញលេញ |
| | ៣.២.៥. ពង្រឹងសមត្ថភាពអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ឱ្យក្លាយជាភ្នាក់ងារជំរុញការនាំចេញ ដែលមានជំនាញខ្ពស់ក្នុងការវិភាគទីផ្សារនាំចេញ កំណត់មុខសញ្ញានាំចេញ និងរៀបចំបណ្តាញធុរកិច្ច ដែលជាមូលដ្ឋានក្នុងការផ្តល់ការពិគ្រោះយោបល់ផ្នែកពាណិជ្ជកម្ម ផ្តល់ព័ត៌មានអំពីទីផ្សារក្រៅប្រទេស និងជួយសម្របសម្រួលសកម្មភាពជំរុញការនាំចេញ រួមទាំង ការរៀបចំការផ្សព្វផ្សាយទីផ្សារ ឬការតាំងពិព័រណ៍<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១១) | ក្រសួងពាណិជ្ជកម្ម | សម្រេចពេញលេញ |
| | ៣.២.៦. ពិចារណាបង្កើតស្ថាប័នហិរញ្ញប្បទានតាមគោលនយោបាយដែលមានកាតព្វកិច្ចផ្តល់កម្ចីទៅឱ្យអ្នកនាំចេញ ដែលផលិតទំនិញនាំចេញក្នុងឧស្សាហកម្មអាទិភាព និងផ្តល់នូវសេវាធានារ៉ាប់រងការនាំចេញ ដើម្បីកាត់បន្ថយភាពមិនប្រាកដប្រជាទាក់ទងនឹងការនាំចេញ<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១២) | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួងពាណិជ្ជកម្ម | សម្រេចពេញលេញ |
| | ៣.២.៧. ពង្រឹងការសម្រួលពាណិជ្ជកម្ម តាមរយៈការកែលម្អនីតិវិធី ការពង្រឹងយន្តការដឹកជញ្ជូនឆ្លងដែន ការកាត់បន្ថយថ្លៃចម្លងការពាណិជ្ជកម្ម និងការពង្រឹងការសម្របសម្រួលស្ថាប័ន<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១២) | -ក្រសួងពាណិជ្ជកម្ម<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួងសាធារណការ និងដឹកជញ្ជូន | សម្រេចពេញលេញ |

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | ៣.២.៨. ពិចារណាបង្កើតប្រព័ន្ធលើកទឹកចិត្តសម្រាប់ក្រុមហ៊ុនក្នុងស្រុកដែលនាំចេញទំនិញថ្មីៗ និងនាំចេញបានចំនួនច្រើនជាងគេ ដោយផ្តល់នូវរង្វាន់លើកទឹកចិត្តពិសេស និងរង្វាន់នានា សម្រាប់ក្រុមហ៊ុនដែលបាននាំទំនិញដល់ចំនួនដែលបានកំណត់ តាមរយៈការវាយតម្លៃប្រកបដោយតម្លាភាព ដោយផ្សារភ្ជាប់នឹងគោលដៅនៃការអភិវឌ្ឍឧស្សាហកម្ម<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១២) | -ក្រសួងពាណិជ្ជកម្ម<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សម្រេចពេញលេញ |
| ៣.៣. ធ្វើឱ្យមានតុល្យភាពរវាងក្រុមហ៊ុនធំ និងសហគ្រាសធុនតូច និងមធ្យម (៥) | ៣.៣.១. បន្តអភិវឌ្ឍតំបន់ឧស្សាហកម្មតាមបណ្តាខេត្ត ដែលជាមូលដ្ឋានប្រមូលផ្តុំនៃសហគ្រាសធុនតូច និងមធ្យម សំដៅជំរុញលើកកម្ពស់ភាពប្រកួតប្រជែងនៃសហគ្រាសទាំងនោះ ពិសេសតាមរយៈការផ្តល់អាទិភាពលើការតភ្ជាប់បណ្តាញអគ្គិសនី និងការផ្គត់ផ្គង់ទឹកស្អាត ការតភ្ជាប់ផ្លូវដឹកជញ្ជូន និងភស្តុភារកម្ម ព្រមទាំងការសម្រួល និងការលើកទឹកចិត្តផ្សេងទៀតពីរដ្ឋ<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៣) | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-រដ្ឋបាលថ្នាក់ក្រោមជាតិ<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | កំពុងអនុវត្ត |
| | ៣.៣.២. ពង្រឹងអភិបាលកិច្ចសាជីវកម្មសម្រាប់ពង្រឹង និងពង្រីកវិស័យឯកជន ដើម្បីលើកស្ទួយវប្បធម៌នៃគណនេយ្យភាពសង្គម និងលទ្ធភាពទទួលបានហិរញ្ញប្បទានក្នុងទីផ្សារហិរញ្ញវត្ថុ តាមរយៈផ្តល់ការបណ្តុះបណ្តាលលើការគ្រប់គ្រងទូទៅ ការគ្រប់គ្រងប្រព័ន្ធផលិតកម្ម និងការគ្រប់គ្រងបច្ចេកវិទ្យាសម្រាប់សហគ្រាសធុនតូច និងមធ្យម<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៩) | -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួងពាណិជ្ជកម្ម | យឺតយ៉ាវ |
| | ៣.៣.៣. សិក្សា និងរៀបចំឱ្យមានយន្តការហិរញ្ញវត្ថុ សមស្របសម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ពិសេស ការផ្តល់កម្ចីដល់សហគ្រាសធុនតូច និងមធ្យម ព្រមទាំងជំរុញការផ្តល់ហិរញ្ញប្បទានដល់ឧស្សាហកម្មអាទិភាព<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី២២) | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | *៣.៣.៣.១. ការបង្កើតធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា* | | សម្រេចពេញលេញ |
| | *៣.៣.៣.២. ការបង្កើតសាជីវកម្មធានាឥណទានកម្ពុជា* | | សម្រេចពេញលេញ |
| ៣.៤ បង្កើននវានុវត្តន៍ផ្នែកឧស្សាហកម្ម (១៨) | ៣.៤.១. លើកស្ទួយសមត្ថភាពវិទ្យាស្ថានឧត្តមសិក្សាដើម្បីជាមូលដ្ឋានរឹងមាំមួយសម្រាប់ក្រេបជញ្ជក់យកវិទ្យាសាស្ត្រ បង្កើនការហ្វឹកហ្វឺន និងនវានុវត្តន៍បច្ចេកវិទ្យាថ្មីៗ សម្រាប់តម្រូវការទីផ្សារ<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៧) | ក្រសួងអប់រំ យុវជន និងកីឡា | សម្រេចពេញលេញ |
| | ៣.៤.២. បង្កើតពានរង្វាន់សម្រាប់ការប្រកួតប្រជែងបច្ចេកទេសនៅលើគ្រប់មុខសញ្ញាអាទិភាព<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៨) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សម្រេចពេញលេញ |
| | ៣.៤.៣. បន្តពង្រឹងក្របខ័ណ្ឌស្ថាប័ន និងសមត្ថភាពគ្រប់គ្រងមាត្រាសាស្ត្រ និងស្តង់ដារដែលជាគ្រឹះសម្រាប់សកម្មភាពឧស្សាហកម្ម និងខិតខំប្រឹងប្រែងបន្តរៀបចំក្របខ័ណ្ឌគតិយុត្ត និងការទទួលស្គាល់ជាអន្តរជាតិនូវស្ថាប័នជាតិសំខាន់ៗ រួមមានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និងវិទ្យាស្ថានស្តង់ដារកម្ពុជា<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១២) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | កំពុងអនុវត្ត |
| | ៣.៤.៤. កែលម្អប្រសិទ្ធភាពនៃការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម តាមរយៈការអនុវត្តនីតិវិធីធ្វើកិច្ចសហប្រតិបត្តិការផ្តល់សិទ្ធិចុះបញ្ជីដល់ភ្នាក់ងារនៃប្រទេសជាដៃគូនានា និងសម្រួលក្នុងការចុះបញ្ជីភ្នាក់ងារដែលប្រកបអាជីវកម្មធ្វើជាតំណាងរបស់អ្នកដាក់ពាក្យសុំក្នុងការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម ដោយផ្តោតការយកចិត្តទុកដាក់លើការធ្វើស្វ័យប្រវត្តិកម្មប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៣) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | យឺតយ៉ាវ |

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
| --- | --- | --- | --- |
| | ៣.៤.៥. បង្កើនការយល់ដឹង និងធ្វើការផ្សព្វផ្សាយអំពីសារប្រយោជន៍នៃស្តង់ដារ មាត្រាសាស្ត្រ និងកម្មសិទ្ធិឧស្សាហកម្ម ដើម្បីជំរុញចូលរួមឱ្យបានទូលំទូលាយពីសំណាក់សហគ្រិន<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៣) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | យឺតយ៉ាវ |
| | ៣.៤.៦. ជួយគាំទ្រលើកកម្ពស់សមត្ថភាព និងសមត្ថកិច្ចមាត្រាសាស្ត្រ និងស្តង់ដារ ក្នុងការធានានូវបរិមាណ គុណភាព សុវត្ថិភាព សេវាកម្ម បរិស្ថាន និងគ្រប់គ្រង<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៣) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | កំពុងអនុវត្ត |
| | ៣.៤.៧. ចាត់វិធានការជាក់ស្តែងក្នុងការពង្រឹងការអនុវត្តស្តង់ដារ មាត្រាសាស្ត្រ និងកម្មសិទ្ធិឧស្សាហកម្ម ដើម្បីប្រែក្លាយក្របខ័ណ្ឌទាំងនេះឱ្យក្លាយជាឧបករណ៍សម្រាប់ជំរុញការប្រកួតប្រជែង<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៣) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | កំពុងអនុវត្ត |
| | ៣.៤.៨. ពង្រឹងសមត្ថភាព "វិទ្យាស្ថានស្តង់ដារកម្ពុជា" ក្នុងការសិក្សាស្រាវជ្រាវរៀបចំស្តង់ដារជាតិសម្រាប់ផលិតផល សេវាកម្ម ផលិតកម្ម និងបច្ចេកទេស អនុលោមតាមស្តង់ដារតំបន់ និង អន្តរជាតិ<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៣) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | កំពុងអនុវត្ត |
| | ៣.៤.៩. ពង្រឹងសមត្ថភាពមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិក្នុងការសិក្សាស្រាវជ្រាវរៀបចំនីតិវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ព្យាសកម្ម តេស្តវិភាគ និងការអនុម័តគំរូឧបករណ៍មាត្រាសាស្ត្រដែលបម្រើឱ្យការអភិវឌ្ឍវិស័យឧស្សាហកម្ម<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៤) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | កំពុងអនុវត្ត |
| | ៣.៤.១០. ជំរុញការរៀបចំនូវក្របខ័ណ្ឌគោលនយោបាយ និងយន្តការអភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៨) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | កំពុងអនុវត្ត |

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | ៣.៤.១១. ពង្រឹងការគ្រប់គ្រងមណ្ឌលច្នៃប្រឌិត និងបង្កើតថ្មីកម្ពុជា ដើម្បីលើកកម្ពស់ការបង្កើតតក្កកម្ម និងការបណ្ដុះបណ្ដាលកម្មសិទ្ធិឧស្សាហកម្ម (ឧបសម្ព័ន្ធ ឃ, ទំព័រទី១៩) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | កំពុងអនុវត្ត |
| | ៣.៤.១២. ពង្រឹង និងកសាងសមត្ថភាពធនធានមនុស្សទៅតាមតម្រូវការសម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាឧស្សាហកម្ម (ឧបសម្ព័ន្ធ ឃ, ទំព័រទី១៨) | -ក្រសួងអប់រំ យុវជន និងកីឡា<br>-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សម្រេចពេញលេញ |
| | ៣.៤.១៣. សហការ និងជំរុញការសិក្សាស្រាវជ្រាវ និងការលើកទឹកចិត្តផ្នែកវិទ្យា-សាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ឧបសម្ព័ន្ធ ឃ, ទំព័រទី១៩) | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួងអប់រំ យុវជន និងកីឡា<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |
| | *៣.៤.១៣.១. សិក្សាស្រាវជ្រាវគោលនយោបាយផ្អែកលើភស្តុតាងជាក់ស្តែងបែបវិទ្យាសាស្ត្រ ក្នុងក្របខណ្ឌសេដ្ឋកិច្ចពលកម្ម ផលិតភាពពលកម្ម និងភាពប្រកួតប្រជែង* | | សម្រេចពេញលេញ |
| | *៣.៤.១៣.២. សហការ និងជំរុញការសិក្សាស្រាវជ្រាវ និងការលើកទឹកចិត្តផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍* | | សម្រេចពេញលេញ |
| | ៣.៤.១៤. សិក្សាលទ្ធភាពបង្កើតសួនវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាភ្ជាប់នឹងសួនឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេសនានា ដើម្បីផ្តល់សេវាពិសោធន៍ និងសិក្សាស្រាវជ្រាវដល់ឧស្សាហកម្ម (ឧបសម្ព័ន្ធ ឃ, ទំព័រទី១៩) | -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | កំពុងអនុវត្ត |
| | ៣.៤.១៥. បង្កើតយន្តការប្រឡងប្រណាំងអ្នកជំនាញបច្ចេកវិទ្យា អ្នកមានគំនិតផ្តួចផ្តើមធុរកិច្ច វិស្វករដែលមានទេពកោសល្យ ដើម្បីចម្រាញ់ឧស្សាហករ ដែលមានទេពកោសល្យ និងបង្កើតកម្លាំងចលករឱ្យខិតខំបង្កើតនវានុវត្តន៍ ជាពិសេសក្នុងចំណោមវិស្វករ និងសហគ្រិនវ័យក្មេង (ឧបសម្ព័ន្ធ ឃ, ទំព័រទី១៩) | -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួងអប់រំ យុវជន និងកីឡា<br>-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | យឺតយ៉ាវ |

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
| --- | --- | --- | --- |
| | ៣.៤.១៦. ពិនិត្យលទ្ធភាពវិនិយោគលើវិទ្យាស្ថានស្រាវជ្រាវរដ្ឋ ដោយផ្តោតទាំងស្រុងទៅលើវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ពិសេស ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងវិស័យអាទិភាពនីមួយៗ ដោយជ្រើសរើសអ្នកវិទ្យាសាស្ត្រ និងវិស្វករមានសមត្ថភាពជាមួយនឹងសម្ភារៈបរិក្ខារមន្ទីរពិសោធន៍សមស្រប<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៩) | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួងអប់រំ យុវជន និងកីឡា<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | កំពុងអនុវត្ត |
| ៣.៥. ធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម (៩) | ៣.៥.១. ពង្រឹងនូវក្របខណ្ឌ និងយន្តការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ពិសេសសំដៅរៀបចំការចុះបញ្ជី ការគ្រប់គ្រង និងការតាមដានវឌ្ឍនភាពនៃវិស័យនេះ ដែលទាក់ទាញសហគ្រាសកម្ពុជាឱ្យទៅចុះបញ្ជីរបបពន្ធផ្លូវការ ដែលអាចឱ្យរាជរដ្ឋាភិបាលកម្ពុជាមានព័ត៌មានច្បាស់លាស់សម្រាប់រៀបចំគោលនយោបាយគាំទ្រ ដើម្បីផ្តល់លទ្ធភាពឱ្យសហគ្រាសទាំងនោះមានលទ្ធភាពទទួលបានព័ត៌មានពីឥណទាន និងការពិគ្រោះយោបល់ផ្នែកធុរកិច្ច ដើម្បីពង្រីកសកម្មភាព និងការវិនិយោគ<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៧) | -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួងពាណិជ្ជកម្ម<br>-ស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត | សម្រេចពេញលេញ |
| | ៣.៥.២. បង្កើតមូលនិធិសម្រាប់ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D) ដោយមានយន្តការគ្រប់គ្រងត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈ ដោយរដ្ឋាភិបាលផ្តល់នូវការវិភាជថវិកាសមស្រប យោងតាមតម្រូវការ និងលទ្ធភាពជាក់ស្តែងនៃថវិកាជាតិ<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៧) | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សម្រេចពេញលេញ |
| | ៣.៥.៣. ជំរុញការបង្កើតសមាគមតាមអនុវិស័យនីមួយៗ ដើម្បីចែករំលែកចំណេះ-ដឹង តស៊ូមតិ និងការពារសិទ្ធិប្រយោជន៍ ក៏ដូចជា ពង្រឹងទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល ក្នុងការទទួលការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៨) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | យឺតយ៉ាវ |

| គោលបំណងគោលនយោបាយ/ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | ៣.៥.៤. ធ្វើវិសោធនកម្មកែលម្អច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ដោយរៀបចំស្តង់ដារគណនេយ្យសាមញ្ញសម្រាប់សហគ្រាសធុនតូច និងមធ្យម<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៨) | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រុមប្រឹក្សាជាតិគណនេយ្យ<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សម្រេចពេញលេញ |
| | ៣.៥.៥. ពង្រឹងយន្តការក្រោមដំបូលតែមួយសម្រាប់ការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម ដោយប្រើប្រាស់ការចុះបញ្ជី និងការកាន់បញ្ជីគណនេយ្យសម្រាប់ជាមូលដ្ឋានវាយតម្លៃ និងជាលក្ខខណ្ឌសម្រាប់ការផ្តល់ការលើកទឹកចិត្ត និងការគាំទ្រពីរាជរដ្ឋាភិបាល<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៨) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | យឺតយ៉ាវ |
| | ៣.៥.៦. លើកទឹកចិត្តដល់សហគ្រាសធុនធំ សហគ្រាសធុនតូច និងមធ្យម ឱ្យកាន់បញ្ជីគណនេយ្យ និងធ្វើការបង់ពន្ធតាមរបបពិត<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៨) | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រុមប្រឹក្សាជាតិគណនេយ្យ | សម្រេចពេញលេញ |
| | ៣.៥.៧. ផ្សព្វផ្សាយឱ្យបានទូលំទូលាយពីភាពងាយស្រួល និងអត្ថប្រយោជន៍នៃការចុះបញ្ជី<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៩) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សម្រេចពេញលេញ |
| | ៣.៥.៨. ផ្តល់ការបណ្តុះបណ្តាលលើការកាន់បញ្ជីគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៩) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សម្រេចពេញលេញ |
| | ៣.៥.៩. ពង្រឹងការប្រើប្រាស់ស្តង់ដារនីយកម្ម និងការវាយតម្លៃការទទួលស្គាល់អនុលោមភាពដោយផ្សារភ្ជាប់ទៅនឹងការធ្វើលទ្ធកម្មសាធារណៈ ការទទួលបានការលើកទឹកចិត្ត និងការជួយឧបត្ថម្ភផ្សេងៗ<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៣) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សម្រេចពេញលេញ |

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| **៤. ការធ្វើឱ្យប្រសើរឡើងនូវគុណភាពការងារ** | | | |
| ៤.១. ធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍជំនាញ និងធនធានមនុស្ស (១៧) | ៤.១.១. ពង្រឹង និងបន្តអភិវឌ្ឍយន្តការគ្រប់គ្រងទីផ្សារពលកម្មនិងការបណ្តុះបណ្តាលជំនាញ ដើម្បីរក្សាស្ថិរភាពនៃការផ្គត់ផ្គង់កម្លាំងពលកម្ម លើកកម្ពស់ផលិតភាព និងកែលម្អកម្រិតជីវភាពរបស់ពលករ តាមរយៈការជំរុញការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលជំនាញ ការពង្រឹងយន្តការកំណត់ប្រាក់បៀវត្សអប្បបរមា និងការពង្រឹងសុខដុមភាពនៃទំនាក់ទំនងវិជ្ជាជីវៈ ឈរលើគោលការណ៍តវិយាបថវិជ្ជមានរបស់សហជីព និងព្រហ្មវិហារធម៌របស់និយោជក ចំពោះនិយោជិត ដោយប្រើប្រាស់យន្តការមានស្រាប់ជាអាទិ៍យន្តការ "គណៈកម្មការប្រឹក្សាការងារ" និង "គណៈកម្មាធិការផលិតភាពកម្ពុជា" (ឧបសម្ព័ន្ធ គ, ទំព័រទី២) | -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងអប់រំ យុវជន និងកីឡា<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-គណៈកម្មាការប្រឹក្សាការងារ<br>-គណៈកម្មាការផលិតភាពកម្ពុជា | |
| | *៤.១.១.១. បន្តអភិវឌ្ឍយន្តការបណ្តុះបណ្តាល ដើម្បីរក្សាស្ថិរភាពនៃការផ្គត់ផ្គង់កម្លាំងពលកម្ម លើកកម្ពស់ផលិតភាព និងកែលម្អកម្រិតជីវភាពរបស់ពលករ តាមរយៈការជំរុញការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល ជំនាញ* | | សម្រេចពេញលេញ |
| | ៤.១.២. ធ្វើវិចារណកម្មលើការលើកទឹកចិត្តបន្ថែម ចំពោះគម្រោងវិនិយោគដែលរួមចំណែកក្នុងការបណ្តុះបណ្តាលជំនាញ ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ ព្រមទាំងនវានុវត្តន៍<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១) | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួង ស្ថាប័នពាក់ព័ន្ធ | សម្រេចពេញលេញ |
| | ៤.១.៣. កសាងធនធានមនុស្ស ដើម្បីជំរុញការអភិវឌ្ឍឧស្សាហកម្មឱ្យមានភាពរឹងមាំ និងជវភាព ដោយផ្តល់ការហ្វឹកហាត់លើជំនាញឯកទេស សម្រាប់ដោះស្រាយកង្វះខាតជំនាញក្នុងវិស័យអាទិភាព ដោយបង្កើនអាហារូបករណ៍សម្រាប់ការបណ្តុះ-បណ្តាលវិស្វករ និងអ្នកបច្ចេកទេស (ឧបសម្ព័ន្ធ ឃ, ទំព័រទី៧) | -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងអប់រំ យុវជន និងកីឡា | សម្រេចពេញលេញ |

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | ៤.១.៤. បង្កើតឱកាសទីពីរសម្រាប់ការទទួលបានការបញ្ចប់ថ្នាក់មធ្យមសិក្សា តាមរយៈការបង្កើតប្រព័ន្ធសមមូលសញ្ញាបត្រ ដោយផ្អែកលើការធ្វើតេស្ត ដែលអនុញ្ញាតឱ្យទទួលបានវិញ្ញាបនបត្រចំណេះដឹងទូទៅគ្រប់កម្រិត ទោះនៅក្រៅប្រព័ន្ធអប់រំផ្លូវការក៏ដោយ<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៦) | ក្រសួងអប់រំ យុវជន និងកីឡា | សម្រេចពេញលេញ |
| | ៤.១.៥. ពង្រឹងគុណភាពអប់រំនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា ដោយផ្តោតលើការពង្រឹងមូលដ្ឋានចំណេះដឹងរបស់កុមារ និងយុវជន លើផ្នែកគណិតវិទ្យា វិទ្យាសាស្ត្រ អក្សរសាស្ត្រ និងបច្ចេកវិទ្យា<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៦) | ក្រសួងអប់រំ យុវជន និងកីឡា | សម្រេចពេញលេញ |
| | ៤.១.៦. ជំរុញការអប់រំចំណេះទូទៅឱ្យបានយ៉ាងហោចណាស់ប្រាំបួនឆ្នាំ ដោយកាត់បន្ថយឱ្យបានជាអតិបរមានូវអត្រាបោះបង់ការសិក្សានៅកម្រិតបឋមសិក្សា និងលើកកម្ពស់ការចូលរៀននៅថ្នាក់មធ្យមសិក្សា<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៦) | ក្រសួងអប់រំ យុវជន និងកីឡា | សម្រេចពេញលេញ |
| | ៤.១.៧. កែលម្អកម្មវិធីសិក្សាដោយដាក់បញ្ចូលជំនាញទន់ (Soft Skills) រួមមានជំនាញទំនាក់ទំនងសង្គមក្នុងការដោះស្រាយបញ្ហា ការគោរពវិន័យនៅកន្លែងធ្វើការ និងជំនាញជាច្រើនទៀតដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍមូលដ្ឋានគ្រឹះឧស្សាហកម្ម<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៧) | ក្រសួងអប់រំ យុវជន និងកីឡា | សម្រេចពេញលេញ |
| | ៤.១.៨. បង្កើនការបណ្តុះបណ្តាលបច្ចេកទេសឱ្យបានច្រើនជងជាងមុន តាមលទ្ធភាពលើជំនាញបច្ចេកទេស ជាពិសេស នៅក្នុងផ្នែកអគ្គិសនី មេកានិក ស្តង់ដារមាត្រាសាស្ត្រ (ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ព្យាសកម្ម តេស្ត និងជំនាញប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ) និងគីមីសាស្ត្រ ទាំងក្នុងកម្រិតមធ្យមសិក្សា | -ក្រសួងអប់រំ យុវជន និងកីឡា<br>-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សម្រេចពេញលេញ |

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | បច្ចេកទេស ទាំងក្នុងកម្រិតឧត្តមសិក្សា<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៧) | | |
| | ៤.១.៩. ផ្តល់អាទិភាពដល់ការបង្កើតសាលាមធ្យមសិក្សាបច្ចេកទេសឱ្យបានច្រើន (ទាំងក្នុងប្រព័ន្ធអប់រំទូទៅ ទាំងក្រៅប្រព័ន្ធ) ដោយផ្តោតលើផ្នែកសំខាន់ៗ ដូចជា អគ្គិសនី ព័ត៌មានវិទ្យា កុំព្យូទ័រ ម៉ាស៊ីន ការជួសជុល និងការដំឡើងរថយន្ត និងម៉ូតូ ការកែច្នៃកសិផល និងសិប្បកម្ម<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៧) | -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងអប់រំ យុវជន និងកីឡា | សម្រេចពេញលេញ |
| | ៤.១.១០. រៀបចំផែនការបណ្តុះបណ្តាលបច្ចេកទេស និងវិទ្យាសាស្ត្រ ដែលបម្រើឱ្យវិស័យឧស្សាហកម្ម ដោយរួមមានផែនការវិនិយោគច្បាស់លាស់ និងក្នុងទស្សន-វិស័យរយៈពេលវែង<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៧) | -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងអប់រំ យុវជន និងកីឡា | សម្រេចពេញលេញ |
| | ៤.១.១១. ជំរុញស្ថាប័ននីយកម្មនូវកម្មវិធីប្រព័ន្ធកម្មសិក្សា (Apprenticeship Schemes) ដែលផ្សារភ្ជាប់ជាមួយប្រព័ន្ធលើកទឹកចិត្តដល់ក្រុមហ៊ុន និងសហគ្រាស ដែលទទួលអនុវត្តតាមប្រព័ន្ធកម្មសិក្សាបែបនេះ<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៧) | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សម្រេចពេញលេញ |
| | ៤.១.១២. ពង្រឹងការបណ្តុះបណ្តាលជំនាញឆ្លើយតបនឹងតម្រូវការរបស់វិស័យឯកជនទាំងវិន័យ កម្រិត ជំនាញ និងសមត្ថភាពតាមរយៈការធ្វើសហប្រតិបត្តិការជាមួយនឹងវិនិយោគិនបរទេសគោលដៅ មានដូចជាការបង្កើតមជ្ឈមណ្ឌលហ្វឹកហ្វឺនជំនាញជប៉ុន កូរ៉េ សិង្ហបុរី<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៨) | -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងអប់រំ យុវជន និងកីឡា | សម្រេចពេញលេញ |
| | ៤.១.១៣. ជំរុញការបណ្តុះបណ្តាលត្រីភាគី "រដ្ឋ-ស្ថាប័នបណ្តុះបណ្តាលក្រុមហ៊ុន/រោងចក្រ" ដើម្បីបំពាក់ជំនាញ និងបង្កើនផលិតភាព ជាពិសេស ការដាក់បញ្ចូលក្នុង | -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងអប់រំ យុវជន និងកីឡា | សម្រេចពេញលេញ |

| គោលបំណងគោលនយោបាយ/ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | កម្មវិធីអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានស្រាប់ តាមរយៈកិច្ចសហប្រតិបត្តិការរវាងវិស័យសាធារណៈ និងសមាគមឧស្សាហកម្ម (ឧបសម្ព័ន្ធ ឃ, ទំព័រទី១៨) | | |
| | ៤.១.១៤. ពង្រីកការបណ្តុះបណ្តាលជំនាញនៅនឹងកន្លែង ដោយផ្តោតការយកចិត្តទុកដាក់លើពលករតាមរោងចក្រ ដើម្បីឱ្យពលករទាំងនោះទទួលបានការអប់រំបណ្តុះបណ្តាល និងផ្តល់ក្តីសង្ឃឹមក្នុងការអភិវឌ្ឍជំនាញ និងបច្ចេកទេសក្នុងពេលអនាគត (ឧបសម្ព័ន្ធ ឃ, ទំព័រទី១៨) | -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងអប់រំ យុវជន និងកីឡា | សម្រេចពេញលេញ |
| | ៤.១.១៥. ពង្រឹងការអប់រំនៅសាកលវិទ្យាល័យដែលទាក់ទងទៅនឹងវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រមូលដ្ឋានសំខាន់ៗផ្សេងទៀត និងវិស្វកម្ម ដោយពង្រឹងសម្ភារៈបរិក្ខារមន្ទីរពិសោធន៍ ដើម្បីឈានទៅកសាងគុណភាពអប់រំសម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ (ឧបសម្ព័ន្ធ ឃ, ទំព័រទី១៨) | ក្រសួងអប់រំ យុវជន និងកីឡា | សម្រេចពេញលេញ |
| | ៤.១.១៦. ជំរុញការសិក្សាអប់រំលើជំនាញវិទ្យាសាស្ត្រ បច្ចេកទេស វិស្វកម្ម និងគណិតវិទ្យា (STEM) ពីកម្រិតបឋមសិក្សា រហូតដល់ក្រោយមធ្យមសិក្សា ពិសេសផ្តោតលើសិស្សក្មេងៗ ជាមួយ នឹងការកែទម្រង់កម្មវិធីសិក្សា ដោយការធ្វើស្តង់ដារនីយកម្មនៃកម្មវិធីសិក្សាទាំងនោះពីកម្រិតបឋមសិក្សាឡើងទៅ (ឧបសម្ព័ន្ធ ឃ, ទំព័រទី១៩) | ក្រសួងអប់រំ យុវជន និងកីឡា | សម្រេចពេញលេញ |
| ៤.២.បង្កើនតម្រូវការពលកម្មជំនាញ | មិនមានវិធានការគោលនយោបាយឆ្លើយតបនឹងអន្តរាគមន៍គោលនយោបាយនេះ | | |
| ៤.៣. ធ្វើឱ្យប្រសើរឡើងនូវទំនាក់-ទំនងវិជ្ជាជីវៈ (៧) | ៤.៣.១. ពង្រឹង និងបន្តអភិវឌ្ឍយន្តការគ្រប់គ្រងទីផ្សារពលកម្មនិងការបណ្តុះបណ្តាលជំនាញ ដើម្បីរក្សាស្ថិរភាពនៃការផ្គត់ផ្គង់កម្លាំងពលកម្ម លើកកម្ពស់ផលិតភាព និងកែលម្អកម្រិតជីវភាពរបស់ពលករ តាមរយៈការជំរុញការអភិវឌ្ឍ | -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងអប់រំ យុវជន និងកីឡា | |

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | កម្មវិធីបណ្តុះបណ្តាលជំនាញ ការពង្រឹងយន្តការកំណត់ប្រាក់បៀវត្សអប្បបរមា និងការពង្រឹងសុខដុមភាពនៃទំនាក់ទំនងវិជ្ជាជីវៈ ឈរលើគោលការណ៍ឥរិយាបថវិជ្ជមានរបស់សហជីព និងព្រហ្មវិហារធម៌របស់និយោជក ចំពោះនិយោជិត ដោយប្រើប្រាស់យន្តការមានស្រាប់ ជាអាទិ៍យន្តការ "គណៈកម្មការប្រឹក្សាការងារ" និង "គណៈកម្មាធិការផលិតភាពកម្ពុជា"<br>(ឧបសម្ព័ន្ធ គ, ទំព័រទី២) | -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-គណៈកម្មាការប្រឹក្សាការងារ<br>-គណៈកម្មាការផលិតភាពកម្ពុជា | |
| | *៤.៣.១.១. ពង្រឹងសុខដុមភាពនៃទំនាក់ទំនងវិជ្ជាជីវៈ ឈរលើគោលការណ៍ឥរិយាបថវិជ្ជមានរបស់សហជីព និងព្រហ្មវិហារធម៌របស់និយោជក ចំពោះនិយោជិត* | | សម្រេចពេញលេញ |
| | ៤.៣.២. បន្តពង្រឹងយន្តការទំនាក់ទំនងត្រីភាគី រួមមាន រដ្ឋាភិបាល និយោជក និងនិយោជិត តាមរយៈ "គណៈកម្មការប្រឹក្សាការងារ" ដើម្បីបង្កើនការយោគយល់គ្នាទន្ទឹមនឹងការខិតខំរៀបចំប្រព័ន្ធយន្តការមួយប្រកបដោយប្រសិទ្ធភាពសម្រាប់កំណត់ប្រាក់ឈ្នួលអប្បបរមា ដែលស៊ីច្រវាក់ទៅនឹងផលិតភាពការងារ សមស្របតាមលក្ខខណ្ឌសេដ្ឋកិច្ចសង្គម និងធានាបាននូវការអភិវឌ្ឍឧស្សាហកម្មជារួម<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៤) | -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួង ស្ថាប័នពាក់ព័ន្ធ | សម្រេចពេញលេញ |
| | ៤.៣.៣. ផ្តួចផ្តើមឱ្យមានការសិក្សាស្រាវជ្រាវទៅលើទំនាក់ទំនងរវាងបុគ្គលិក និយោជិត និងនិយោជក ដើម្បីកំណត់ពីបទពិសោធល្អៗក្នុងការស្វែងរកដំណោះ-ស្រាយជាប្រព័ន្ធមួយដែលអាចបង្កើនផលិតផលសរុប ជាពិសេសការបណ្តុះបណ្តាលអាជីពក្នុងការដោះស្រាយបញ្ហារបស់កម្មករ ស្របទៅតាមច្បាប់ការងារ និងបទ-ប្បញ្ញត្តិជាធរមាន (ឧបសម្ព័ន្ធ ឃ, ទំព័រទី១៥) | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សម្រេចពេញលេញ |

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | ៤.៣.៤. រៀបចំច្បាប់ស្តីពីសហជីព និងច្បាប់ស្តីពីតុលាការការងារ [២] (ឧបសម្ព័ន្ធ ឃ, ទំព័រទី១៥) | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សម្រេចពេញលេញ |
| | ៤.៣.៥. ពិនិត្យឡើងវិញពីច្បាប់ការងារ និងការអនុវត្តកន្លងមក ដើម្បីស្វែងរកចំណុចវិជ្ជមាន និងចំណុចអវិជ្ជមាន ហើយធ្វើការគូសបញ្ជាក់ឡើងវិញពីតួនាទីរបស់និយោជក និងសហជីពក្នុងដំណើរការអភិវឌ្ឍទីផ្សារការងារ ដែលថ្លឹងបាននូវតុល្យភាពនៃការអភិវឌ្ឍ និងសុខុមាលភាពកម្មករ (ឧបសម្ព័ន្ធ ឃ, ទំព័រទី១៦) | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សម្រេចពេញលេញ |
| | ៤.៣.៦. រៀបចំគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ (ឧបសម្ព័ន្ធ ឃ, ទំព័រទី១៦) | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សម្រេចពេញលេញ |
| ៤.៤. ធ្វើឱ្យប្រសើរឡើងនូវការផ្តត់ផ្គង់ការងារ (៤) | ៤.៤.១. ពង្រឹងយន្តការគ្រប់គ្រងការជ្រើសរើសកម្លាំងពលកម្ម ការផ្តល់ព័ត៌មានពីទីផ្សារពលកម្ម និងការបណ្តុះបណ្តាលកម្មករឱ្យយល់ដឹងពីជីវភាព និងសិទ្ធិស្របច្បាប់របស់ខ្លួន ពិសេស កាត់បន្ថយការចំណាយហួសហេតុក្នុងការទទួលបានការងារ (ឧបសម្ព័ន្ធ ឃ, ទំព័រទី១៥) | -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ទីភ្នាក់ងារជាតិមុខរបរ | សម្រេចពេញលេញ |
| | *៤.៤.១.១. ពង្រឹងការយល់ដឹងអប់រំអំពីការចាប់អាជីព និងជំនាញបច្ចេកទេសក៏ដូចជាកម្មវិធីសិក្សាបន្ត ដើម្បីអភិវឌ្ឍជំនាញដោយផ្សារភ្ជាប់ទៅនឹងការបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានស្រាប់* | | សម្រេចពេញលេញ |
| | ៤.៤.២. ពង្រឹងយន្តការគ្រប់គ្រងកម្មករជំនាញ ជាពិសេសត្រៀមលក្ខណៈឱ្យបានល្អប្រសើរសម្រាប់សមាហរណកម្មអាស៊ាន (ឧបសម្ព័ន្ធ ឃ, ទំព័រទី១៦) | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | យឺតយ៉ាវ |

[២] សេចក្តីព្រាងច្បាប់ស្តីពីតុលាការការងារ ត្រូវបានរៀបចំសិក្ខាសាលាត្រីភាគីចំនួន១ដង ក្នុងឆ្នាំ២០១៧ និងបានបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីនីតិវិធីជម្រះក្តីវិវាទការងារ នៅខែកញ្ញា ឆ្នាំ២០១៧ និងបានសម្រេចបញ្ឈប់រៀបចំសេចក្តីព្រាងច្បាប់នេះនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៧ (លិខិតលេខ ១០២៦ សជណ.អវ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី) ដោយផ្អែកលើសំណើរបស់ដៃគូពាក់ព័ន្ធ។

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | ៤.៤.៣. ពង្រឹងការយល់ដឹងអំពីការចាប់អាជីពនិងជំនាញបច្ចេកទេស ក៏ដូចជាកម្មវិធីសិក្សាបន្ត ដើម្បីអភិវឌ្ឍជំនាញ ដោយផ្សារភ្ជាប់ទៅនឹងការបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានស្រាប់<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៦) | ក្រសួងអប់រំ យុវជន និងកីឡា | សម្រេចពេញលេញ |
| ៤.៥. ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ (៨) | ៤.៥.១. ពង្រឹង និងបន្តអភិវឌ្ឍយន្តការគ្រប់គ្រងទីផ្សារពលកម្មនិងការបណ្តុះ-បណ្តាលជំនាញ ដើម្បីរក្សាស្ថិរភាពនៃការផ្គត់ផ្គង់កម្លាំងពលកម្ម លើកកម្ពស់ផលិតភាព និងកែលម្អកម្រិតជីវភាពរបស់ពលករ តាមរយៈការជំរុញការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលជំនាញ ការពង្រឹងយន្តការកំណត់ប្រាក់បៀវត្សអប្បបរមា និងការពង្រឹងសុខដុមភាពនៃទំនាក់ទំនងវិជ្ជាជីវៈ ឈរលើគោលការណ៍ត្រីភាគីវិជ្ជមានរបស់សហជីព និងព្រហ្មវិហារធម៌របស់និយោជក ចំពោះនិយោជិត ដោយប្រើប្រាស់យន្តការមានស្រាប់ ជាអាទិ៍យន្តការ "គណៈកម្មការប្រឹក្សាការងារ" និង "គណៈកម្មាធិការផលិតភាពកម្ពុជា"<br>(ឧបសម្ព័ន្ធ គ, ទំព័រទី២) | -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងអប់រំ យុវជន និងកីឡា<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-គណៈកម្មការប្រឹក្សាការងារ<br>-គណៈកម្មាការផលិតភាពកម្ពុជា | |
| | *៤.៥.១.១. ពង្រឹងយន្តការកំណត់ប្រាក់បៀវត្សអប្បបរមាដោយប្រើប្រាស់យន្តការមានស្រាប់ "គណៈកម្មាធិការប្រឹក្សាការងារ"/"ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា"* | | សម្រេចពេញលេញ |
| | ៤.៥.២. កំណត់ឱ្យបានច្បាស់លាស់នូវឯកសារបទដ្ឋាន និងគោលការណ៍ណែនាំស្តីពីការការពារបរិស្ថាន និងសុវត្ថិភាពផលិតកម្ម សម្រាប់គម្រោងវិនិយោគដែលបោះទីតាំងក្នុងតំបន់សេដ្ឋកិច្ចពិសេស និងតំបន់ឧស្សាហកម្មផ្សេងទៀត<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៦) | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងបរិស្ថាន | សម្រេចពេញលេញ |
| | ៤.៥.៣. ពង្រឹងយន្តការចុះធ្វើអធិការកិច្ចលក្ខខណ្ឌការងារ តាមរយៈការពង្រីកកម្មវិធីរោងចក្រល្អប្រសើរ ឬពិនិត្យលទ្ធភាពក្នុងការបង្កើតក្រុមការងារចម្រុះធ្វើអធិការកិច្ចជាប្រចាំ និងមានកម្មវិធីច្បាស់លាស់ ដើម្បីកាត់បន្ថយចំនួនត្រួតពិនិត្យផង និង | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សម្រេចពេញលេញ |

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | ជានាបានប្រសិទ្ធភាពក្នុងការត្រួតពិនិត្យផង។ ក្រុមការងារចម្រុះនេះត្រូវរាយការណ៍ជាទៀងទាត់ជូនរាជរដ្ឋាភិបាល<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៥) | | |
| | ៤.៥.៤. លើកកម្ពស់សុខុមាលភាពរបស់កម្មករ តាមរយៈការជំរុញអនុវត្តគោល-នយោបាយលំនៅឋានសម្រាប់កម្មករ ដែលអនុញ្ញាតឱ្យពួកគេ អាចមានលទ្ធភាពធ្វើជាម្ចាស់កម្មសិទ្ធិលំនៅឋានសម្រាប់បង្កើតគ្រួសារ និងមិនធ្វើការផ្លាស់ប្តូរទីលំនៅញឹកញាប់ពេក ដែលបង្កើតបញ្ហាខ្វះកម្លាំងពលកម្មក្នុងរយៈពេលខ្លី<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៥) | -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សម្រេចពេញលេញ |
| | ៤.៥.៥. ពង្រឹងយន្តការសន្សំក្នុងស្រុក រួមមាន ការអភិវឌ្ឍ និងការកែទម្រង់មូលនិធិសោធន និងវិស័យធានារ៉ាប់រង ដូចមានចែងក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី២៣) | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួងសង្គមកិច្ច យុវនីតិសម្បទា និងអតីតយុទ្ធជន<br>-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | |
| | *៤.៥.៥.១. ពង្រឹងយន្តការសន្សំក្នុងស្រុក តាមរយៈការអភិវឌ្ឍ និងការកែទម្រង់របបសោធន* | | កំពុងអនុវត្ត |
| | *៤.៥.៥.២. ការរៀបចំអនុក្រឹត្យស្តីពីការការធានារ៉ាប់រង ថ្មីឡើងវិញ* | | សម្រេចពេញលេញ |
| **៥. បង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមា** | | | |
| ៥.១. ការតភ្ជាប់រវាងសហគ្រាសក្នុងស្រុកជាមួយសហគ្រាសបរទេស (ព្រមទាំងការផ្ទេរបច្ចេក-វិទ្យា) (៣) | ៥.១.១. សិក្សារៀបចំសួនឧស្សាហកម្មសម្រាប់សហគ្រាសធុនតូច និងមធ្យម សំដៅជំរុញការតភ្ជាប់រវាងសហគ្រាសធំបរទេស និងសហគ្រាសក្នុងស្រុក ពិសេសការចូលរួមក្នុងខ្សែច្រវាក់តម្លៃ និងខ្សែច្រវាក់ផលិតកម្មតំបន់ ក្នុងបរិការណ៍នៃសមាហរណកម្មតំបន់<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៥) | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ | សម្រេចពេញលេញ |

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | ៥.១.២. ពិនិត្យលទ្ធភាពផ្តល់ការគាំទ្រដល់សហគ្រាសធុនតូច និងមធ្យមសម្រាប់ការបណ្តុះបណ្តាល និងការវិនិយោគលើគ្រឿងម៉ាស៊ីន ឬបរិក្ខារផលិតកម្ម ព្រមទាំងការលើកទឹកចិត្តផ្សេងទៀត ដោយផ្សារភ្ជាប់លក្ខខណ្ឌនៃការផលិតវត្ថុធាតុដើមក្នុងស្រុក ការលើកកម្ពស់គុណភាពផលិតផល និងទំនើបកម្មនៃខ្សែច្រវាក់ផលិតកម្មសំដៅផ្សារភ្ជាប់ទៅនឹងសាជីវកម្មពហុជាតិ (MNCs)<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៧) | -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | កំពុងអនុវត្ត |
| | ៥.១.៣. ពង្រឹងសមត្ថភាព និងសហគ្រិនភាពនៃសហគ្រាសក្នុងស្រុក ដើម្បីអាចផ្សារភ្ជាប់ និងទាញយកផលប្រយោជន៍ពីសក្តានុពលសហគ្រាស និងវិនិយោគបរទេសធំៗស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៨) | -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | កំពុងអនុវត្ត |
| ៥.២. ពង្រឹងខ្សែច្រវាក់តម្លៃក្នុងស្រុក | មិនមានវិធានការគោលនយោបាយឆ្លើយតបនឹងអន្តរាគមន៍គោលនយោបាយនេះ | | |
| ៥.៣ បង្កើនភាពជាម្ចាស់របស់សហគ្រាសក្នុងស្រុក | មិនមានវិធានការគោលនយោបាយឆ្លើយតបនឹងអន្តរាគមន៍គោលនយោបាយនេះ | | |
| ៥.៤. បង្កើនការកែច្នៃកសិកម្មក្នុងស្រុក (៦) | ៥.៤.១. ពិនិត្យលទ្ធភាពបង្កើតនូវតំបន់កែច្នៃកសិផល ដូចជាតំបន់កែច្នៃ និងផលិតសង្ហារិម តំបន់កែច្នៃផលិតសម្ភារៈពីកៅស៊ូ តំបន់កែច្នៃផលិតម្ហូបអាហារពីសមុទ្រ តំបន់កែច្នៃចំណីអាហារសម្រាប់គោលដៅប្រើប្រាស់ក្នុងស្រុកផង និងនាំចេញផង ជាពិសេសដោយប្រើប្រាស់យន្តការភាពជាដៃគូ រវាងរដ្ឋ និងវិស័យឯកជន<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៩) | -ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួងពាណិជ្ជកម្ម<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | |
| | *៥.៤.១.១. រៀបចំផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រសម្រាប់កសិ-ឧស្សាហកម្មកម្ពុជា* | | សម្រេចពេញលេញ |
| | *៥.៤.១.២. រៀបចំច្បាប់ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា* | | យឺតយ៉ាវ |

| គោលបំណងគោលនយោបាយ/ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | ៥.៤.២. ផ្ដល់ការលើកទឹកចិត្តចំពោះក្រុមហ៊ុនទាំងឡាយណាដែលបោះទីតាំងនៅក្នុងតំបន់ទាំងនោះ (តំបន់កែច្នៃកសិផល)<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី៩) | សម្របសម្រួលដោយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ<br>ក្រសួង ស្ថាប័នចូលរួម៖<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | កំពុងអនុវត្ត |
| | ៥.៤.៣. រៀបចំនូវយន្តការសម្រួលដល់ការនាំចេញកសិផលកែច្នៃ ដោយដោះស្រាយបញ្ហាភស្តុភារកម្ម លុបបំបាត់កម្រៃក្រៅផ្លូវការ និងកែលម្អការសម្រួលពាណិជ្ជកម្ម<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១០) | -ក្រសួងពាណិជ្ជកម្ម<br>-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សម្រេចពេញលេញ |
| | ៥.៤.៤. សិក្សាកំណត់នូវមុខទំនិញអាទិភាពដែលមានសក្តានុពលកែច្នៃសម្រាប់នាំចេញ ហើយរៀបចំផែនការសកម្មភាពដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយដោយផ្អែកលើខ្សែច្រវាក់តម្លៃ ដើម្បីកំណត់មូលដ្ឋានគាំទ្រជាក់លាក់ដល់ការអភិវឌ្ឍវិស័យទាំងនោះ (ឧបសម្ព័ន្ធ ឃ, ទំព័រទី១០) | -ក្រសួងពាណិជ្ជកម្ម<br>-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សម្រេចពេញលេញ |
| វិធានការទូទៅដែលមិននៅក្នុងអន្តរាគមន៍គោលនយោបាយ<br>(៨) | ពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពនៃយន្តការត្រួតពិនិត្យ និងតាមដានការអនុវត្តគម្រោងវិនិយោគ ដើម្បីធានាការគោរពគោលការណ៍ និងលក្ខខណ្ឌនៃកិច្ចសន្យាវិនិយោគ ព្រមទាំងអនុលោមភាពនៃច្បាប់កម្ពុជាជាធរមាន (ឧបសម្ព័ន្ធ ឃ, ទំព័រទី២) | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សម្រេចពេញលេញ |
| | ធ្វើវិចារណកម្មយន្តការប្រមូលចំណូល និងកែលម្អសេវាអ្នកជាប់ពន្ធ សំដៅលើកកម្ពស់វប្បធម៌បង់ពន្ធ ក្នុងចំណោមសហគ្រាស និងអ្នកជាប់ពន្ធគ្រប់ប្រភេទ<br>(ឧបសម្ព័ន្ធ ឃ, ទំព័រទី១៤) | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សម្រេចពេញលេញ |

| គោលបំណងគោលនយោបាយ/ ផ្នែកអន្តរាគមន៍គោលនយោបាយ | វិធានការ / អនុវិធានការ | ក្រសួង ស្ថាប័នទទួលខុសត្រូវ | វឌ្ឍនភាព |
|---|---|---|---|
| | បង្កើនការផ្តល់សេវាដើម្បីឱ្យអ្នកជាប់ពន្ធងាយស្រួលទទួលព័ត៌មានពីការបង់ពន្ធ និងការលើកលែងពន្ធ<br>( ឧបសម្ព័ន្ធ ឃ, ទំព័រទី១៤ ) | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សម្រេចពេញលេញ |
| | ពិនិត្យ និងសម្រួលឡើងវិញនូវក្របខ័ណ្ឌនៃការអនុវត្ត ដោយសម្រួល ឬដកចេញនូវយន្តការទាំងឡាយណាដែលបណ្តាលឱ្យខ្វាស់គ្នារវាងនីតិវិធីនៃការយកពន្ធ និងការលើកលែងពន្ធ<br>( ឧបសម្ព័ន្ធ ឃ, ទំព័រទី១៤ ) | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សម្រេចពេញលេញ |
| | កែលម្អប្រសិទ្ធភាព និងអភិបាលកិច្ចប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ពិសេស ការវិភាជ និង ការរៀបចំកម្មវិធីវិនិយោគសាធារណៈ សម្រាប់បម្រើដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ( ឧបសម្ព័ន្ធ ឃ, ទំព័រទី២២ ) | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួងផែនការ | |
| | - *រៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈ* | | សម្រេចពេញលេញ |
| | - *កែលម្អប្រសិទ្ធភាព និងអភិបាលកិច្ចប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ពិសេស ការវិភាជសម្រាប់បម្រើដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម* | | សម្រេចពេញលេញ |
| | ផ្តល់អាទិភាពខ្ពស់នៅក្នុងកម្មវិធីវិនិយោគសាធារណៈ សម្រាប់សកម្មភាពគម្រោង និងកម្មវិធីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម កន្សោមឧស្សាហកម្ម ឬរបៀងឧស្សាហកម្ម<br>( ឧបសម្ព័ន្ធ ឃ, ទំព័រទី២៣ ) | -ក្រសួងផែនការ<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សម្រេចពេញលេញ |

**សម្គាល់៖** ពណ៌កូដ

- វិធានការច្បាស់លាស់(៨៥)
- វិធានការត្រៀម(២៤)
- វិធានការមិនច្បាស់លាស់(១៨)

# បញ្ជីពាក្យកាត់

## ពាក្យកាត់ជាភាសាខ្មែរ

| | |
|---|---|
| ក.អ.ក. | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |

## ពាក្យកាត់ជាភាសាអង់គ្លេស

| | | |
|---|---|---|
| API | Additional Progress Indicator | សូចនាករវឌ្ឍនភាពបន្ថែម |
| ASEAN | Association of Southeast Asian Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) |
| CAGR | Compound Annual Growth Rate | អត្រាកំណើនមធ្យមប្រចាំឆ្នាំ |
| EBA | Everything But Arms | ប្រព័ន្ធអនុគ្រោះពន្ធគ្រប់យ៉ាងលើកលែងតែអាវុធ |
| EIA | Environmental Impact Assessment | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន |
| ESG | Environmental, Social, and Governance | បរិស្ថាន សង្គម និងអភិបាលកិច្ច |
| FTA | Free Trade Agreement | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី |
| GSP | Generalized System of Preferences | ប្រព័ន្ធអនុគ្រោះពន្ធទូទៅ |
| IDP | Cambodia Industrial Development Policy | គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា |
| JETRO | Japan External Trade Organization | អង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន |
| KPI | Key Performance Indicator | សូចនាករគន្លឹះ |
| LDC | Least Developed Country | ប្រទេសមានកម្រិតអភិវឌ្ឍន៍តិចតួច |
| MTR | Mid-Term Review | ការវាយតម្លៃពាក់កណ្តាលអាណត្តិ |
| P.A. | Per Annum | ក្នុងមួយឆ្នាំ |
| RCEP | Regional Comprehensive Economic Partnership | កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ |
| RPS | Renewable Portfolio Standard | ស្តង់ដារនៃការបង្កើតថាមពលពីប្រភពកកើតឡើងវិញ |
| RTF | Report Template Format | ទម្រង់គំរូរបាយការណ៍ |
| STEM | Science, Technology, Engineering, and Mathematics | វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា |

| | | |
|---|---|---|
| WDI | World Development Indicators | ប្រព័ន្ធទិន្នន័យសូចនាករអភិវឌ្ឍន៍ពិភពលោករបស់ធនាគារពិភពលោក |
| WITS | World Integrated Trade Solution | ប្រព័ន្ធទិន្នន័យពាណិជ្ជកម្មពិភពលោករបស់ធនាគារពិភពលោក |

# បញ្ជីរូបភាព

## ក. រូបភាពក្នុងខ្លឹមសាររបាយការណ៍


រូបភាពទី១ តក្កកម្មអន្តរាគមន៍គោលនយោបាយ IDP ..... ៤

រូបភាពទី២ តម្លៃបន្ថែមសរុបនៃវិស័យឧស្សាហកម្មសម្រាប់មនុស្សម្នាក់..... ៥

រូបភាពទី៣ តម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាលសម្រាប់មនុស្សម្នាក់..... ៦

រូបភាពទី៤ ការនាំចេញផលិតផលកម្មន្តសាលសម្រាប់មនុស្សម្នាក់ ..... ៧

រូបភាពទី៥ ចំណែកនៃការនាំចេញកសិផលកែច្នៃក្នុងការនាំចេញសរុប..... ៨

រូបភាពទី៦ ចំណែកតម្លៃបន្ថែមនៃអនុវិស័យកម្មន្តសាល ៣នាំមុខគេធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល ...១០

រូបភាពទី៧ ចំណែកនៃការនាំចេញផលិតផលកម្មន្តសាលមិនមែនសម្លៀកបំពាក់ និងផលិតផលស្បែកជើងធៀបនឹងការនាំចេញសរុប ..... ១១

រូបភាពទី៨ ចំនួនការងារក្នុងវិស័យកម្មន្តសាលមិនមែនកាត់ដេរ..... ១៣

រូបភាពទី៩ ចំណែកការងារក្នុងវិស័យឧស្សាហកម្មធៀបនឹងចំនួនការងារសរុប ..... ១៤

រូបភាពទី១០ ជញ្ជីងពាណិជ្ជកម្មផលិតផលកម្មន្តសាល..... ១៦

រូបភាពទី១១ ការតាមដានវឌ្ឍនភាពជារួមនៃការអនុវត្តវិធានការគោលនយោបាយ IDP ក្នុងឆ្នាំ២០២១-២០២៣.......១៧

រូបភាពទី១២ ការប្រៀបធៀបវឌ្ឍនភាពជារួមនៃការអនុវត្តវិធានការគោលនយោបាយ រវាងរបាយការណ៍ MTR និងការតាមដានក្នុងឆ្នាំ២០២១-២០១៣..... ១៧


## ខ. រូបភាពក្នុងបរិសិដ្ឋ

### បរិសិដ្ឋទី១


រូបភាពទី១.១ ផលធៀបរវាងការនាំចូលផលិតផលកម្មន្តសាលធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល ..... ១

រូបភាពទី១.២ ទំហំទុនវិនិយោគឯកជនក្នុងស្រុកក្នុងវិស័យឧស្សាហកម្ម..... ១

រូបភាពទី១.៣ លំហូរទុនវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យកម្មន្តសាល..... ២

រូបភាពទី១.៤ ចំណែកនៃការវិនិយោគលើសម្ភារៈបរិក្ខារជាប់បានយូរធៀបនឹងការកកើតទុនអចល័តសរុប ..... ២

រូបភាពទី១.៥ ផលិតភាពការងារក្នុងវិស័យឧស្សាហកម្ម ..... ២

រូបភាពទី១.៦ ផលធៀបរវាងការនាំចូលផលិតផលមូលធនធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល ......... ៣

រូបភាពទី១.៧ ចំណែកនៃចំនួនសហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យកម្មន្តសាលដែលធ្វើការនាំចេញធៀបនឹងចំនួនសហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យកម្មន្តសាលសរុប ......... ៣

រូបភាពទី១.៨ ចំណែកនៃការនាំចេញរបស់សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យកម្មន្តសាល ធៀបនឹងការនាំចេញសរុប...៣

រូបភាពទី១.៩ បរិមាណទំនិញដឹកជញ្ជូនតាមគ្រប់បណ្តាញគមនាគមន៍ (សរុបតាមបណ្តាញគមនាគមន៍នីមួយៗ) ..... ៤

រូបភាពទី១.១០ បរិមាណទំនិញដឹកជញ្ជូនតាមគ្រប់បណ្តាញគមនាគមន៍ (សរុបគ្រប់បណ្តាញគមនាគមន៍) ......... ៤

រូបភាពទី១.១១ ចំនួនច្រកទ្វារព្រំដែនដែលបានបង្កើតនិងដាក់ឱ្យដំណើរការជាផ្លូវការ ......... ៤

រូបភាពទី១.១២ ចំនួនច្រកទ្វារព្រំដែនដែលបានដំឡើងកម្រិតសមត្ថភាពឱ្យមានភាពស្មើគ្នាជាមួយប្រទេសជិតខាង .. ៥

រូបភាពទី១.១៣ អត្រាអ្នកប្រើប្រាស់អ៊ិនធឺណិតល្បឿនលឿន (ក្នុងប្រជាជន ១០០ នាក់) ......... ៥

រូបភាពទី១.១៤ វិសាលភាពគ្របដណ្តប់នៃសេវាអ៊ិនធឺណែតល្បឿនលឿននៅក្នុងតំបន់ដែលមានប្រជាជនរស់នៅ ... ៥

រូបភាពទី១.១៥ សន្ទស្សន៍ភូមិដែលទទួលបានការផ្គត់ផ្គង់អគ្គិសនី ......... ៥

រូបភាពទី១.១៦ ការដាច់ចរន្តអគ្គិសនីនៅតំបន់សេដ្ឋកិច្ចពិសេស (ម៉ោង) ......... ៦

រូបភាពទី១.១៧ ការដាច់ចរន្តអគ្គិសនីនៅតំបន់សេដ្ឋកិច្ចពិសេស (ចំនួនដង) ......... ៦

រូបភាពទី១.១៨ ថ្លៃអគ្គិសនីដែលទិញពីទ្វារចរន្តអនុស្ថានីយ ......... ៦

រូបភាពទី១.១៩ ថ្លៃអគ្គិសនីដែលទិញពីខ្សែមេប្រព័ន្ធភ្នំពេញ និងកណ្តាល ......... ៧

រូបភាពទី១.២០ ថ្លៃអគ្គិសនីដែលទិញពីខ្សែមេនៅតាមខេត្ត ......... ៧

រូបភាពទី១.២១ ចំនួនក្រុមហ៊ុន និងសហគ្រាសកម្មន្តសាលថ្មីដែលបានចុះបញ្ជី ......... ៧

រូបភាពទី១.២២ ចំនួនមុខទំនិញនាំចេញ ......... ៨

រូបភាពទី១.២៣ ចំនួនមុខទំនិញកម្មន្តសាលនាំចេញ ......... ៨

រូបភាពទី១.២៤ ចំណែកនៃការនាំចេញផលិតផលកម្មន្តសាលសំខាន់ ៥នាំមុខគេ ធៀបនឹងការនាំចេញផលិតផលកម្មន្តសាលសរុប ......... ៨

រូបភាពទី១.២៥ ចំណែកនៃការនាំចេញផលិតផលកម្មន្តសាលទៅទីផ្សារសំខាន់ ៣នាំមុខគេ ធៀបនឹងការនាំចេញផលិតផលកម្មន្តសាលសរុប ......... ៩

រូបភាពទី១.២៦ ចំនួនទីផ្សារនាំចេញដែលមានទំហំលើសពី ១០លានដុល្លារអាម៉េរិក ......... ៩

រូបភាពទី១.២៧ ចំណែកនៃចំនួនការងារដែលផ្តល់ដោយសហគ្រាសធុនតូចនិងមធ្យមធៀបនឹងចំនួនការងារសរុបក្នុងវិស័យឧស្សាហកម្ម ......... ៩

រូបភាពទី១.២៨ ចំនួនសំណើនៃការដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្ម ......... ១០

រូបភាពទី១.២៩ ចំនួនប្រកាសនីយបត្រតក្កកម្មផ្តល់ជូនសរុប ......... ១០

រូបភាពទី១.៣០ អត្រាចុះបញ្ជីសហគ្រាសធុនតូច ........ ១១
រូបភាពទី១.៣១ អត្រាចុះបញ្ជីសហគ្រាសធុនមធ្យម ........ ១១
រូបភាពទី១.៣២ អត្រាចុះបញ្ជីសហគ្រាសធុនធំ ........ ១១
រូបភាពទី១.៣៣ អត្រាសហគ្រាសធុនតូចដែលកាន់បញ្ជីគណនេយ្យសាមញ្ញ ........ ១២
រូបភាពទី១.៣៤ អត្រាសហគ្រាសធុនមធ្យមដែលមានតារាងតុល្យការ ........ ១២
រូបភាពទី១.៣៥ អត្រាសហគ្រាសធុនធំដែលមានតារាងតុល្យការ ........ ១២
រូបភាពទី១.៣៦ ចំណែកនៃការចុះឈ្មោះចូលរៀននៅមធ្យមសិក្សា និងឧត្តមសិក្សា ក្នុងចំនួនប្រជាជនគ្រប់អាយុចូលរៀន ... ១៣
រូបភាពទី១.៣៧ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ ........ ១៣
រូបភាពទី១.៣៨ អត្រានិស្សិតបញ្ចប់ការសិក្សាផ្នែក STEM ........ ១៣
រូបភាពទី១.៣៩ ចំនួនសិស្សនិស្សិតបញ្ចប់ការអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈដែលមានសញ្ញាបត្រ ........ ១៤
រូបភាពទី១.៤០ ចំនួនព័ត៌មានតម្រូវការជ្រើសរើសកម្លាំងពលកម្មជំនាញ ........ ១៤
រូបភាពទី១.៤១ ចំនួនកម្លាំងពលកម្មជំនាញ ........ ១៤
រូបភាពទី១.៤២ ប្រាក់ឈ្នួលអប្បបរមា ........ ១៥
រូបភាពទី១.៤៣ ភាគរយនៃវិវាទការងារ (ធំៗ) ដែលបានដោះស្រាយ ........ ១៥
រូបភាពទី១.៤៤ អត្រាសហគ្រាសក្នុងស្រុកដែលជួបប្រទះបញ្ហាគម្លាតជំនាញ និងចំណែកនៃសហគ្រាសដែលពិបាកជ្រើសរើសកម្លាំងពលកម្ម ........ ១៥
រូបភាពទី១.៤៥ អត្រាសហគ្រាស គ្រឹះស្ថានដែលមានសេវាសង្គ្រោះអប្បបរមា ........ ១៦
រូបភាពទី១.៤៦ ចំនួនកម្មករនិយោជិតដែលទទួលបានបណ្ណសមាជិកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) ........ ១៦
រូបភាពទី១.៤៧ ចំណែកនៃតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាលធៀបនឹងការនាំចេញផលិតផលកម្មន្តសាលសរុប ........ ១៧
រូបភាពទី១.៤៨ ចំណែកនៃចំនួនគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមានម្ចាស់ភាគហ៊ុនខ្មែរកាន់កាប់ចាប់ពី៥១% ឡើងទៅ ធៀបនឹងចំនួនគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សរុប ........ ១៨
រូបភាពទី១.៤៩ ចំណែកនៃចំនួនការងារសរុបដែលបានបង្កើតដោយសហគ្រាសបរទេសធៀបនឹងចំនួនការងារសរុប ........ ១៨
រូបភាពទី១.៥០ ទំហំនាំចេញនៃកសិផលកែច្នៃ ........ ១៨

## បរិសិដ្ឋទី២

រូបភាពទី២.១ ការតាមដានវឌ្ឍនភាពនៃការអនុវត្តវិធានការ តាមគោលបំណងគោលនយោបាយក្នុងឆ្នាំ ២០២១-២០២៣ ........ ២១
រូបភាពទី២.២ ការប្រៀបធៀបលើវឌ្ឍនភាពនៃការអនុវត្តវិធានការតាមគោលបំណងគោលនយោបាយ ........ ២១

# ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## លេខាធិការដ្ឋានដឹកនាំ និងសម្របសម្រួល
## ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា


អាសយដ្ឋាន ៖ វិមានរដ្ឋាភិបាល តីរវិថីស៊ីសុវត្ថិ វត្តភ្នំ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរសព្ទ ៖ (+៨៥៥ ) ០៩៩ ៧៩៩ ៥៧៩ / (+៨៥៥) ០៩៨ ៧៩៩ ៥៧៩

គេហទំព័រ ៖ www.cdc.gov.kh